## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

# របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# សេវាប្រាក់បញ្ញើ-សន្សំ

កម្មសិក្សាពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ឈ្មោះស្ថាប័ន៖ **ធនាគារ ហុង លីអុង ក.អ សាខាផ្សារអូឡាំពិក**


តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **ធី សុភ័ក្រ្តនីត**

**សិន់ ច័ន្ទបូរី**

សាស្ត្រាចារ្យណែនាំ

លោក **សួន ចំរើន**


ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១២

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេររបាយការណ៍ ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ធី សុភ័ក្ត្រនីត និងស៊ន់ ច័ន្ទបូរី ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែក ធនាគារ និង ហិរញ្ញវត្ថុ ជំនាន់ទី១២ ក្រុម$B_4C_4$ ឆ្នាំសិក្សា២០១៨-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- លោកឪពុក អ្នកម្តាយ ដែលលោកតែងតែអប់រំ ទូន្មាន ប្រៀនប្រដៅ ចិញ្ចឹមបីបាច់ ថែរក្សា និងផ្គត់ផ្គង់គ្រប់បែបយ៉ាងដល់រូបយើងខ្ញុំ។ កូនទាំងអស់គ្នា សូមសម្តែងនូវការដឹងគុណ ដល់លោកទាំងពីរ ដែលតែងតែយកចិត្តទុកដាក់គ្រប់យ៉ាងលើការសិក្សា និងជីវភាពរស់-នៅប្រចាំថ្ងៃ។
- ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស លោក លោកស្រី ប្រធាន អនុប្រធានការិយាល័យ លោក លោកស្រីសាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានផ្តល់ដំបូន្មានល្អៗ និងបង្ហាត់បង្រៀនយើងខ្ញុំយ៉ាងយកចិត្តទុកដាក់កន្លងមក។
- លោកសាស្ត្រាចារ្យ សួន ចំរើន ដែលបានជួយណែនាំ ផ្តល់យោបល់ កែលម្អរាល់កំហុស ខុសឆ្គងទាំងឡាយដល់យើងខ្ញុំ និងបានជួយសម្របសម្រួលក្នុងការសរសេររបាយការណ៍ កម្មសិក្សាមួយនេះប្រកបដោយជោគជ័យ។
- លោកស្រី កែវ ចិន្តា នាយិកាធនធានមនុស្សនៃធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី ដែលបានអនុញ្ញាតអោយយើងខ្ញុំចុះកម្មសិក្សានៅធនាគារ ហុង លីអុង សាខាផ្សារអូឡាំ-ពិក។
- លោកស្រី ប៊ុន ពុធារី ប្រធានសាខាធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក និងបុគ្គលិក ទាំងអស់របស់ធនាគារ ដែលបានយកចិត្តទុកដាក់ក្នុងការណែនាំ និងផ្តល់ឯកសារដែល ទាក់ទងនឹងប្រធានបទដល់យើងខ្ញុំ ក្នុងកំឡុងពេលចុះកម្មសិក្សាកន្លងមក។
- មិត្តរួមថ្នាក់ដែលបានជួយលើកទឹកចិត្ត និងផ្តល់មតិនានាដល់យើងខ្ញុំ។

យើងខ្ញុំ សូមថ្លែងអំណរគុណ និងជូនពរដល់អ្នកមានគុណទាំងអស់ អោយជួបតែពុទ្ធពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ជាពិសេសសូមជូនពរអោយ ធនាគារ ហុង លីអុង ទទួលបានជោគជ័យក្នុងដំណើរការអាជីវកម្មរបស់ខ្លួន។

# **អារម្ភកថា**

បន្ទាប់ពីបានសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចអស់រយៈពេល៤ឆ្នាំកន្លងមក បានធ្វើអោយយើងខ្ញុំទទួលបាននូវចំណេះដឹងយ៉ាងច្រើន និងទទួលបានឱកាសមួយដែលសាកលវិទ្យាល័យ បានអនុញ្ញាតអោយយើងខ្ញុំ ធ្វើការស្រាវជ្រាវនូវរបាយការណ៍កម្មសិក្សានេះ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ។

របាយការណ៍កម្មសិក្សានេះ យើងខ្ញុំបានចងក្រងឡើងដោយផ្អែកលើប្រធានបទ "**សេវាប្រាក់បញ្ញើ-សន្សំ**" របស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក ដោយបានផ្តោតសំខាន់ទៅលើប្រភេទនៃគណនីប្រាក់បញ្ញើ-សន្សំ ដែលធនាគារមាន ព្រមទាំងនីតិវិធី និងលក្ខខណ្ឌតម្រូវក្នុងការបើក និងបិទគណនី។ យ៉ាងណាមិញ យើងខ្ញុំក៏បានស្វែងយល់ពីប្រតិបត្តិការមួយចំនួនទៀតរបស់ធនាគារផងដែរ។ ដោយដឹងថា សព្វថ្ងៃតម្រូវការមូលធនកាន់តែកើនឡើង ហើយធនាគារនានាបានខិតខំរិះរកវាល់មធ្យោបាយផ្សេងៗ ដើម្បីបម្រើជូនអតិថិជន និងបានស្វែងយល់ពីសារៈសំខាន់នៃសេវាមួយនេះ ទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទនេះឡើង។

យើងខ្ញុំសង្ឃឹមថា របាយការណ៍កម្មសិក្សាមួយនេះ នឹងផ្តល់ផលប្រយោជន៍ដល់យើងខ្ញុំ និងអាចផ្តល់ជាឯកសារជំនួយដល់អ្នកអាន និងអ្នកសិក្សាជំនាន់ក្រោយៗទៀត ដែលមានបំណងចង់សិក្សាស្វែងយល់ពីប្រតិបត្តិការនៃសេវាប្រាក់បញ្ញើ-សន្សំ របស់ធនាគារ ហុង លីអុង ផងដែរ។

ជាទីបញ្ចប់ យើងខ្ញុំនឹងទទួលយកនូវរាល់កំហុសខុសឆ្គងដែលកើតមានឡើងដោយអចេតនា និងមតិកែលម្អក្នុងន័យស្ថាបនាទាំងឡាយពីសំណាក់លោកសាស្រ្តាចារ្យ និងមិត្តអ្នកអានទាំងអស់ដោយក្តីរីករាយ។

# មាតិកា

**ទំព័រ**


អក្សរកាត់ ........ VII

បញ្ជីតារាង ........ VIII

បញ្ជីរូបភាព ........ IX

បញ្ជីក្រាហ្វិក ........ X

បញ្ជីឧបសម្ព័ន្ធ ........ XI

**សេចក្តីផ្តើម**

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

**ជំពូកទី១**

**រំលឹកទ្រឹស្តី**

១.១. លក្ខណៈទូទៅរបស់ធនាគារ ........ ៥

១.១.១. និយមន័យធនាគារ ........ ៥

១.២. ប្រវត្តិនៃការកកើតធនាគារ ........ ៥

១.៣. គ្រឹះស្ថានធនាគារនៅកម្ពុជា ........ ៧

១.៣.១. ធនាគារជាតិ ឬធនាគារកណ្តាល ........ ៧

១.៣.២. ធនាគារពាណិជ្ជ ........ ៨

១.៣.២.១. និយមន័យ ........ ៨

១.៣.២.២. តួនាទីរបស់ធនាគារពាណិជ្ជ ........ ៩

១.៣.២.៣. មុខងាររបស់ធនាគារពាណិជ្ជ ........ ១០

១.៣.២.៤. សេវាកម្មរបស់ធនាគារពាណិជ្ជ ........ ១១

១.៣.២.៥. សារៈសំខាន់របស់ធនាគារពាណិជ្ជ ............ ១៣
១.៤. សេវាប្រាក់បញ្ញើ ............ ១៤
១.៤.១. និយមន័យប្រាក់បញ្ញើ ............ ១៤
១.៤.២. ប្រភេទគណនីប្រាក់បញ្ញើ ............ ១៤
ក. គណនីសន្សំ ឬសញ្ជ័យ ............ ១៤
ខ. គណនីចរន្ត ............ ១៤
គ. គណនីប្រាក់បញ្ញើមានកាលកំណត់ ............ ១៤
ឃ. គណនីប្រាក់បញ្ញើគ្មានកាលកំណត់ ............ ១៥
ង. គណនីបញ្ញើសន្សំជូនដំណឹង ............ ១៥
ច. គណនី(Corporate Deposit) ............ ១៥
ឆ. គណនី(Trust)សម្រាប់ទិញ-លក់អចលនទ្រព្យ ............ ១៥
ជ. គណនីមូលនិធិសិក្សាអប់រំ ............ ១៦
ឈ. គណនីសន្សំសម្រាប់កុមារ ............ ១៦
១.៤.៣. សារៈប្រយោជន៍នៃប្រាក់បញ្ញើ ............ ១៦
ក. ចំពោះអតិថិជន ............ ១៦
ខ. ចំពោះធនាគារ ............ ១៦
គ. ចំពោះក្រុមហ៊ុន ............ ១៧
ឃ. ចំពោះសេដ្ឋកិច្ច ............ ១៧
១.៤.៤. ហានិភ័យប្រាក់បញ្ញើ-សន្សំ ............ ១៧
១.៤.៥. យុទ្ធសាស្ត្រនៃការប្រមូលប្រាក់បញ្ញើ ............ ១៨
១.៤.៥.១. ផ្សព្វផ្សាយពីសុវត្ថិភាពក្នុងការដាក់ប្រាក់បញ្ញើនៅធនាគារ ............ ១៨
១.៤.៥.២. ផ្សព្វផ្សាយពីអត្ថប្រយោជន៍ដែលទទួលបានពីការដាក់ប្រាក់បញ្ញើ ............ ១៩
១.៤.៥.៣. ផ្តល់អត្រាការប្រាក់ខ្ពស់ដល់អតិថិជន ............ ១៩
១.៤.៦. កត្តាកំណត់បម្រែបម្រួលនៃប្រាក់បញ្ញើ ............ ១៩
១.៤.៦.១. កត្តាអត្រាការប្រាក់ ............ ១៩
១.៤.៦.២. កត្តាចិត្តសាស្ត្រ ............ ១៩
១.៤.៧. ការត្រួតពិនិត្យប្រាក់បញ្ញើ ............ ១៩

១.៤.៧.១. រូបិយប័ណ្ណក្លែងក្លាយ ............ ២០
១.៤.៧.២. ការចុះហត្ថលេខាលើមូលប្បទានបត្រ ............ ២០
១.៤.៧.៣. ការផ្ញើរបស់អាជីវកម្ម ............ ២០
១.៤.៨. ការកំណត់អត្រាការប្រាក់ ............ ២១
១.៤.៨.១. ការប្រាក់ទោល ឬសាមញ្ញ ............ ២១
១.៤.៨.២. ការប្រាក់ផ្គួប ឬសមាស ............ ២១

## ជំពូកទី២

## ស្ថានភាពទូទៅរបស់ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី

២.១. ប្រវត្តិធនាគារ ហុង លីអុង ............ ២៣
២.២. ទីតាំងភូមិសាស្ត្រ អត្តសញ្ញាណ និងរូបសញ្ញា ............ ២៤
២.២.១. ទីតាំងភូមិសាស្ត្ររបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក ............ ២៤
២.២.២. អត្តសញ្ញាណ និងរូបសញ្ញា ............ ២៤
២.៣. ចក្ខុវិស័យ បេសកកម្ម និងយុទ្ធសាស្ត្រជាអាទិភាព ............ ២៥
២.៣.១. ចក្ខុវិស័យ ............ ២៥
២.៣.២. បេសកកម្ម ............ ២៥
២.៣.៣. យុទ្ធសាស្ត្រជាអាទិភាព ............ ២៥
២.៤. ផែនការ គោលដៅ និងយុទ្ធសាស្ត្រចម្បងរបស់ធនាគារសម្រាប់ឆ្នាំ២០១៨ ............ ២៦
២.៤.១. ផែនការ និងគោលដៅ ............ ២៦
២.៤.២. យុទ្ធសាស្ត្រចម្បង ............ ២៦
២.៥. ធនធានមនុស្ស ............ ២៧
២.៦. អតិថិជនគោលដៅ ............ ២៧
២.៧. ដើមទុន និងភាគទុនិក ............ ២៨
២.៨. ផលិតផល និងសេវាកម្ម ............ ២៨
២.៩. រចនាសម្ព័ន្ធនៃការគ្រប់គ្រង ............ ៣១

## ជំពូកទី៣

## សេវាប្រាក់បញ្ញើ-សន្សំ របស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក

៣.១. ប្រភេទគណនីប្រាក់បញ្ញើ-សន្សំ ............ ៣២

៣.១.១. គណនីប្រាក់សន្សំ(Savings Account) ........ ៣២
៣.១.១.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍ ........ ៣២
៣.១.១.២. លក្ខខណ្ឌ និងការកំណត់ ........ ៣២
៣.១.១.៣. អត្រាការប្រាក់ ........ ៣២
៣.១.២. គណនីចរន្ត(Current Account) ........ ៣៣
៣.១.២.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍ ........ ៣៣
៣.១.២.២. លក្ខខណ្ឌ និងការកំណត់ ........ ៣៣
៣.១.២.៣. អត្រាការប្រាក់ ........ ៣៤
៣.១.៣. គណនីប្រាក់បញ្ញើមានកាលកំណត់(Fixed Deposit Account) ........ ៣៤
៣.១.៣.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍ ........ ៣៤
៣.១.៣.២. លក្ខខណ្ឌ និងការកំណត់ ........ ៣៤
៣.១.៣.៣. អត្រាការប្រាក់ ........ ៣៤
៣.១.៤. គណនីប្រាក់សន្សំសម្រាប់កុមារ(Kid's Saving Account) ........ ៣៥
៣.១.៤.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍ ........ ៣៥
៣.១.៤.២. លក្ខខណ្ឌ និងការកំណត់ ........ ៣៦
៣.១.៤.៣. អត្រាការប្រាក់ ........ ៣៦
៣.១.៥. គណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិត(E-Saver) ........ ៣៦
៣.១.៥.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍ ........ ៣៦
៣.១.៥.២. លក្ខខណ្ឌ និងការកំណត់ ........ ៣៧
៣.១.៥.៣. វិធីបើកគណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិត ........ ៣៧
៣.១.៥.៤. អត្រាការប្រាក់ ........ ៣៨
៣.១.៦. គណនីសេវាអាទិភាព(Priority Banking) ........ ៣៨
៣.១.៦.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍ ........ ៣៨
៣.១.៦.២. លក្ខខណ្ឌ និងការកំណត់ ........ ៣៨
៣.១.៦.៣. អត្រាការប្រាក់ ........ ៣៩
៣.១.៧. គណនីចរន្តអាជីវកម្ម(Business Current Account) ........ ៣៩
៣.១.៧.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍ ........ ៣៩

៣.១.៧.២. លក្ខខណ្ឌ និងការកំណត់ ........ ៤០
៣.១.៧.៣. អត្រាការប្រាក់ ........ ៤០
៣.១.៨. គណនីអាជីវកម្មទទួលបានការប្រាក់(Business Account Bearing Interest) ........ ៤០
៣.១.៨.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍ ........ ៤០
៣.១.៨.២. លក្ខខណ្ឌ និងការកំណត់ ........ ៤១
៣.១.៨.៣. អត្រាការប្រាក់ ........ ៤១
៣.១.៩. គណនីអាជីវកម្មរូបិយប័ណ្ណបរទេស(Business Foreign Currencies Account) ...... ៤១
៣.១.៩.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍ ........ ៤១
៣.១.៩.២. លក្ខខណ្ឌ និងការកំណត់ ........ ៤២
៣.១.៩.៣. អត្រាការប្រាក់ ........ ៤២
៣.២. ការគណនាការប្រាក់ និងការកាត់ពន្ធ ........ ៤៣
៣.២.១. ការគណនាការប្រាក់ ........ ៤៣
៣.២.២. ការកាត់ពន្ធ ........ ៤៣
៣.៣. ឯកសារចាំបាច់ដើម្បីបើកគណនីប្រាក់បញ្ញើ-សន្សំ ........ ៤៣
៣.៣.១. សម្រាប់បុគ្គល ........ ៤៣
៣.៣.២. សម្រាប់កុមារ ........ ៤៤
៣.៣.៣. សម្រាប់ក្រុមហ៊ុន សហគ្រាស ឬស្ថាប័ន ........ ៤៤
៣.៣.៤. សម្រាប់អនិវាសជន ........ ៤៤
៣.៤. ប្រតិបត្តិការសេវាប្រាក់បញ្ញើ-សន្សំ ........ ៤៤
៣.៤.១. ការបើកគណនី ........ ៤៥
៣.៤.២. ការបិទគណនី ........ ៤៥
៣.៤.៣. ការកែប្រែ ........ ៤៦
៣.៥. យុទ្ធសាស្ត្រប្រមូលប្រាក់បញ្ញើ ........ ៤៧
៣.៥.១. យុទ្ធសាស្ត្រទាក់ទាញអតិថិជន ........ ៤៧
៣.៥.២. យុទ្ធសាស្ត្រថែរក្សាអតិថិជន ........ ៤៨
៣.៥.៣. យុទ្ធសាស្ត្រផ្សព្វផ្សាយ ........ ៤៨
៣.៦. ហានិភ័យប្រាក់បញ្ញើ និងវិធីទប់ស្កាត់ហានិភ័យ ........ ៤៨

៣.៦.១. រូបិយប័ណ្ណក្លែងក្លាយ ..... ៤៨
៣.៦.២. អសមតុល្យរវាងប្រាក់បញ្ញើ និងឥណទាន ..... ៤៩
៣.៦.៣. បទល្មើសលាងលុយកង្វក់ ..... ៤៩
៣.៦.៤. ការដកសាច់ប្រាក់មុនកាលកំណត់ ..... ៤៩
៣.៧. លទ្ធផលនៃការស្រាវជ្រាវ ..... ៥០
៣.៧.១. សមតុល្យប្រាក់បញ្ញើ-សន្សំពីឆ្នាំ ២០១៥ ដល់ ២០១៧ របស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក ..... ៥០
៣.៧.១.១. សមតុល្យគណនីប្រាក់សន្សំ ..... ៥០
៣.៧.១.២. សមតុល្យគណនីចរន្ត ..... ៥១
៣.៧.១.៣. សមតុល្យគណនីប្រាក់បញ្ញើមានកាលកំណត់ ..... ៥២
៣.៧.១.៣.១. សម្រាប់គណនីបុគ្គល ..... ៥២
៣.៧.១.៣.២. សម្រាប់គណនីអាជីវកម្ម ..... ៥៣
៣.៧.១.៤. សមតុល្យគណនីប្រាក់សន្សំសម្រាប់កុមារ ..... ៥៤
៣.៧.១.៥. សមតុល្យគណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិត ..... ៥៥
៣.៧.១.៦. សមតុល្យគណនីសេវាអាទិភាព ..... ៥៦
៣.៧.១.៧. សមតុល្យគណនីចរន្តអាជីវកម្ម និងអាជីវកម្មទទួលបានការប្រាក់ ..... ៥៧
៣.៨. ចំណុចខ្លាំង និងចំណុចខ្សោយ ..... ៥៨
៣.៨.១. ចំណុចខ្លាំង ..... ៥៨
៣.៨.២. ចំណុចខ្សោយ ..... ៥៩

**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

១. សេចក្តីសន្និដ្ឋាន ..... ៦០
២. ការផ្តល់អនុសាសន៍ ..... ៦១
ឯកសារយោង
ឧបសម្ព័ន្ធ

# អក្សរកាត់

ATM: Automated Teller Machine

CDM: Cash Deposit Machine

# បញ្ជីតារាង

ចំណងជើង

តារាង២.៧៖ ដើមទុនរបស់ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៧ ........ ២៨
តារាង៣.១.១.៣៖ អត្រាការប្រាក់របស់គណនីប្រាក់សន្សំ ........ ៣៣
តារាង៣.១.៣.៣៖ អត្រាការប្រាក់របស់គណនីប្រាក់បញ្ញើមានកាលកំណត់ ........ ៣៥
តារាង៣.១.៤.៣៖ អត្រាការប្រាក់របស់គណនីប្រាក់សន្សំសម្រាប់កុមារ ........ ៣៦
តារាង៣.១.៥.៤៖ អត្រាការប្រាក់របស់គណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិត ........ ៣៨
តារាង៣.១.៦.៣៖ អត្រាការប្រាក់របស់គណនីសេវាអាទិភាព ........ ៣៩
តារាង៣.១.៨.៣៖ អត្រាការប្រាក់របស់គណនីអាជីវកម្មទទួលបានការប្រាក់ ........ ៤១
តារាង៣.១.៩.២៖ សមតុល្យក្នុងគណនីអាជីវកម្មរូបិយប័ណ្ណបរទេស ........ ៤២
តារាង៣.៧.១.១៖ សមតុល្យគណនីប្រាក់សន្សំពីឆ្នាំ ២០១៥ - ២០១៧ ........ ៥០
តារាង៣.៧.១.២៖ សមតុល្យគណនីចរន្តពីឆ្នាំ ២០១៥ - ២០១៧ ........ ៥១
តារាង៣.៧.១.៣.១៖ សមតុល្យគណនីប្រាក់បញ្ញើមានកាលកំណត់ សម្រាប់គណនីបុគ្គល ពីឆ្នាំ ២០១៥ - ២០១៧ ........ ៥២
តារាង៣.៧.១.៣.២៖ សមតុល្យគណនីប្រាក់បញ្ញើមានកាលកំណត់ សម្រាប់គណនីអាជីវកម្ម ពីឆ្នាំ ២០១៥ - ២០១៧ ........ ៥៣
តារាង៣.៧.១.៤៖ សមតុល្យគណនីប្រាក់សន្សំសម្រាប់កុមារពីឆ្នាំ ២០១៥ - ២០១៧ ........ ៥៤
តារាង៣.៧.១.៥៖ សមតុល្យគណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិតពីឆ្នាំ ២០១៥ - ២០១៧ . ៥៥
តារាង៣.៧.១.៦៖ សមតុល្យគណនីសេវាអាទិភាពពីឆ្នាំ ២០១៥ - ២០១៧ ........ ៥៦
តារាង៣.៧.១.៧៖ សមតុល្យគណនីចរន្តអាជីវកម្ម និងគណនីអាជីវកម្មទទួលបានការប្រាក់ពីឆ្នាំ ២០១៥ - ២០១៧ ........ ៥៨

# បញ្ជីរូបភាព

ចំណងជើង

រូបភាព២.២.១ ទីតាំងភូមិសាស្ត្ររបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក..................២៤

រូបភាព២.២.២ រូបសញ្ញារបស់ធនាគារ ហុង លីអុង ..........................................................២៥

រូបភាព២.៩ រចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក....... ៣១

# បញ្ជីក្រាហ្វិក

ចំណាងជើង

ក្រាហ្វិក៣.៧.១.១៖ សមតុល្យគណនីប្រាក់សន្សំពីឆ្នាំ ២០១៥ - ២០១៧ ................................ ៥០
ក្រាហ្វិក៣.៧.១.២៖ សមតុល្យគណនីចរន្តពីឆ្នាំ ២០១៥ - ២០១៧ ........................................ ៥១
ក្រាហ្វិក៣.៧.១.៣.១៖ សមតុល្យគណនីប្រាក់បញ្ញើមានកាលកំណត់ សម្រាប់គណនីបុគ្គលពីឆ្នាំ ២០១៥ - ២០១៧ ........................................................................................................ ៥២
ក្រាហ្វិក៣.៧.១.៣.២៖ សមតុល្យគណនីប្រាក់បញ្ញើមានកាលកំណត់ សម្រាប់គណនីអាជីវកម្មពីឆ្នាំ ២០១៥ - ២០១៧ ................................................................................................ ៥៣
ក្រាហ្វិក៣.៧.១.៤៖ សមតុល្យគណនីប្រាក់សន្សំសម្រាប់កុមារពីឆ្នាំ ២០១៥ - ២០១៧ ............ ៥៤
ក្រាហ្វិក៣.៧.១.៥៖ សមតុល្យគណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិតពីឆ្នាំ ២០១៥ - ២០១៧៥៥
ក្រាហ្វិក៣.៧.១.៦៖ សមតុល្យគណនីសេវាអាទិភាពពីឆ្នាំ ២០១៥ - ២០១៧........................... ៥៦
ក្រាហ្វិក៣.៧.១.៧៖ សមតុល្យគណនីចរន្តអាជីវកម្ម និងគណនីអាជីវកម្មទទួលបានការប្រាក់ពីឆ្នាំ២០១៥ - ២០១៧ ................................................................................................ ៥៨

# បញ្ជីឧបសម្ព័ន្ធ

ចំណាងជើង
ឧបសម្ព័ន្ធទី១៖ ដើមទុនរបស់ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៧
ឧបសម្ព័ន្ធទី២៖ សេវា(Connect)
ឧបសម្ព័ន្ធទី៣៖ គណនីប្រាក់សន្សំ
ឧបសម្ព័ន្ធទី៤៖ គណនីចរន្ត
ឧបសម្ព័ន្ធទី៥៖ គណនីប្រាក់បញ្ញើមានកាលកំណត់
ឧបសម្ព័ន្ធទី៦៖ គណនីប្រាក់សន្សំសម្រាប់កុមារ
ឧបសម្ព័ន្ធទី៧៖ គណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិត
ឧបសម្ព័ន្ធទី៨៖ គណនីសេវាអាទិភាព
ឧបសម្ព័ន្ធទី៩៖ គណនីចរន្តអាជីវកម្ម
ឧបសម្ព័ន្ធទី១០៖ គណនីអាជីវកម្មទទួលបានការប្រាក់
ឧបសម្ព័ន្ធទី១១៖ គណនីអាជីវកម្មរូបិយប័ណ្ណបរទេស
ឧបសម្ព័ន្ធទី១២៖ ឯកសារចាំបាច់ដើម្បីបើកគណនី
ឧបសម្ព័ន្ធទី១៣៖ ពាក្យស្នើសុំបើកគណនី
ឧបសម្ព័ន្ធទី១៤៖ ពាក្យស្នើសុំបិទ និងកែប្រែគណនី
ឧបសម្ព័ន្ធទី១៥៖ លិខិតបញ្ជាក់ពីប្រភពចំណូលរបស់អតិថិជន

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលកំពុងតែអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងសេដ្ឋកិច្ច បន្ទាប់ពីបានងើបចេញពីសង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំ។ ដោយហេតុនេះហើយ ប្រទេសមួយនេះបានផ្លាស់ប្តូររបបសេដ្ឋកិច្ចរបស់ខ្លួនពីសេដ្ឋកិច្ចផែនការ មកជាសេដ្ឋកិច្ចទីផ្សារសេរីវិញដោយបើកចំហរអោយវិនិយោគិនទាំងក្នុង និងក្រៅស្រុក ងាកមកវិនិយោគទៅលើគ្រប់វិស័យនានានៅក្នុងប្រទេសកម្ពុជា។ ស្របពេលជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ និងបើកទូលាយចំពោះអាជីវកម្មលើវិស័យធនាគារយ៉ាងខ្លាំងគួរអោយកត់សម្គាល់។

យោងតាមរយៈរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជាកន្លងមកបានបង្ហាញថា គ្រឹះស្ថានហិរញ្ញវត្ថុ ជាពិសេស គឺគ្រឹះស្ថានធនាគារនេះផ្ទាល់បានបន្តការរីកចំរើនឥតឈប់ឈរ។ ប៉ុន្តែ ការរីកចំរើននេះនៅមានកម្រិតនៅឡើយ បើប្រៀបធៀបជាមួយនឹងប្រទេសអភិវឌ្ឍន៍ដទៃទៀត។

បច្ចុប្បន្ននេះ យើងសង្កេតឃើញថាវិស័យធនាគារ គឺជាពាណិជ្ជកម្មមួយប្រភេទដែលមានការអភិវឌ្ឍលឿន និងប្រែប្រួលយ៉ាងឆាប់រហ័ស។ មិនតែប៉ុណ្ណោះ វាត្រូវបានគេទទួលស្គាល់ថា ជាកោសិកាក្នុងប្រព័ន្ធសេដ្ឋកិច្ច ដែលជួយអោយចរន្តមូលធនមានដំណើរការកាន់តែប្រសើរឡើង និងបានក្លាយទៅជាវិស័យមួយដែលមានសក្តានុពល ក្នុងការជំរុញខឿនសេដ្ឋកិច្ចថែមទៀតផង។ កត្តានេះហើយ បានឆ្លុះបញ្ចាំងនូវស្ថានភាពហិរញ្ញវត្ថុមួយយ៉ាងរឹងមាំ និងបានជំរុញអោយធនាគារខិតខំយកចិត្តទុកដាក់បង្កើតនូវយុទ្ធសាស្ត្រស្វែងរកផលិតផល ឬសេវាកម្មណាដែលលេចធ្លោលើទីផ្សារប្រកួតប្រជែង និងដើម្បីផ្តល់ជូនអតិថិជនរបស់ខ្លួន អោយបានសមស្របទៅតាមតម្រូវការរបស់ពួកគេ។

ជាមួយគ្នានេះដែរ វិស័យធនាគារកំពុងតែទទួលបានការគាំទ្រ និងការជឿទុកចិត្តពីសំណាក់អតិថិជន តាមរយៈការធ្វើប្រតិបត្តិការផ្តល់ជូននូវសេវាហិរញ្ញវត្ថុដូចជា សេវាផ្តល់កម្ចី សេវាប្តូរប្រាក់ សេវាទូទាត់ សេវាផ្ទេរប្រាក់ និងជាពិសេសនោះគឺ សេវាប្រាក់បញ្ញើ-សន្សំ និងផ្តល់ជូននូវសេវាកម្មជាច្រើនទៀត ដោយភ្ជាប់មកជាមួយនឹងបច្ចេកវិទ្យាទំនើបៗ និងបង្កើតសេវាប្រតិបត្តិការហិរញ្ញវត្ថុតាមរយៈទូរស័ព្ទដៃ ម៉ាស៊ីនអេធីអឹម(ATM) ម៉ាស៊ីនដាក់ប្រាក់ស្វ័យប្រវត្តិ(CDM) ដែលជួយអោយអតិថិជនទទួលយកសេវាកម្មទាំងអស់នេះ បានកាន់តែងាយស្រួល និងប្រសើរឡើង។ ដូច្នេះហើយ យើងខ្ញុំបានសម្រេចជ្រើសរើសយកប្រធានបទ“សេវាប្រាក់បញ្ញើ-សន្សំ”ដើម្បីយកមក

សិក្សាស្វែងយល់អោយបានកាន់តែស៊ីជម្រៅ អំពីប្រតិបត្តិការនានាដែលទាក់ទងនឹងសេវាកម្មមួយនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តាមរយៈការសង្កេតមើលទៅលើប្រតិបត្តិការនីមួយៗរបស់ធនាគារ ហុង លីអុង ដែលបានផ្តល់ជូនអតិថិជន យើងបានកំណត់ថា សេវាប្រាក់បញ្ញើ-សន្សំ គឺពិតជាមានសក្តានុពល និងបានដើរតួយ៉ាងសំខាន់ក្នុងការជួយទ្រទ្រង់ ពន្លឿន និងបានជួយសម្រួលទៅដល់ប្រតិបត្តិការផ្សេងៗរបស់ធនាគារបានយ៉ាងមានប្រសិទ្ធភាព។ សេវាកម្មមួយនេះ មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ចំពោះតែធនាគារប៉ុណ្ណោះទេ ក៏ប៉ុន្តែវាបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនទៀតដល់អតិថិជនរបស់ធនាគារដូចគ្នា។ ដោយសារតែអត្ថប្រយោជន៍យ៉ាងច្រើនរបស់សេវាកម្មប្រភេទនេះ វាបានទាមទារអោយធនាគារចាំបាច់ត្រូវធ្វើការពង្រឹង និងគ្រប់គ្រងអោយបានល្អិតល្អន់ទៅលើប្រតិបត្តិការនានាដែលពាក់ព័ន្ធនឹងសេវាកម្មមួយនេះ។

កត្តានេះ បានជំរុញអោយយើងខ្ញុំចង់សិក្សាស្វែងយល់ពីបញ្ហាមួយចំនួនដូចខាងក្រោម៖

- តើធនាគារ ហុង លីអុង មានសេវាប្រាក់បញ្ញើ-សន្សំ ប៉ុន្មានប្រភេទ?
- តើធនាគារ ហុង លីអុង មាននីតិវិធី និងលក្ខខណ្ឌតម្រូវអ្វីខ្លះក្នុងការបើក និងបិទគណនីប្រាក់បញ្ញើ-សន្សំ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដោយផ្អែកលើសេវាប្រាក់បញ្ញើ-សន្សំ ដែលកំពុងមានប្រតិបត្តិការនៅធនាគារ ហុង លីអុង បានធ្វើអោយការស្រាវជ្រាវមួយនេះផ្តោតសំខាន់ទៅលើ៖

- ទិដ្ឋភាពទូទៅដែលពាក់ព័ន្ធនឹងប្រធានបទ
- ស្ថានភាពទូទៅរបស់ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី
- ប្រភេទគណនីសេវាប្រាក់បញ្ញើ-សន្សំ របស់ធនាគារ ហុង លីអុង
- ស្វែងយល់ពីប្រតិបត្តិការ នីតិវិធី និងលក្ខខណ្ឌតម្រូវ ចំពោះសេវាកម្មប្រភេទនេះ
- ធ្វើការវិភាគទៅលើភាពខ្លាំង និងភាពខ្សោយនៃសេវាប្រាក់បញ្ញើ-សន្សំ របស់ធនាគារ ហុង លីអុង។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

យើងខ្ញុំបានចុះកម្មសិក្សានៅធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក គឺបានផ្តោតសំខាន់

ទៅលើប្រធានបទ "សេវាប្រាក់បញ្ញើ-សន្សំ" ចាប់ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៧។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

តាមរយៈការចុះកម្មសិក្សា និងការចងក្រងនូវរបាយការណ៍កម្មសិក្សាមួយនេះឡើង យើងខ្ញុំបានសង្កេតឃើញថា កិច្ចការស្រាវជ្រាវមួយនេះបានចងក្រងឡើងដើម្បី៖

- បង្កើនចំណេះដឹង ដោយផ្សារភ្ជាប់ទ្រឹស្តីជាមួយនឹងការអនុវត្តជាក់ស្តែង
- បង្កើនចំណេះដឹងបន្ថែមទាក់ទងនឹងសេវាប្រាក់បញ្ញើ-សន្សំ របស់ធនាគារ ហុង លីអុង ដែលមានប្រតិបត្តិការកន្លងមក
- ទុកជាឯកសារជំនួយក្នុងការសិក្សាស្រាវជ្រាវសម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយ
- រក្សាទុកជាស្នាដៃនៅពេលបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីទទួលបានរបាយការណ៍កម្មសិក្សាមួយនេះ យើងខ្ញុំបានប្រើប្រាស់នូវវិធីសាស្ត្រដូចខាងក្រោម៖

### ក. ការប្រមូលទិន្នន័យ

ទិន្នន័យបន្ទាប់បន្សំ គឺជាប្រភេទទិន្នន័យដែលមានស្រាប់ ហើយអាចទទួលបានតាមរយៈ៖

- ការសាកសួរដោយផ្ទាល់ពីប្រធានសាខារបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក
- ឯកសារពាក់ព័ន្ធដែលមានស្រាប់នៅក្នុងធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក
- ឯកសារដែលមាននៅក្នុងបណ្ណាល័យរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យផ្សេងទៀត
- សៀវភៅដែលធ្លាប់បានសិក្សាកន្លងមក
- ការណែនាំរបស់លោកសាស្ត្រាចារ្យណែនាំ និងសាស្ត្រាចារ្យជំនាញ
- ឯកសារស្រាវជ្រាវនានារបស់និស្សិតជំនាន់មុនៗ
- និងពត៌មានដែលទទួលបានពីគេហទំព័រផ្លូវការរបស់ធនាគារ ហុង លីអុង និងគេហទំព័រដទៃទៀត ដែលមាននៅក្នុងប្រព័ន្ធអ៊ីនធើណិត។

### ខ. ការវិភាគទិន្នន័យ

ក្រោយពីទទួលបានទិន្នន័យដូចដែលបានរៀបរាប់ខាងលើ ក្រុមរបស់យើងខ្ញុំបានធ្វើការវិភាគតាមបែបពណ៌នា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះ យើងខ្ញុំបានកំណត់នូវកម្មវត្ថុសំខាន់ៗ ដើម្បីធ្វើអោយរបាយ-ការណ៍មួយនេះមានទម្រង់ និងសណ្តាប់ធ្នាប់ល្អ។

ដោយយើងបានបែងចែកជា៥ផ្នែកសំខាន់ៗដូចខាងក្រោម៖

- សេចក្តីផ្តើម៖ មានដូចជា លំនាំបញ្ហា ចំណោទបញ្ហា គោលបំណង ទំហំ និងដែនកំណត់ សារៈសំខាន់ វិធីសាស្ត្រ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- ជំពូកទី១ រំលឹកទ្រឹស្តី៖ មានដូចជា ទ្រឹស្តីដែលពាក់ព័ន្ធ និងបទពិសោធន៍នានាទាក់ទង នឹងប្រធានបទ។
- ជំពូកទី២ ស្ថានភាពទូទៅរបស់ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី៖ មានដូចជា ប្រវត្តិ ទីតាំងភូមិសាស្ត្រ អត្តសញ្ញាណ និងរូបសញ្ញា ចក្ខុវិស័យ បេសកកម្ម យុទ្ធសាស្ត្រជាអាទិភាព ផែនការ គោលដៅ និងយុទ្ធសាស្ត្រចំបងរបស់ធនាគារសម្រាប់ឆ្នាំ២០១៨ ធនធានមនុស្ស អតិថិជនគោលដៅ ដើមទុន ភាគទុនិក ផលិតផល សេវាកម្ម និងរចនា-សម្ព័ន្ធនៃការគ្រប់គ្រង របស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក។
- ជំពូកទី៣ ប្រតិបត្តិការសេវាប្រាក់បញ្ញើ-សន្សំ របស់ធនាគារ ហុង លីអុង សាខាផ្សារអូ-ឡាំពិក៖ មានដូចជា ប្រភេទគណនីប្រាក់បញ្ញើ-សន្សំ ប្រតិបត្តិការគណនីប្រាក់បញ្ញើ-សន្សំ យុទ្ធសាស្ត្រនៃការប្រមូលប្រាក់បញ្ញើ ហានិភ័យប្រាក់បញ្ញើ និងវិធីទប់ស្កាត់ហានិ-ភ័យ លទ្ធផលនៃការស្រាវជ្រាវ វិភាគចំណុចខ្លាំង និងចំណុចខ្សោយ។
- សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍



# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. លក្ខណៈទូទៅរបស់ធនាគារ

វិស័យធនាគារ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច ព្រោះវិស័យមួយនេះ អាចប្រមូលធនធានហិរញ្ញវត្ថុដែលនៅទំនេរ សម្រាប់បម្រើអោយតម្រូវការក្នុងផលិតកម្ម និងអាជីវកម្ម។ ដើម្បីផ្សារភ្ជាប់ការសន្សំជាមួយការវិនិយោគ និងកំណើនសេដ្ឋកិច្ច នោះការអភិវឌ្ឍវិស័យធនាគារ ត្រូវតែដើរទន្ទឹមគ្នាជាមួយនឹងការអភិវឌ្ឍវិស័យឯកជន សម្រាប់ជួយទ្រទ្រង់ដល់ការបង្កើនល្បឿននៃកំណើនសេដ្ឋកិច្ច ដែលត្រូវបានចាត់ទុកថា ជាមធ្យោបាយចម្បងសម្រាប់កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។[1]

### ១.១.១. និយមន័យធនាគារ

ធនាគារ គឺជាស្ថាប័នហិរញ្ញវត្ថុ ដែលធ្វើប្រតិបត្តិការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុជាច្រើនប្រភេទដូចជា ទទួលប្រាក់បញ្ញើ-សន្សំពីសាធារណជន ផ្តល់ឥណទានដល់ឯកត្តជន និងក្រុមហ៊ុនអាជីវកម្ម ដោយយកការប្រាក់ រួមទាំងផ្តល់សេវាលើការងារទូទាត់ និងធ្វើការវិនិយោគក្រោមរូបភាពជាសញ្ញាប័ណ្ណ មូលបត្រមានតម្លៃ ដើម្បីស្វែងរកប្រាក់ចំណេញដល់ម្ចាស់ក្រុមហ៊ុន។[2]

ធនាគារ ត្រូវបានគេយល់ថាជាអន្តរការីហិរញ្ញវត្ថុ ដែលផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុយ៉ាងទូលំទូលាយជាពិសេស ការទទួលប្រាក់បញ្ញើ-សន្សំ សេវាឥណទាន សេវាទូទាត់ និងសម្តែងឡើងនូវមុខងារហិរញ្ញវត្ថុនៃក្រុមហ៊ុនអាជីវកម្មនៅក្នុងសេដ្ឋកិច្ច។[3]

## ១.២. ប្រវត្តិនៃការកកើតធនាគារ[4]

ដើមកំណើតនៃការកកើតធនាគារ បានកើតឡើងដោយមានការផ្សារភ្ជាប់ជាមួយនឹងប្រវត្តិនៃការរីកចំរើននៃវិស័យមួយចំនួន នៅក្នុងប្រទេសកម្ពុជា។

ដំបូងឡើយ ធនាគារកើតឡើងតាមរយៈមុខងារប្តូរប្រាក់របស់ជាងមាស នាសម័យបុរាណ។ ដើម្បីបង្កើតភាពងាយស្រួលទៅលើពាណិជ្ជកម្មជាតិ និងអន្តរជាតិ នៅក្នុងប្រទេសនីមួយៗ គឺបាន

---

[1] Peter S.Rose & Sylvia C.Hudgins, 2013, Bank Management & Financial Services, 9th Edition, p2-4

[2] ខៃ ភូសនិត, ១៩៩៦, ការគ្រប់គ្រងធនាគារពាណិជ្ជ, ទំព័រទី១

[3] https://www.academia.edu

[4] សួន ចំរើន, ២០១២, រូបិយវត្ថុ និងធនាគារ, ទំព័រទី៦-៨

តម្រូវអោយមានចរាចរណ៍ផ្លាស់ប្តូរប្រាក់នៅតាមច្រកព្រំដែន និងមជ្ឈមណ្ឌលពាណិជ្ជកម្ម។ កត្តាទាំងនេះ បានជំរុញអោយមានការប្រកបរបរប្តូរប្រាក់ឡើង ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូររូបិយប័ណ្ណរវាងប្រទេសមួយជាមួយនឹងរូបិយប័ណ្ណប្រទេសមួយទៀត។ ដូចនេះ អ្នកប្រកបរបរប្តូរប្រាក់ ក៏ទទួលបានប្រាក់កម្រៃសមស្របពីរបរមួយនេះផងដែរ។ ចំពោះអ្នកប្រកបរបរនេះភាគច្រើនគឺជាអ្នកមាន និងពីមុនអាចជាអ្នកដែលអាចផ្តល់កម្ចីក្នុងអត្រាការប្រាក់ដែលខ្ពស់ និងរក្សាទុកលុយអោយ។ ដោយសារ ការរក្សាទុកលុយអោយមានចំនួនកាន់តែច្រើនឡើង បានធ្វើអោយចំណូលរបស់អ្នកទាំងនោះកាន់តែខ្ពស់ ដូចនេះហើយ បានធ្វើអោយមានការទូទាត់ថ្លៃទំនិញជំនួស និងការទូទាត់មិនប្រើសាច់ប្រាក់។ តាមរយៈការទូទាត់មិនប្រើសាច់ប្រាក់នេះដែរ បានធ្វើអោយពាណិជ្ជករយកប្រាក់ទៅផ្ញើកាន់តែច្រើនឡើងថែមទៀត។

ដំបូងឡើយ ធនាគារទាំងនេះបានប្រើប្រាស់មូលធនផ្ទាល់ខ្លួនក្នុងការធ្វើប្រតិបត្តិការ។ ប៉ុន្តែការធ្វើបែបនេះ មិនអាចស្ថិតនៅយូរអង្វែងបាននោះទេ ដោយម្ចាស់ធនាគារបានសង្កេតឃើញថាជានិច្ចកាលមានអ្នកផ្ញើប្រាក់ និងអ្នកស្នើសុំខ្ចី ហើយអ្នកផ្ញើទាំងនោះមិនបានដកប្រាក់ព្រមគ្នានោះទេ ជាហេតុធ្វើអោយបរិមាណលុយនៅសល់ច្រើនក្នុងធនាគារ។ ម្ចាស់ធនាគារក៏បានប្រើប្រាស់លុយទាំងនោះ ក្នុងការផ្តល់កម្ចីបន្ថែមដើម្បីបង្កើនប្រាក់ចំណេញ និងបានស្វែងរកយុទ្ធសាស្ត្រថ្មីៗដើម្បីទាក់ទាញប្រាក់បញ្ញើអោយបានច្រើនជាងមុន និងធ្វើការផ្តល់ប្រាក់កម្ចីដោយបន្ទាបអត្រាការប្រាក់។ ជាមួយគ្នានេះដែរ មានម្ចាស់ធនាគារធំៗមួយចំនួន បានពង្រីកការផ្តល់កម្ចីថ្វាយដល់ស្តេចនៅក្នុងគោលបំណងជំនួយក្នុងការធ្វើសឹកសង្គ្រាម។ ដោយសារ ប្រាក់ចំណេញដែលទទួលបានពីការផ្តល់កម្ចីមានកម្រិតខ្ពស់ វាក៏បានធ្វើអោយម្ចាស់ធនាគារជាច្រើនបានប្រើប្រាស់នូវលិខិតដែលបញ្ជាក់ប្រាក់បញ្ញើ(ជំនួសអោយការចរាចរមាស ឬ ប្រាក់) និងបានបោះពុម្ពលិខិតដើម្បីផ្តល់កម្ចី។ មិនតែប៉ុណ្ណោះ ធនាគារបានផ្តល់ប្រាក់កម្ចីលើសពីប្រាក់បញ្ញើដែលខ្លួនមាន តែការធ្វើបែបនេះពិតជាមានហានិភ័យខ្ពស់។ ស្ថានភាពទាំងនេះហើយ បានធ្វើអោយធនាគារជាច្រើនគ្មានលទ្ធភាពសងបំណុល និងក្ស័យធន។

ចំពោះការក្ស័យធនរបស់ធនាគារទាំងនេះ បានធ្វើអោយការទូទាត់ជំនួសជួបវិបត្តិ និងផ្តល់ផលអាក្រក់ចំពោះអ្នកធ្វើអាជីវកម្ម។ ម្យ៉ាងទៀត អត្រាការប្រាក់ខ្ពស់ធ្វើអោយពួកគេមិនអាចទទួលយកបាន។ ដូចនេះហើយ ពួកគេក៏បានបង្កើតធនាគារដោយខ្លួនឯងដែលហៅថា ធនាគារពាណិជ្ជ (បង្កើតឡើងដោយពាណិជ្ជករ)។ ធនាគារទាំងនេះ ក៏បានអនុវត្តនូវមុខងារដូចធនាគារមុនៗដែរ គឺ

ទទួលប្រាក់បញ្ញើ ជួយរក្សាទុកលុយ ទូទាត់ជំនួស និងផ្តល់កម្ចីជាដើម។ ដើម្បីទប់ស្កាត់ហានិភ័យ ធនាគារបានធ្វើការផ្តល់កម្ចីតែនៅរយៈពេលខ្លីប៉ុណ្ណោះ។ ម្យ៉ាងទៀត ធនាគារមិនផ្តល់កម្ចីទៅដល់អ្នកប្រើប្រាស់ និងរដ្ឋាភិបាលនោះទេ។

ប្រសិនបើធនាគារពាណិជ្ជក្ស័យធនច្រើន វាបានធ្វើអោយអ្នកផ្ញើប្រាក់នៅធនាគារទទួលរងការខាតបង់យ៉ាងធ្ងន់ធ្ងរ និងជាមូលហេតុដែលនាំអោយមានការបង្កើតឡើងនូវធនាគារទទួលប្រាក់បញ្ញើ មានន័យថា ធនាគារប្រភេទនេះមិនផ្តល់កម្ចីនោះទេ គឺគ្រាន់តែរក្សាទុកលុយជំនួសដោយយកថ្លៃសេវាប៉ុណ្ណោះ។ ស្របពេលជាមួយគ្នានេះដែរ នៅតាមប្រទេសនីមួយៗបានបង្កើតនូវធនាគារជាច្រើនប្រភេទដូចជា ធនាគារកណ្តាល ធនាគារពាណិជ្ជ ធនាគារឯកទេស ធនាគារអភិវឌ្ឍន៍ (ទាំងនេះគឺជាការបង្កើតឡើងនូវប្រព័ន្ធធនាគារមួយ)។

តាមរយៈការរីកចំរើននៃសេដ្ឋកិច្ច និងបច្ចេកវិទ្យា បានធ្វើអោយប្រតិបត្តិការរបស់ធនាគារកាន់តែមានការរីកចំរើន ចាប់តាំងពីធនាគារបុគ្គលរហូតដល់ការបង្កើតបាននូវធនាគារភាគហ៊ុន។ ក្រោយមកទៀត ធនាគារពាណិជ្ជចាប់ផ្តើមផ្តល់កម្ចីរយៈពេលវែង និងផ្តល់កម្ចីដល់អ្នកប្រើប្រាស់ អ្នកទិញភាគហ៊ុន និងបានបង្កើតឡើងនូវប្រភេទប្រាក់បញ្ញើជាច្រើនទៀត ស្របតាមតម្រូវការរបស់អតិថិជន។

## **១.៣. គ្រឹះស្ថានធនាគារនៅកម្ពុជា**

វិស័យធនាគារនៅប្រទេសកម្ពុជា គឺជាប្រព័ន្ធដែលមានពីរថ្នាក់រួមមាន វិស័យសាធារណៈ (តំណាងដោយធនាគារជាតិនៃកម្ពុជា) និងវិស័យឯកជនរួមមាន ធនាគារពាណិជ្ជ ធនាគារឯក-ទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដែលបានចូលរួមនៅក្នុងសកម្មភាពឥណទានជនបទ។[5]

### **១.៣.១. ធនាគារជាតិ ឬធនាគារកណ្តាល**[6]

ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលរបស់ប្រទេសកម្ពុជា គឺជាអាជ្ញាធររូបិយវត្ថុ និងត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជា។ បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជាគឺ កំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ សំដៅរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយពិគ្រោះជាមួយនឹងរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និង

[5] https://www.nbc.org.kh

[6] https://www.nbc.org.kh

ហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជា មានសិទ្ធិផ្តាច់មុខក្នុងការបោះផ្សាយប្រាក់រៀលដែលជារូបិយវត្ថុជាតិ។ ធនាគារជាតិនៃកម្ពុជា ជាអ្នករក្សាស្ថិរភាពរូបិយវត្ថុ។ នៅក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា ជាអ្នកផ្តល់ និងដកហូតអាជ្ញាប័ណ្ណ ចេញបទ-ប្បញ្ញត្តិ និងត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជា ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រចាំ ចេញផ្សាយរបាយការណ៍ និងព្រឹត្តបត្រផ្សេងៗ ត្រួតពិនិត្យប្រព័ន្ធទូទាត់ជាតិ ដំឡើងតារាងស្ថិតិជញ្ជីងទូទាត់ និងចូលរួមក្នុងការគ្រប់គ្រងបំណុល និងឥណទេយ្យក្រៅប្រទេស។

### ១.៣.២. ធនាគារពាណិជ្ជ

#### ១.៣.២.១. និយមន័យ

ធនាគារពាណិជ្ជ គឺជាស្ថាប័នហិរញ្ញវត្ថុ ដែលផ្តត់ផ្គង់នូវសេវាហិរញ្ញវត្ថុដូចជា ទទួលប្រាក់បញ្ញើ ផ្តល់ឥណទាន បម្រើសេវាទូទាត់ និងសេវាកម្មជាច្រើនទៀត។[7]

យោងតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជាបានចែងថា៖ ធនាគារពាណិជ្ជ គឺជានីតិបុគ្គលដែលអនុវត្តនូវប្រតិបត្តិការទទួលប្រាក់បញ្ញើ និងសន្សំ ផ្តល់ឥណទាន ជាមធ្យោបាយទូទាត់ ផាត់ទាត់ទាំងរូបិយប័ណ្ណ និងរូបិយវត្ថុជូនដល់សាធារណជន។ ដូចនេះ យើងអាចកំណត់បានថាធនាគារពាណិជ្ជ គឺជាស្ថាប័នហិរញ្ញវត្ថុដែលបម្រើជូននូវសេវាកម្មយ៉ាងតិចបីគឺ សេវាបញ្ញើ-សន្សំ សេវាឥណទាន សេវាទូទាត់ និងផាត់-ទាត់។ល។

[8]ធនាគារ គឺជានីតិបុគ្គលដែលមាននីតិសម្បទានពិសេស ក្នុងការជ្រើសរើសយកប្រតិបត្តិ-ការធនាគារ ជាមុខរបរប្រក្រតី។ ប្រតិបត្តិការដែលជាសកម្មភាពរបស់ធនាគាររួមមាន៖

- ការផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណជន ដោយមានកម្រៃរាប់បញ្ចូល ចំពោះឥណទានភតិសន្យា និងការសន្យាតាមហត្ថលេខា
- ការទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន
- ប្រព្រឹត្តិកម្ម និងដាក់អោយអតិថិជនប្រើប្រាស់មធ្យោបាយទូទាត់ជា រូបិយវត្ថុ ឬរូបិយ-ប័ណ្ណ។

[7] https://Khemsarith.wordpress.com

[8] ធនាគារជាតិនៃកម្ពុជា, មីនា ២០០៨, ក្រមច្បាប់អនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, ទំព័រទី៣៣

អង្គការណាក៏ដោយ អោយតែអនុវត្តជាប្រក្រតីនូវប្រតិបត្តិការណាមួយ ក្នុងចំណោមប្រតិបត្តិការទាំងបីខាងលើ គឺត្រូវបានចាត់ទុកថាបានធ្វើអាជីវកម្មធនាគារ តាមការជាក់ស្តែង។ ចំណែកអង្គភាពណាមួយដែលអនុវត្តតែសកម្មភាពមួយ ក្នុងចំណោមប្រតិបត្តិការទាំងបីខាងលើ ឬអនុវត្តតែផ្នែកណាមួយនៃសកម្មភាពនីមួយៗនោះ នឹងត្រូវបានអោយឈ្មោះថាជា ធនាគារឯកទេស។

### ១.៣.២.២. តួនាទីរបស់ធនាគារពាណិជ្ជ[9]

ធនាគារពាណិជ្ជមានតួនាទីដូចជា៖

- តួនាទីអន្តរការី៖ តួនាទីនេះសម្តែងឡើងតាមរយៈ ការផ្ទេរប្រាក់សន្សំដែលធនាគារទទួលបានពីបណ្តាសាធារណជន ឬអង្គភាពអាជីវកម្មផ្សេងៗ ទៅអោយអ្នកដែលខ្វះខាតមូលធន តាមរយៈការផ្តល់ឥណទាន ដើម្បីវិនិយោគជាមួយគោលដៅបង្កើនប្រាក់ចំណេញ និងលើកកម្ពស់ជីវភាពរស់នៅ អោយបានប្រសើរឡើង។
- តួនាទីទូទាត់៖ ធនាគារអនុវត្តតួនាទីនេះ ដោយជំនួសមុខអោយអតិថិជនក្នុងការទូទាត់នូវសកម្មភាពនៃការទិញទំនិញ ឬសេវាកម្មនានាដូចជា ការបង្កើតអោយអតិថិជនប្រើប្រាស់មូលប្បទានបត្រ ផ្គត់ផ្គង់នូវប្រព័ន្ធទូទាត់អេឡិចត្រូនិច ឬការចែកចាយរូបិយវត្ថុជាដើម។
- តួនាទីជាអ្នកធានា៖ ធនាគារពាណិជ្ជ សម្តែងតួនាទីនេះឡើងតាមរយៈ ការឈរខ្លួនសងបំណុលជំនួសអោយអតិថិជនរបស់ខ្លួន នៅពេលដែលពួកគេគ្មានលទ្ធភាពសង ដោយចេញលិខិតឥណទាន។
- តួនាទីគ្រប់គ្រងហានិភ័យ៖ តួនាទីនេះសម្តែងឡើងតាមរយៈ ការជួយដល់អតិថិជនក្នុងការរៀបចំផ្នែកហិរញ្ញវត្ថុ សម្រាប់ហានិភ័យនៃការបាត់បង់ទ្រព្យសម្បត្តិ ធនធានមនុស្ស ព្រមទាំងទ្រព្យសកម្មនានា។
- តួនាទីជាធនាគារវិនិយោគ៖ តាមរយៈតួនាទីនេះ ធនាគារពាណិជ្ជបានជួយដល់ក្រុមហ៊ុនសាជីវកម្ម និងរដ្ឋាភិបាល ក្នុងការរៃអង្គាសនូវមូលនិធិថ្មី បន្តការទិញ និងស្វែងរកទីផ្សារថ្មីបន្ថែមទៀត។
- តួនាទីជាអ្នកប្រឹក្សាយោបល់៖ ធនាគារ អនុវត្តតួនាទីនេះឡើង ក្នុងគោលបំណងផ្តល់ជូន

[9] Peter S.Rose & Sylvia C. Hudgins, 2013, Bank Management & Financial Services, 9th Edition

ឬចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ផ្សេងៗ ស្តីពីប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ និង បទពិសោធន៍ដែលធនាគារធ្លាប់បានឆ្លងកាត់ ជូនអតិថិជនទាំងរូបវន្តបុគ្គល នីតិបុគ្គល ទាំងក្នុង និងក្រៅប្រទេស។

- តួនាទីរក្សាគុណតម្លៃ៖ ធនាគារ បានថែរក្សាគុណតម្លៃរបស់អតិថិជន និងបញ្ជាក់ពីតម្លៃពិតរបស់ពួកគេ។
- តួនាទីជាភ្នាក់ងារ៖ តួនាទីនេះសម្តែងឡើងតាមរយៈ ការជំនួសមុខអោយអតិថិជនក្នុងការគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិរបស់ពួកគេ ឬបោះផ្សាយ និងការទិញត្រលប់មកវិញនូវមូលបត្រ។
- តួនាទីអនុវត្តគោលនយោបាយ៖ តួនាទីនេះបានសម្តែងឡើងតាមរយៈ ការអនុវត្តគោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ដើម្បីសម្រេចបាននូវទិសដៅសង្គមជាដើម។

### ១.៣.២.៣. មុខងាររបស់ធនាគារពាណិជ្ជ[10]

ធនាគារពាណិជ្ជ ត្រូវបានគេទទួលស្គាល់ថាជាអន្តរការីហិរញ្ញវត្ថុ ដែលមានមុខងារចម្បង៤ យ៉ាង គួរអោយកត់សម្គាល់រួមមាន៖

- មុខងារផ្តល់ប្រព័ន្ធទូទាត់ និងជម្រះបញ្ជី៖ ជាធម្មតា ធនាគារដើរតួនាទីពីររួមមាន ការធ្វើចរន្តសាច់ប្រាក់ និងសេវាជម្រះបញ្ជី។ ការធ្វើចរន្តសាច់ប្រាក់ សំដៅទៅដល់ការប្តូររូបិយ-ប័ណ្ណ និងការគ្រប់គ្រងប្រាក់បញ្ញើ-សន្សំ ដោយប្រាក់បញ្ញើ-សន្សំមានការកើនឡើងដោយសារអតិថិជនផ្តោតសំខាន់ទៅលើសុវត្ថិភាពនៃការថែរក្សាសាច់ប្រាក់ ដែលជាការកាត់បន្ថយនូវហានិភ័យផ្សេងៗ។ ក៏ប៉ុន្តែ ធនាគារបានដើរតួនាទីដ៏សំខាន់ក្នុងការទូទាត់ខ្នាតធំ ការទូទាត់រវាងអ្នកបង់ប្រាក់ និងអ្នកទទួលប្រាក់។ ប្រព័ន្ធទូទាត់ ក៏បានក្លាយទៅជាបណ្តាញមួយយ៉ាងសំខាន់ សម្រាប់ជួយសម្រួលទៅដល់ការផ្ទេរមូលនិធិ ពីគណនីធនាគារ ទៅកាន់ភ្នាក់ងារសេដ្ឋកិច្ចផ្សេងៗ។
- មុខងារបំលែងទ្រព្យសកម្ម៖ ជាក់ស្តែង ធនាគារបានធ្វើការប្រមូលប្រាក់បញ្ញើខ្នាតតូច និងផ្តល់កម្ចីខ្នាតធំ ទៅកាន់អ្នកវិនិយោគនានា។ ម្យ៉ាងវិញទៀត គុណភាពនៃការបំលែងកើតមានឡើង នៅពេលដែលការដាក់ប្រាក់នៅធនាគារ បានផ្តល់អត្ថប្រយោជន៍ជាច្រើន

[10] Xavier Freixas and Jean-Charles Rochet, 2008, Microeconomics of Banking, The MIT Press, Cambridge, Massachusetts, London, England, p.2-7

និងបានកាត់បន្ថយហានិភ័យពីការវិនិយោគដោយផ្ទាល់របស់អតិថិជន ហើយអតិថិជនទាំងនោះ ភាគច្រើនជាអ្នកវិនិយោគខ្នាតតូច។

- មុខងារគ្រប់គ្រងហានិភ័យ៖ ធនាគារពាណិជ្ជ ត្រូវប្រឈមមុខនឹងហានិភ័យយ៉ាងច្រើន ដូចជា ហានិភ័យឥណទាន ហានិភ័យប្រាក់បញ្ញើ។ល។ ហើយហានិភ័យទាំងនោះត្រូវតែបានគ្រប់គ្រង និងកាត់បន្ថយ។ ធនាគារពាណិជ្ជ ត្រូវប៉ាន់ស្មានលើហានិភ័យឥណទានជាមុនដោយត្រួតពិនិត្យ និងអង្កេតលើអ្នកខ្ចីប្រាក់អោយបានច្បាស់លាស់ ដោយទាមទារអោយមានការធ្វើកិច្ចសន្យាយ៉ាងត្រឹមត្រូវ និងមានដាក់វត្ថុបញ្ចាំផ្សេងៗ។ យ៉ាងណាមិញ គម្លាតរវាងអត្រាការប្រាក់នៃប្រាក់បញ្ញើ-សន្សំ និងសេវាឥណទាន គឺជាចំណូលការប្រាក់របស់ធនាគារ ហើយធនាគារត្រូវតែធ្វើអោយចំណូលនោះ មានភាពវិជ្ជមានជានិច្ច។ ចំពោះករណីខ្លះ ដែលធនាគារមិនបានផ្តល់ការប្រាក់ទៅលើគណនីចរន្ត ហើយធនាគារក៏ត្រូវប្រឈមនឹងការដកសាច់ប្រាក់ ដោយមិនបានទទួលដំណឹងជាមុន។ ដូចនេះដែរ ធនាគារពាណិជ្ជ ត្រូវតែគ្រប់គ្រងហានិភ័យក្នុងផលបត្ររបស់ខ្លួន ទាំងហានិភ័យអត្រាការប្រាក់ និងហានិភ័យសាច់ប្រាក់ ដើម្បីធានាថាធនាគារនឹងមានសាច់ប្រាក់គ្រប់គ្រាន់នៅពេលដែលអតិថិជនធ្វើការដកប្រាក់ ព្រមទាំងធ្វើអោយមានភាពវិជ្ជមាននៃចំណូលការប្រាក់ផងដែរ។
- មុខងារបង្កើតនូវពត៌មាន និងត្រួតពិនិត្យអ្នកសុំខ្ចីប្រាក់៖ ធនាគារ គ្រប់គ្រងរាល់បញ្ហានានា ដែលកើតចេញពីពត៌មានមិនពិតប្រាកដ ឬមិនគ្រប់គ្រាន់របស់អ្នកសុំខ្ចីប្រាក់។ រាល់ការវិនិយោគលើពត៌មានវិទ្យា និងបច្ចេកវិទ្យា អាចជួយអោយធនាគារមានភាពងាយស្រួលក្នុងការរក្សាទុកទិន្នន័យរបស់អតិថិជន និងត្រួតពិនិត្យពីតម្រូវការកម្ចីផ្សេងៗរបស់អតិថិជនបានប្រសើរជាងមុន និងជួយកាត់បន្ថយកម្រិតហានិភ័យរបស់អ្នកសុំខ្ចីបានផងដែរ។

### ១.៣.២.៤. សេវាកម្មរបស់ធនាគារពាណិជ្ជ

ធនាគារពាណិជ្ជ មានផ្តល់សេវាកម្មធំៗបីគឺ សេវាប្រាក់បញ្ញើ សេវាឥណទាន និងសេវាទូទាត់។ ក្រៅពីសេវាកម្មទាំងបីប្រភេទនេះ ធនាគារក៏មានសេវាកម្មផ្សេងៗទៀតដូចជា សេវាប្តូរប្រាក់ សេវាផ្ទេរប្រាក់ សេវាមូលប្បទានបត្រទេសចរណ៍ សេវាហិរញ្ញប្បទានពាណិជ្ជកម្ម និងសេវាលិខិតឥណទាន។ល។

- សេវាប្រាក់បញ្ញើ៖ គឺជាសេវាមួយប្រភេទរបស់ធនាគារ ក្នុងការទទួលយកប្រាក់បញ្ញើពីអតិថិជនមករក្សាទុក ដោយផ្តល់ជូននូវការប្រាក់ដល់ពួកគេវិញ។ សេវាប្រាក់បញ្ញើមានច្រើនប្រភេទដូចជា សេវាប្រាក់សន្សំ សេវាប្រាក់បញ្ញើមានកាលកំណត់។ល។[11]
- សេវាឥណទាន៖ គឺជាសេវាមួយប្រភេទ ដែលធនាគារផ្តល់កម្ចីដល់សាធារណជន ដើម្បីបំពេញនូវសេចក្តីត្រូវការផ្សេងៗ ប៉ុន្តែអតិថិជនមានកាតព្វកិច្ចសងត្រលប់វិញនូវប្រាក់ដើម និងការប្រាក់។ សេវាឥណទានមានច្រើនប្រភេទដូចជា ឥណទានអាជីវកម្ម ឥណ-ទានគេហដ្ឋាន ឥណទានរថយន្ត។ល។[12]
- សេវាទូទាត់៖ ធនាគារ បានក្លាយទៅជាអន្តរការីទូទាត់ធំជាងគេ នៅគ្រប់បណ្តាប្រទេសទាំងអស់។ ធនាគារ ទូទាត់ជំនួសអោយអតិថិជនរបស់ខ្លួននូវតម្លៃទំនិញ និងសេវា។ ដើម្បីអោយការទូទាត់មានភាពឆាប់រហ័ស និងងាយស្រួល ធនាគារក៏បានផ្តល់ឧបករណ៍ទូទាត់ជាច្រើនប្រភេទដល់អតិថិជនដូចជា៖ មូលប្បទានបត្រ ក្រេឌីតកាត និងដេបីតកាតជាដើម។[13]
- សេវាប្តូរប្រាក់៖ ជាសេវាមួយប្រភេទ ដែលធនាគារធ្វើការប្តូររូបិយប័ណ្ណរបស់ប្រទេសមួយជាមួយនឹងរូបិយប័ណ្ណរបស់ប្រទេសមួយទៀត ជំនួសអោយអតិថិជន។
- សេវាផ្ទេរប្រាក់៖ គឺជាសេវាផ្ទេរមូលធន បែបអេឡិចត្រូនិចឆ្លងបណ្តាញ តាមរយៈការចាត់ចែងដោយធនាគារជាច្រើនលើពិភពលោក។ សេវាមួយនេះ បានអនុញ្ញាតអោយបុគ្គលម្នាក់ ផ្ទេរប្រាក់ទៅកាន់បុគ្គលម្នាក់ទៀត ដោយប្រើពេលវេលារហ័ស មានសុវត្ថិ-ភាព និងមានភាពងាយស្រួលក្នុងការផ្ទេរទាំងក្នុងតំបន់ និងការផ្ទេរជាលក្ខណៈសកល។
- សេវាមូលប្បទានបត្រទេសចរណ៍៖ មូលប្បទានបត្រទេសចរណ៍ គឺជាទម្រង់នៃឧបករណ៍ទូទាត់ម្យ៉ាង ដែលអាចធ្វើអោយមានចរាចរណ៍ទិញលក់បាន ដោយផ្អែកតាមតម្លៃចារិក ដែលតម្រូវអោយគោរពទៅតាមលក្ខខណ្ឌនានា ដែលធនាគារបោះផ្សាយបានកំណត់។ ជាធម្មតា អតិថិជនអាចស្វែងរកជាវមូលប្បទានបត្រទេសចរណ៍ពីស្ថាប័នហិរញ្ញវត្ថុ ឬធនាគារណាមួយនៅក្នុងតំបន់ដែលខ្លួនរស់នៅ ហើយអាចទូទាត់ ឬប្តូរជា

[11] សួន ចំរើន, ២០១១-២០១២, ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ, ទំព័រទី៥៣-៥៤

[12] https://www.facebook.com/Khemsarithedu/

[13] ងួន ហេង, ២០១០, រូបិយវត្ថុ និងធនាគារ, ទំព័រទី៤២

សាច់ប្រាក់សុទ្ធមកវិញនៅតំបន់ផ្សេងទៀត ពេលដែលគាត់ធ្វើដំណើរឆ្លងកាត់តំបន់ ឬប្រទេសណាមួយ។ ក្នុងករណី ដែលមូលប្បទានបត្រទេសចរណ៍មានការខូចខាត ឬបាត់បង់ដោយប្រការណាមួយ អតិថិជននៅតែអាចទទួលបានអត្ថប្រយោជន៍ពីមូលប្បទានបត្រទេសចរណ៍ដែលខ្លួនបានទិញ។[14]

- សេវាហិរញ្ញប្បទានពាណិជ្ជកម្ម៖ គឺជាសកម្មភាពមួយ ដែលធនាគារមានសុក្រិតភាពពាណិជ្ជកម្មរវាងអ្នកលក់ និងអ្នកទិញ តាមរយៈធនាគារ។ ធនាគារ ដែលដើរតួនាទីជាអន្តរការី ក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ។[15]
- សេវាលិខិតឥណទាន៖ គឺជារបៀបទូទាត់ម្យ៉ាង ដែលគេអនុវត្តនៅក្នុងអាជីវកម្មជាពិសេស អាជីវកម្មអន្តរជាតិ។ សេវាឥណទានពាណិជ្ជកម្មមានពីរប្រភេទគឺ សេវាលិខិតឥណទានសម្រាប់ការនាំចេញ និងសេវាលិខិតឥណទានសម្រាប់ការនាំចូល។[16]
- សេវាលិខិតធនាគារ៖ ដើម្បីប្រតិបត្តិការមុខជំនួញមានទំហំធំៗ ឬគ្រោងការដែលមានតម្លៃថ្លៃ អ្នកធ្វើពាណិជ្ជកម្មចាំបាច់ត្រូវមានលិខិតធានា។ ដោយយោងទៅតាមគោលបំណង និងតម្រូវការផ្សេងៗ ធនាគារពាណិជ្ជបានបង្កើតសេវាលិខិតធានាជាច្រើនប្រភេទ ដែលអតិថិជនអាចប្រើប្រាស់ដើម្បីបំពេញនូវតម្រូវការពាណិជ្ជកម្ម។ លិខិតធានាទាំងនេះមានដូចជា លិខិតធានាលើការដឹកជញ្ជូន ការដេញថ្លៃ ការទូទាត់ ការអនុវត្តលើកិច្ចសន្យា។ល។[17]

### ១.៣.២.៥. សារៈសំខាន់របស់ធនាគារពាណិជ្ជ

ធនាគារពាណិជ្ជមានសារៈសំខាន់ដូចខាងក្រោម៖

- ជម្រុញអោយមានចលនាបម្លាស់ទីសាច់ប្រាក់រហ័សក្នុងប្រព័ន្ធសេដ្ឋកិច្ច និងពាណិជ្ជកម្ម
- បង្កើនប្រសិទ្ធភាពនូវការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់រដ្ឋាភិបាល នៅក្នុងការគ្រប់គ្រងចរន្តសាច់ប្រាក់ និងការផ្គត់ផ្គង់សាច់ប្រាក់នៅក្នុងសេដ្ឋកិច្ច
- ជួយលើកកម្ពស់ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ដោយផ្តល់អោយជាហិរញ្ញប្បទានទៅដល់អ្នកផលិត និងអ្នកវិនិយោគ ដើម្បីមានដើមទុនគ្រប់គ្រាន់ ក្នុងការពង្រីកអាជីវកម្ម

[14] សួន ចំរើន, ២០០៩, រូបិយវត្ថុ និងធនាគារ, ទំព័រទី៨
[15] ជា គឹមឡេង, ២០១៦-២០១៧, រូបិយវត្ថុ និងធនាគារ, ទំព័រទី៧៤
[16] ជា គឹមឡេង, ២០១៦-២០១៧, រូបិយវត្ថុ និងធនាគារ, ទំព័រទី៧៥
[17] ជា គឹមឡេង, ២០១៦-២០១៧, រូបិយវត្ថុ និងធនាគារ, ទំព័រទី៧៥-៧៦

និងបង្កើនផលិតកម្មផ្គត់ផ្គង់នៅលើទីផ្សារ

- ជួយជម្រុញទៅដល់ការប្រព្រឹត្តទៅនៃសកម្មភាពពាណិជ្ជកម្មអន្តរជាតិ រវាងប្រទេសនឹងប្រទេស និងផ្តល់ភាពងាយស្រួលក្នុងការទូទាត់។[18]

## ១.៤. សេវាប្រាក់បញ្ញើ

### ១.៤.១. និយមន័យប្រាក់បញ្ញើ

ប្រាក់បញ្ញើ គឺជាប្រាក់ដែលបុគ្គល សាធារណជន ឬក្រុមហ៊ុនយកមកដាក់នៅធនាគារ ដើម្បីធានានូវសុវត្ថិភាព និងទទួលបានការប្រាក់បន្ថែមពីលើប្រាក់បញ្ញើរបស់ខ្លួន ទៅតាមលក្ខខណ្ឌដែលធនាគារបានកំណត់ និងតាមប្រភេទនៃគណនីប្រាក់បញ្ញើនីមួយៗ។

### ១.៤.២. ប្រភេទគណនីប្រាក់បញ្ញើ

#### ក. គណនីសន្សំ ឬសញ្ជ័យ (Savings Account)

គណនីសន្សំ គឺជាប្រភេទគណនីប្រាក់បញ្ញើដែលសហគ្រាស ឬបុគ្គល ផ្ញើប្រាក់នៅធនាគារដើម្បីអោយធនាគាររក្សាទុក និងទទួលបានការប្រាក់។ ជាទូទៅ ចំពោះគណនីប្រភេទនេះធនាគារផ្តល់អត្រាការប្រាក់តិចជាងគណនីប្រាក់បញ្ញើមានកាលកំណត់។ ចំពោះគណនីមួយនេះមិនប្រើប្រាស់មូលប្បទានបត្រទេ គឺប្រើប្រាស់សៀវភៅធនាគារ(Pass Book) ឬកាត(ATM) ដើម្បីងាយស្រួលដកប្រាក់តាមតម្រូវការ និងគ្រប់ពេលវេលា។[19]

#### ខ. គណនីចរន្ត (Current Account)

គណនីចរន្ត គឺជាគណនីមួយប្រភេទ ដែលផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការដក ឬដាក់ប្រាក់បានគ្រប់ពេលវេលា និងតាមតម្រូវការ។ ធនាគារនឹងផ្តល់ជូនសៀវភៅមូលប្បទានបត្រហើយចំពោះការផ្តល់ជូននេះនឹងត្រូវបានគិតកម្រៃ ទៅតាមការកំណត់របស់ធនាគារ។ ហើយការប្រើប្រាស់សៀវភៅមូលប្បទានបត្រនេះ មានភាពងាយស្រួលក្នុងការដក ឬដាក់ប្រាក់ និងទូទាត់ទំនិញ ឬសេវាផ្សេងៗ។ ការប្រើប្រាស់គណនីប្រភេទនេះ អតិថិជនមិនទទួលបានការប្រាក់ទេ ហើយអតិថិជនត្រូវបង់កម្រៃសេវាលើប្រតិបត្តិការរបស់ខ្លួន។[20]

#### គ. គណនីប្រាក់បញ្ញើមានកាលកំណត់ (Fixed Deposit Account)

គណនីប្រាក់បញ្ញើមានកាលកំណត់ គឺជាគណនីមួយដែលបុគ្គល និងក្រុមហ៊ុនសាជីវកម្ម

[18] សួន ចំរើន, ២០០៧, ស្ថាប័ន និងទីផ្សាររូបិយវត្ថុ, ទំព័រទី៤-៥

[19] សួន ចំរើន, ២០១០-២០១១, រូបិយវត្ថុ និងធនាគារ, ទំព័រទី១១

[20] សួន ចំរើន, ២០១០-២០១១, រូបិយវត្ថុ និងធនាគារ, ទំព័រទី១០

ដាក់ប្រាក់បញ្ញើរបស់ពួកគេក្នុងរយៈពេលកំណត់ណាមួយ ដើម្បីទទួលបានអត្រាការប្រាក់ខ្ពស់។ អត្រាការប្រាក់ត្រូវបានផ្តល់ អាស្រ័យទៅនឹងរយៈពេលដែលផ្ញើប្រាក់គឺអាច ១ខែ ៣ខែ ៦ខែ ៩ខែ ១២ខែ។ល។ ប្រសិនបើអ្នកចង់ដកប្រាក់របស់អ្នកមុនកាលកំណត់ នោះធនាគារនឹងផ្តល់ប្រាក់ដើមជូនអតិថិជនវិញ ហើយចំពោះអត្រាការប្រាក់វិញ ធនាគារនីមួយៗមានគោលការណ៍ខុសពីគ្នា ដោយធនាគារអាចផ្តល់ជូននូវអត្រាការប្រាក់មួយក្នុងកម្រិតដែលទាប ឬមិនផ្តល់ជូន និងអាចពិន័យថែមទៀត។[21]

**ឃ. គណនីប្រាក់បញ្ញើគ្មានកាលកំណត់** (Demand Deposit Account)

គណនីប្រាក់បញ្ញើគ្មានកាលកំណត់ គឺជាគណនីប្រាក់បញ្ញើដែលក្រុមហ៊ុន សហគ្រាស ឬបុគ្គល ផ្ញើប្រាក់នៅធនាគារក្នុងគោលបំណងអោយធនាគាររក្សាទុកលុយអោយ និងទូទាត់ជំនួសតាមតម្រូវការរបស់អ្នកផ្ញើ។ ចំពោះគណនីប្រភេទនេះ ផ្តល់ភាពងាយស្រួលសម្រាប់អតិថិជនអាចដកប្រាក់បានគ្រប់ពេលវេលាដែលខ្លួនត្រូវការ ដោយមិនចាំបាច់ជូនដំណឹងទៅធនាគារជាមុនទេ។[22]

**ង. គណនីបញ្ញើសន្សំជូនដំណឹង** (Notice Withdraw Account)

គណនីបញ្ញើសន្សំជូនដំណឹង គឺជាប្រភេទគណនីដែលអាចអោយអតិថិជនដកប្រាក់បានក៏ប៉ុន្តែ អតិថិជនត្រូវជូនដំណឹងជាមុន ព្រោះថាការដកប្រាក់ដោយមិនបានជូនដំណឹងជាមុន ធនាគារនឹងអនុញ្ញាតអោយអតិថិជនដកប្រាក់ តែអតិថិជនត្រូវបង់ថ្លៃសេវាតាមគោលការណ៍របស់ធនាគារ។ ចំពោះការប្រាក់ ត្រូវបានធនាគារផ្តល់អោយខ្ពស់ជាងគណនីសន្សំធម្មតា។[23]

**ច. គណនី** (Corporate Deposit)

គណនីនេះ គឺជាផលិតផលប្រាក់បញ្ញើ-សន្សំ ដែលធនាគារផ្តល់ជូនអតិថិជនជាក្រុមហ៊ុនដែលមានសក្តានុពលធំៗ ហើយមានតម្រូវការផ្ញើសាច់ប្រាក់ក្នុងរយៈពេលកំណត់។ សមតុល្យសរុបនៃគណនីនេះ មិនត្រូវលើសពី២០% នៃសមតុល្យប្រាក់បញ្ញើសរុបរបស់ធនាគារឡើយ។[24]

**ឆ. គណនី** (Trust) **សម្រាប់ទិញ-លក់អចលនទ្រព្យ**

គណនី(Trust) គឺជាគណនីដែលធនាគារទទួលខុសត្រូវក្នុងការថែរក្សា គ្រប់គ្រង និងចាត់-

---

[21] សួន ចំរើន, ២០១០-២០១១, រូបិយវត្ថុ និងធនាគារ, ទំព័រទី១១

[22] សួន ចំរើន, ២០១០-២០១១, រូបិយវត្ថុ និងធនាគារ, ទំព័រទី១០-១១

[23] ជា គឹមឡេង, ២០១៦-២០១៧, រូបិយវត្ថុ និងធនាគារ, ទំព័រទី៧៦

[24] ជា គឹមឡេង, ២០១៦-២០១៧, រូបិយវត្ថុ និងធនាគារ, ទំព័រទី៧៧

ចែងសាច់ប្រាក់ ឬទ្រព្យសម្បត្តិរបស់អតិថិជន ទៅតាមកិច្ចសន្យា ឬកិច្ចព្រមព្រៀងរវាងធនាគារ និងអតិថិជន។[25]

**ង. គណនីមូលនិធិសិក្សាអប់រំ** (Education Fund Account)

គណនីមូលនិធិសិក្សាអប់រំ គឺជាសេវាប្រាក់បញ្ញើ-សន្សំមួយប្រភេទ ដែលធនាគារពាណិជ្ជបានទទួលខុសត្រូវថែរក្សា គ្រប់គ្រង និងចាត់ចែងសាច់ប្រាក់ ដែលអតិថិជនដាក់ប្រាក់សន្សំ ក្នុងគោលបំណងសម្រាប់ទូទាត់រាល់ការចំណាយផ្សេងៗ ដែលពាក់ព័ន្ធនឹងការសិក្សាអប់រំដូចជា បង់ថ្លៃសាលារៀន ថ្លៃសម្ភារៈសិក្សាជាដើម។ល។ អតិថិជនដែលបានដាក់ប្រាក់សន្សំនៅក្នុងគណនីមូលនិធិសិក្សាអប់រំជាមួយធនាគារពាណិជ្ជ គឺអតិថិជនមានផែនការសម្រាប់ចំណាយនៅលើការសិក្សាអប់រំច្បាស់លាស់ ដែលជាមធ្យោបាយមួយដ៏ល្អ ធ្វើអោយអតិថិជនអាចសម្រេចបានតាមគោលដៅពិតប្រាកដ។[26]

**ឈ. គណនីសន្សំសម្រាប់កុមារ** ( Kid's Saving Account)

គណនីសន្សំសម្រាប់កុមារ គឺជាគណនីមួយប្រភេទ ដែលផ្តល់ឱកាសអោយកុមារបានស្វែងយល់ពីអត្ថប្រយោជន៍នៃការសន្សំប្រាក់ ដែលត្រូវបើកជាគណនីរួមជាមួយមនុស្សពេញវ័យ ក៏ប៉ុន្តែពួកគេអាចប្រើប្រាស់លុយទាំងអស់នោះបាន លុះត្រាដល់កាលកំណត់ជាក់លាក់មួយ។[27]

### ១.៤.៣. សារៈប្រយោជន៍នៃប្រាក់បញ្ញើ

**ក. ចំពោះអតិថិជន (ម្ចាស់ប្រាក់បញ្ញើ)**

- មានសុវត្ថិភាពជាងទុកនៅផ្ទះ ជៀសវាងមានហានិភ័យផ្សេងៗ
- ទទួលបានការប្រាក់ ដែលធ្វើអោយសាច់ប្រាក់មានការកើនឡើង
- ងាយស្រួលទូទាត់ និងមានភាពងាយស្រួលក្នុងការផ្ទេរទៅកាន់ភាគីម្ខាងទៀត ដោយមិនចាំបាច់យកប្រាក់តាមខ្លួន។

**ខ. ចំពោះធនាគារ**

- ធនាគារ អាចបង្កើនមូលធនដើម្បីផ្តល់កម្ចី ដោយទទួលបានការប្រាក់ត្រលប់មកវិញតាមរយៈប្រាក់បញ្ញើរបស់អតិថិជន
- ធានានូវនិរន្តរភាពយូរអង្វែង បង្កើនប្រាក់ចំណេញ និងតម្លៃភាគហ៊ុនរបស់ធនាគារ

[25] ជា គឹមឡេង, ២០១៦-២០១៧, រូបិយវត្ថុ និងធនាគារ, ទំព័រទី៧៧

[26] ជា គឹមឡេង, ២០១៦-២០១៧, រូបិយវត្ថុ និងធនាគារ, ទំព័រទី៧៧

[27] https://www.capitalone.com/bank/savings-accounts/kids-savings-account

- មានមូលធនគ្រប់គ្រាន់ក្នុងការទូទាត់បំណុលផ្សេងៗ
- បង្កើនវិសាលភាពអាជីវកម្មរបស់ខ្លួន។

**គ. ចំពោះក្រុមហ៊ុន**

- មានប្រភពហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការដំណើរការ និងពង្រីកអាជីវកម្មរបស់ខ្លួន
- មានទុនបង្វិលគ្រប់គ្រាន់ នៅពេលអាជីវកម្មជួបប្រទះនូវបញ្ហាហិរញ្ញវត្ថុ។

**ឃ. ចំពោះសេដ្ឋកិច្ច**

- អំណោយផលដល់ការអភិវឌ្ឍ និងការវិនិយោគលើវិស័យឯកជននានា
- នៅពេលដែលអតិថិជនយកប្រាក់របស់ខ្លួនទៅដាក់ផ្ញើនៅធនាគារនោះ វាបានធ្វើអោយចំណូលរបស់គេកើនឡើង តាមរយៈការប្រាក់ដែលទទួលបានពីធនាគារ
- នៅពេលដែលចំណូលកើនឡើង នាំអោយតម្រូវការកើនឡើង ហើយការផ្គត់ផ្គង់ក៏មានការកើនឡើងដែរ
- ស្របពេលដែលតម្រូវការកើនឡើង វាបានធ្វើអោយសហគ្រាស ឬក្រុមហ៊ុនធ្វើការពង្រីកនូវអាជីវកម្មរបស់ខ្លួន ដូចនេះហើយគេត្រូវការកម្លាំងពលកម្មបន្ថែម ហើយកត្តានេះបានធ្វើអោយអត្រានិកម្មភាពថយចុះ
- ប្រសិនបើការផ្គត់ផ្គង់កើនឡើង នោះការនាំចេញនឹងកើនឡើងដែរ ហើយធ្វើអោយមានតម្រូវការរូបិយវត្ថុជាតិច្រើន ជាហេតុនាំអោយតម្លៃរូបិយវត្ថុជាតិកើនឡើងដែរ កត្តានេះបានជំរុញអោយវិស័យសេដ្ឋកិច្ចជាតិមានការរីកចំរើន។

**១.៤.៤. ហានិភ័យប្រាក់បញ្ញើ-សន្សំ**[28]

ហានិភ័យដែលអាចនឹងកើតមានឡើងទាក់ទងនឹងប្រាក់បញ្ញើ-សន្សំ ដែលធនាគារអាចនឹងប្រឈមរួមមាន៖

- ហានិភ័យទីផ្សារ៖ ហានិភ័យនេះ កើតមានឡើងដោយសារតែ បម្រែបម្រួលតម្លៃនៃប្រាក់បញ្ញើ-សន្សំ។ ហានិភ័យទីផ្សារចម្បងរបស់ សេវាប្រាក់បញ្ញើ-សន្សំ គឺជាហានិភ័យអត្រាការប្រាក់ ដែលកើតឡើងពីបម្រែបម្រួលនៃអត្រាការប្រាក់ ហើយធ្វើអោយអត្រាការប្រាក់លើប្រាក់បញ្ញើ-សន្សំ មានកម្រិតទាបជាងអត្រាការប្រាក់លើប្រាក់កម្ចី ជាហេតុនាំអោយ

[28] Anthony M.Santomero, 1997, Commercial Bank Risk Management: Analysis of the Process, Financial Institutions Center, University of Pennsylvania, p.8-10

ប្រាក់ចំណេញថយចុះ។

- ហានិភ័យសន្ទនីយភាព៖ ធនាគារ អាចនឹងជួបប្រទះនូវបញ្ហាធំ ប្រសិនបើធនាគារគ្មានប្រាក់គ្រប់គ្រាន់ នៅពេលដែលអតិថិជនធ្វើការដកប្រាក់ ឬនៅពេលដែលអតិថិជនធ្វើការដកប្រាក់ទាំងអស់ពីធនាគារ នោះវាអាចបណ្តាលអោយធនាគារមានបញ្ហាក្នុងការផ្តល់កម្ចីត្រលប់ទៅវិញ ថែមទាំងធ្វើអោយអតិថិជនបាត់បង់ទំនុកចិត្តមកលើធនាគារ។
- ហានិភ័យប្រតិបត្តិការ៖ ហានិភ័យនេះ បានធ្វើអោយប៉ះពាល់ដល់ដំណើរប្រតិបត្តិការប្រាក់បញ្ញើ-សន្សំ ដែលបណ្តាលមកពីបញ្ហានៃបច្ចេកវិទ្យា ធនធានមនុស្សមិនគ្រប់គ្រាន់ និងការថយចុះនៃប្រាក់បញ្ញើរបស់អតិថិជនជាដើម។
- ហានិភ័យដែលទាក់ទងនឹងបញ្ហាលាងលុយកង្វក់៖ បច្ចុប្បន្ននេះ បណ្តាធនាគារនានា និងរដ្ឋាភិបាល គឺមានការព្រួយបារម្ភទៅលើបញ្ហាលាងលុយកង្វក់ តាមរយៈការផ្ទេរប្រាក់តាមគណនីធនាគារ ដើម្បីអោយប្រាក់ទាំងនោះក្លាយជាស្របច្បាប់វិញ។ កត្តានេះ បានបង្កឡើងជាហានិភ័យចំពោះធនាគារ នៅពេលមានដំណើរការទទួលប្រាក់ទាំងអស់នោះ ដោយសារតែធនាគារមិនអាចបដិសេធ ចំពោះសេវាផ្ទេរលុយ ឬប្រាក់បញ្ញើ-សន្សំ ពីក្រៅប្រទេសបានឡើយ។

### ១.៤.៥. យុទ្ធសាស្ត្រនៃការប្រមូលប្រាក់បញ្ញើ

ប្រាក់បញ្ញើរបស់អតិថិជន គឺជាប្រភពធនធានមួយដ៏សំខាន់បំផុតសម្រាប់ប្រតិបត្តិការនានារបស់ធនាគារ។ ធនាគារបានបង្កើតនូវសេវាប្រាក់បញ្ញើ-សន្សំជូនដល់អតិថិជន ក្នុងគោលបំណងដើម្បីប្រមូលនូវសាច់ប្រាក់ដែលនៅទំនេរយកទៅធ្វើការវិនិយោគ និងផ្តល់កម្ចីទៅកាន់អតិថិជនដែលខ្វះមូលធន និងទទួលបានប្រាក់ចំណេញពីការប្រាក់ ដែលអតិថិជនបង់សងត្រលប់មកវិញ។ ដើម្បីអោយប្រតិបត្តិការទទួលបានជោគជ័យ ធនាគារខិតខំរិះរកនូវមធ្យោបាយ និងយុទ្ធសាស្ត្រល្អៗមួយចំនួនដូចជា៖

#### ១.៤.៥.១. ផ្សព្វផ្សាយពីសុវត្ថិភាពក្នុងការដាក់ប្រាក់បញ្ញើនៅធនាគារ

ធនាគារ ត្រូវធ្វើការផ្សព្វផ្សាយជូនដល់សាធារណជន អំពីភាពរឹងមាំ និងនិរន្តរភាពនៃបរអាជីវកម្មរបស់ខ្លួន និងហានិភ័យនានា ដែលអាចនឹងកើតមានឡើង នៅពេលដែលអតិថិជនទុកប្រាក់នៅគេហដ្ឋាន។ ជាពិសេស ត្រូវផ្សព្វផ្សាយពីអត្ថប្រយោជន៍ ដែលអតិថិជនទទួលបាន នៅពេលដែលដាក់ប្រាក់នៅធនាគារ នោះអតិថិជននឹងជឿថា ការដាក់ប្រាក់នៅធនាគារ គឺទទួលបាន

បានការការពារ យ៉ាងល្អប្រសើរ និងមានសុវត្ថិភាព។

**១.៤.៥.២. ផ្សព្វផ្សាយពីអត្ថប្រយោជន៍ដែលទទួលបានពីការដាក់ប្រាក់បញ្ញើ**

នៅពេលដែលអតិថិជនដាក់ប្រាក់បញ្ញើនៅធនាគារ គឺមិនត្រឹមតែទទួលបាននូវសុវត្ថិភាពក្នុងការថែរក្សានូវសាច់ប្រាក់ប៉ុណ្ណោះទេ អតិថិជនថែមទាំងទទួលបានការប្រាក់ រួមជាមួយនឹងការធ្វើប្រតិបត្តិការផ្សេងៗបានរហ័ស និងអត្ថប្រយោជន៍ផ្សេងទៀត។ កត្តាទាំងនេះ ក៏អាចធ្វើអោយធនាគារទទួលបានការពេញចិត្តពីអតិថិជន និងអាចបង្កើនប្រាក់បញ្ញើក្នុងធនាគារថែមទៀតផង។

**១.៤.៥.៣. ផ្តល់អត្រាការប្រាក់ខ្ពស់ដល់អតិថិជន**

ការផ្តល់អត្រាការប្រាក់មួយក្នុងកម្រិតដែលខ្ពស់ជូនដល់អតិថិជន បានជួយជំរុញចិត្តអតិថិជន អោយពិចារណាក្នុងការដាក់ប្រាក់នៅធនាគារ។ ដូចនេះ ធនាគារក៏អាចទាក់ទាញអតិថិជនបានមួយកម្រិតថែមទៀត កាលណាធនាគារផ្តល់ជូនអត្រាការប្រាក់ខ្ពស់ជាងធនាគារដទៃទៀត។

**១.៤.៦. កត្តាកំណត់បម្រែបម្រួលនៃប្រាក់បញ្ញើ**

មានកត្តាជាច្រើន ដែលជះឥទ្ធិពលទៅលើបម្រែបម្រួលនៃចំនួនប្រាក់បញ្ញើក្នុងធនាគារៈ

**១.៤.៦.១. កត្តាអត្រាការប្រាក់**

ដើម្បីទាក់ទាញអតិថិជន និងយកឈ្នះទៅលើដៃគូប្រកួតប្រជែង ធនាគារបានធ្វើការដំឡើងអត្រាការប្រាក់។ ប្រសិនបើ ធនាគារផ្តល់អត្រាការប្រាក់ក្នុងកម្រិតទាបជាងធនាគារដទៃនោះ វានឹងធ្វើអោយចំនួនប្រាក់បញ្ញើនៅក្នុងធនាគារមានការថយចុះជាមិនខាន។

**១.៤.៦.២. កត្តាចិត្តសាស្រ្ត**

អតិថិជនមួយចំនួន អាចមានការស្ទាក់ស្ទើរក្នុងការផ្ញើប្រាក់នៅធនាគារ ប្រសិនបើប្រទេសជួបប្រទះនូវបញ្ហាមួយចំនួនដូចជា សេដ្ឋកិច្ចធ្លាក់ចុះ សង្គ្រាម នយោបាយ គ្រោះធម្មជាតិ និងបញ្ហាប្រឈមដទៃទៀត ដោយពួកគេយល់ថានឹងមានផលលំបាកក្នុងការទទួលបាន ឬដកប្រាក់ត្រលប់មកវិញនៅក្នុងស្ថានភាពទាំងអស់នេះ។ កត្តាទាំងនេះហើយ ដែលអាចនឹងធ្វើអោយប្រាក់បញ្ញើរបស់ធនាគារមានការធ្លាក់ចុះ។

**១.៤.៧. ការត្រួតពិនិត្យប្រាក់បញ្ញើ**

មុនពេលទទួលប្រាក់បញ្ញើពីអតិថិជន គឺជាការសំខាន់ណាស់ ដែលត្រូវធ្វើការត្រួតពិនិត្យនូវប្រាក់បញ្ញើទាំងនោះ។ ដូច្នេះ ធនាគារត្រូវតែដឹងនូវអ្វីដែលខ្លួនគួរទទួលយក និងមិនអាចទទួលយកបាន។

### **១.៤.៧.១. រូបិយប័ណ្ណក្លែងក្លាយ**

រូបិយប័ណ្ណក្លែងក្លាយ គឺជាក្រដាសប្រាក់ ឬកាក់ដែលត្រូវបានផលិតឡើងដោយមានទម្រង់ទ្រង់ទ្រាយ និងមានរូបភាពដូចគ្នាបេះបិតនឹងរូបិយវត្ថុពិតប្រាកដ។ ការកាន់កាប់រូបិយប័ណ្ណបានចោទជាបញ្ហាមួយចំនួនដល់បេឡាករ ហើយបញ្ហាដែលសំខាន់នោះ គឺត្រូវតែបញ្ជាក់អោយបានច្បាស់ថា រូបិយប័ណ្ណដែលខ្លួនកំពុងកាន់នោះជារូបិយប័ណ្ណពិត ឬរូបិយប័ណ្ណក្លែងក្លាយ ដោយសារតែការក្លែងបន្លំក្រដាសប្រាក់ មានការកើនឡើងស្របនឹងកំណើននៃឧបករណ៍ថតចម្លងទំនើបៗ ដែលធ្វើអោយមានការពិបាកក្នុងការត្រួតពិនិត្យ។

ប្រសិនបើពិនិត្យឃើញរូបិយប័ណ្ណក្លែងក្លាយ ធនាគារិកដែលទទួលបន្ទុក ត្រូវតែដកចំនួនប្រាក់ក្លែងក្លាយចេញពីប្រាក់បញ្ញើរបស់អតិថិជន រួចរៀបចំបញ្ជូនប្រាក់ក្លែងក្លាយទាំងនោះជូនទៅធនាគារកណ្តាលជាបន្ទាន់ ដើម្បីធ្វើការត្រួតពិនិត្យម្តងទៀត។ សម្រាប់ប្រាក់ក្លែងក្លាយ ធនាគារនឹងមិនបញ្ជូនទៅអោយអតិថិជនវិញជាដាច់ខាត។ ចំពោះអ្នកមានចេតនាក្លែងបន្លំ ឬអ្នកប្រព្រឹត្តបទល្មើសនេះនឹងត្រូវផ្តន្ទាទោសទៅតាមច្បាប់របស់ប្រទេសនីមួយៗដែលបានចែង។[29]

### **១.៤.៧.២. ការចុះហត្ថលេខាលើមូលប្បទានបត្រ**

មូលប្បទានបត្រដែលបានបង់ចូលដើម្បីដកជាសាច់ប្រាក់ ឬចុះឥណទាន ទៅក្នុងគណនីប្រាក់បញ្ញើ គឺបេឡាករត្រូវតែត្រួតពិនិត្យដោយប្រុងប្រយ័ត្នជាទីបំផុត ដើម្បីធានាពីភាពត្រឹមត្រូវនៃហត្ថលេខារបស់បុគ្គលដែលមានសិទ្ធិចុះហត្ថលេខា នៅក្នុងមូលប្បទានបត្រនោះ។ សម្រាប់ការចុះហត្ថលេខានេះ គឺបានជំនួយដល់ការតាមដានក្នុងកិច្ចបញ្ជីការគណនេយ្យ និងដើម្បីជាសក្ខីកម្មដល់ការចំណាយសងដល់ភាគីណាមួយជាអ្នកទទួលផល។

### **១.៤.៧.៣. ការផ្ញើរបស់អាជីវកម្ម**

ជាទូទៅ នៅពេលដែលមានប្រតិបត្តិការបង់ប្រាក់ ឬមូលប្បទានបត្រកើតឡើង បេឡាករនឹងដំណើរការរាប់នូវចំនួនសាច់ប្រាក់ផ្ញើរបស់អតិថិជន និងពិនិត្យភ្លាមៗនៅនឹងកន្លែងបញ្ជរទទួលប្រាក់។ ទោះយ៉ាងណា ការបង់ចូលនូវសាច់ប្រាក់ ឬកាក់ក្នុងបរិមាណច្រើនរបស់អតិថិជនជាពាណិជ្ជករ គឺមិនអាចបញ្ចប់ដំណើរការរាប់ប្រាក់ ក្នុងរយៈពេលខ្លីបានឡើយ។ ដូច្នេះ ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជនប្រភេទនេះ មានធនាគារខ្លះបានអនុញ្ញាតអោយបេឡាករ ទទួលប្រាក់បញ្ញើទាំងនោះទុកជាបណ្តោះអាសន្នសិន ដោយមិនចាំបាច់ឆ្លងកាត់ការរាប់ប្រាក់ជាក់ស្តែង

[29] ធនាគារជាតិនៃកម្ពុជា, មីនា ២០០៨, ក្រមច្បាប់អនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

ឬផ្ទៀងផ្ទាត់ នៅពេលទទួលប្រាក់ទាំងនោះឡើយ។ ក្នុងករណីនេះ ធនាគារ និងអតិថិជននោះ បានព្រមព្រៀងគ្នាជាមុនថា ចំនួនប្រាក់បញ្ញើទាំងនោះនឹងត្រូវរាប់ ហើយនឹងផ្ទៀងផ្ទាត់ជាក់ស្តែង នៅពេលក្រោយ ដោយផ្អែកតាមប្រព័ន្ធនៃការត្រួតពិនិត្យទូទៅ។

### ១.៤.៨. ការកំណត់អត្រាការប្រាក់

ការកំណត់អត្រាការប្រាក់ និងការគណនាការប្រាក់ជូនអតិថិជន អាចជាយុទ្ធសាស្ត្រមួយ ក្នុងការទាក់ទាញប្រាក់បញ្ញើ និងរក្សាលំនឹងប្រតិបត្តិការសមតុល្យសាច់ប្រាក់ក្នុងធនាគារ។ ការគណនាការប្រាក់មានពីររបៀបគឺ ការប្រាក់ទោល និងការប្រាក់ផ្ទួប។

#### ១.៤.៨.១. ការប្រាក់ទោល ឬសាមញ្ញ[30]

ការប្រាក់ទោល ឬសាមញ្ញ គឺជាការប្រាក់ដែលគិតទៅលើតែប្រាក់ដើម នៅក្នុងកំឡុងពេលមួយ។ ការប្រាក់នៅក្នុងកំឡុងពេលនីមួយៗ មិនបូកបញ្ចូលជាមួយប្រាក់ដើម ដើម្បីយកមកគិតការប្រាក់នៅចុងគ្រាឡើយ។

រូបមន្ត១.៤.៨.១ រូបមន្តការប្រាក់ទោល ឬសាមញ្ញ

$$I = PV \times r \times t$$

- I: ការប្រាក់
- PV: ប្រាក់ដើម
- r: អត្រាការប្រាក់
- t: រយៈពេលផ្ញើប្រាក់

ឧទាហរណ៍៖ កញ្ញាបានផ្ញើប្រាក់នៅធនាគារមួយចំនួន ១,០០០ដុល្លារ ជាមួយអត្រាការប្រាក់ប្រចាំឆ្នាំគឺ ៥%។ តើកញ្ញានឹងទទួលបានការប្រាក់ប៉ុន្មាន ប្រសិនបើនាងផ្ញើប្រាក់ទាំងនោះក្នុងរយៈពេល២ឆ្នាំ?

ដូចនេះ ការប្រាក់ដែលកញ្ញាទទួលបានគឺ ១,០០០ x ៥% x ២ = ១០០ដុល្លារ

#### ១.៤.៨.២. ការប្រាក់ផ្ទួប ឬសមាស[31]

ការប្រាក់ផ្ទួប ឬសមាស គឺជាការប្រាក់ដែលគេគណនាឡើង នៅចុងកំឡុងពេលនីមួយៗ

[30] ជា សែម, ២០១៥-២០១៦, គណិតវិទ្យាសេដ្ឋកិច្ច, ទំព័រទី២៥

[31] ព្រុំ សុគុណា, ២០០៩, គណិតវិទ្យាវិភាគ សម្រាប់ថ្នាក់មូលដ្ឋាន, ទំព័រទី១៣

ហើយការប្រាក់ដែលទទួលបាននៅចុងកំឡុងពេលទី១ ត្រូវបូកបន្ថែមនឹងប្រាក់ដើម ដើម្បីធ្វើជាប្រាក់ដើមនៅកំឡុងពេលទី២ សម្រាប់គិតការប្រាក់។ គេនឹងធ្វើរបៀបនេះ រហូតដល់កំឡុងពេលចុងក្រោយ។

រូបមន្ត១.៤.៨.២ រូបមន្តការប្រាក់ផ្គួប ឬសមាស

$$I = FV - PV$$

ដែល

$$FV = PV(1+r)^t$$

- I: ការប្រាក់
- FV: ប្រាក់អនាគត
- PV: ប្រាក់ដើម
- r: អត្រាការប្រាក់
- t: រយៈពេលផ្ញើប្រាក់

ឧទាហរណ៍៖ កញ្ញាបានផ្ញើប្រាក់នៅធនាគារមួយចំនួន ១,០០០ដុល្លារ ជាមួយអត្រាការប្រាក់សមាសប្រចាំឆ្នាំ ៥%។ តើកញ្ញានឹងទទួលបានការប្រាក់ប៉ុន្មានក្នុងរយៈពេល២ឆ្នាំ?

យើងបាន FV = ១,០០០(១+៥%)$^{២}$ = ១,១០២.៥ដុល្លារ

ដូចនេះ ការប្រាក់ដែលកញ្ញាទទួលបានគឺ ១,១០២.៥ - ១,០០០ = ១០២.៥ដុល្លារ

# ជំពូកទី២

# ស្ថានភាពទូទៅរបស់ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី

## ២.១. ប្រវត្តិធនាគារ ហុង លីអុង

ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធនៃធនាគារ ហុង លីអុង បើហាដ ដែលជាក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រជាសាធារណៈ នៅប្រទេសម៉ាឡេស៊ី និងត្រូវជាសមាជិកនៃសម្ព័ន្ធ ហុង លីអុង ដែលមានការិយាល័យកណ្តាលស្ថិតនៅ ទីក្រុងគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។

ធនាគារ បានទទួលអាជ្ញាប័ណ្ណប្រតិបត្តិការពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣ និងបើកសម្ពោធទីស្នាក់ការកណ្តាលជាផ្លូវការ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣។ បន្ទាប់មកទៀត ធនាគារក៏ទទួលបានការអនុញ្ញាតអោយបើកដំណើរការនូវសាខា៤ទៀត នាដើមខែមករា ឆ្នាំ២០១៥ ដើម្បីបម្រើជូនអតិថិជនបុគ្គល និងអតិថិជនអាជីវកម្មនូវផលិតផល និងសេវាកម្មរបស់ធនាគារ នៅក្នុងប្រទេសកម្ពុជា។

ដើម្បីបង្កើតមូលដ្ឋានពាណិជ្ជកម្ម និងគោលការណ៍គុណតម្លៃដ៏រឹងមាំរបស់ខ្លួន ធនាគារក៏បានបោះជំហានមកកាន់តែខិតជិតអតិថិជនរបស់ខ្លួន នៅក្នុងប្រទេសកម្ពុជា តាមរយៈទីស្នាក់ការកណ្តាល ដែលមានទីតាំងស្ថិតនៅតំបន់យុទ្ធសាស្ត្រពាណិជ្ជកម្ម ក្នុងរាជធានីភ្នំពេញ។ គិតត្រឹមឆ្នាំ២០១៧ ធនាគារមានសាខាចំនួន៥ ម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិ(ATM)ចំនួន១២ និងម៉ាស៊ីនដាក់ប្រាក់(CDM)ចំនួន៣ រួមទាំងបណ្តាញសេវាកម្មតាមប្រព័ន្ធអេឡិចត្រូនិចដែលរួមមាន ស្វ័យការិយាល័យទំនាក់ទំនងអតិថិជន និងសេវាធនាគារតាមអ៊ីនធើណិត។

ធនាគារ កំពុងតែបន្តកសាងកេរ្តិ៍ឈ្មោះក្នុងការបំពេញតម្រូវការអតិថិជន តាមរយៈការផ្តល់ជូននូវសេវាហិរញ្ញវត្ថុដែលមានលក្ខណៈទូលំទូលាយ និងប្រកបទៅដោយជំនាញវិជ្ជាជីវៈ នៅក្នុងប្រទេសកម្ពុជា។ ធនាគារ បានផ្តល់សេវាកម្មដ៏សម្បូរបែបរួមមាន សេវាប្រាក់បញ្ញើ-សន្សំ ឥណទាន ហិរញ្ញប្បទានពាណិជ្ជកម្ម ទីផ្សារហិរញ្ញវត្ថុអន្តរជាតិ និងសេវាហិរញ្ញប្បទានផ្សេងៗទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនបុគ្គល និងអាជីវកម្ម។

កន្លងមកនេះ ធនាគារបានខិតខំប្រឹងប្រែងឥតឈប់ឈរ និងបន្តផ្តោតជាចម្បងលើឌីជីថលភាវូបនីយកម្ម ដោយបន្តដាក់បញ្ចូលនូវនីតិវិធី និងសេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិច និងឌីជីថល ព្រមទាំងធ្វើអោយការប្រើប្រាស់សេវាទាំងនេះកាន់តែមានភាពងាយស្រួល និងប្រសិទ្ធភាព

ក្នុងគោលបំណងផ្តល់បទពិសោធន៍សេវាធនាគារដ៏ល្អប្រសើរជូនអតិថិជន។ ធនាគារ ទទួលបានមរតកមួយដ៏រឹងមាំពីក្រុមហ៊ុនមេរបស់ខ្លួនគឺ ធនាគារ ហុង លីអុង បើហាដ ដែលជាស្ថាប័នផ្តល់ហិរញ្ញវត្ថុឈានមុខគេមួយនៅក្នុងប្រទេសម៉ាឡេស៊ី ដែលមានប្រវត្តិជាង១០០ឆ្នាំ មកហើយ។

## ២.២. ទីតាំងភូមិសាស្ត្រ អត្តសញ្ញាណ និងរូបសញ្ញា

### ២.២.១. ទីតាំងភូមិសាស្ត្ររបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក

ធនាគារតែងតែសិក្សា និងស្វែងរកគ្រប់វិធីក្នុងការទទួលបាននូវវឌ្ឍនភាពដ៏ខ្ជាប់ខ្ជួន និងភាពរហ័ស នៅប្រទេសកម្ពុជា ដើម្បីធានាអោយបានថាធនាគារបានផ្តល់ជូនសេវាកម្មហិរញ្ញវត្ថុយ៉ាងសម្បូរបែប និងរក្សាបានតំណែងក្នុងការប្រកួតប្រជែង និងសមស្របតាមបរិបទនៃការកើនឡើងនូវប្រព័ន្ធឌីជីថល បច្ចេកវិទ្យា និងសេវាធនាគារតាមរយៈទូរស័ព្ទដៃ។ បច្ចុប្បន្ននេះ ធនាគារកំពុងធ្វើប្រតិបត្តិការ តាមរយៈសាខាទាំង៥របស់ខ្លួនរួមមាន ទីស្នាក់ការកណ្តាល សាខាផ្សារអូ-ឡាំពិក សាខាទួលគោក សាខាពេទ្យលោកសង្ឃ និងសាខាម៉ៅសេទុង ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ។

ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក មានទីតាំងស្ថិតនៅ អាគារលេខ ៣៤៥-៣៤៩ មហាវិថីព្រះសីហនុ (ផ្លូវ២៧៤) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

រូបភាព២.២.១ ទីតាំងភូមិសាស្ត្ររបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក




### ២.២.២. អត្តសញ្ញាណ និងរូបសញ្ញា

ធនាគារ ហុង លីអុង មានរូបសញ្ញាឆ្នូតបីពណ៌ខៀវចាស់ និងក្រហមដែលប្រៀបដូចជារបត់មួយមានទិសផ្ទុយគ្នា និងមានអក្សរពណ៌ខៀវចាស់នៅខាងស្តាំនៃរូបសញ្ញា ជាភាសាអង់គ្លេសដាក់ថា "**HongLeong Bank**" ដែលមានន័យជាភាសាខ្មែរថា "**ធនាគារ ហុង លីអុង**"។

ធនាគារ ហុង លីអុង មានរូបសញ្ញាដូចខាងក្រោមៈ

រូបភាព២.២.២ រូបសញ្ញារបស់ធនាគារ ហុង លីអុង

## ២.៣. ចក្ខុវិស័យ បេសកកម្ម និងយុទ្ធសាស្ត្រជាអាទិភាព

### ២.៣.១. ចក្ខុវិស័យ

ចក្ខុវិស័យរបស់ធនាគារ គឺក្លាយទៅជាស្ថាប័នផ្តល់សេវាកម្មហិរញ្ញវត្ថុដែលពេញនិយមបំផុត ប្រកបដោយការច្នៃប្រឌិត និងឌីជីថល នៅក្នុងចំណោមធនាគារឈានមុខគេនៅកម្ពុជា។

### ២.៣.២. បេសកកម្ម

បេសកកម្មរបស់ធនាគារ គឺផ្តល់អោយអតិថិជននូវបទពិសោធន៍សេវាកម្មធនាគារ ប្រកបដោយការច្នៃប្រឌិតរួមជាមួយនឹងបូរណភាព និងវិជ្ជាជីវៈខ្ពស់បំផុត ស្របតាមការពេញចិត្តខុសៗគ្នារបស់បុគ្គលនីមួយៗ។

### ២.៣.៣. យុទ្ធសាស្ត្រជាអាទិភាព

ធនាគារ មានយុទ្ធសាស្ត្រជាអាទិភាពដូចខាងក្រោមៈ

- ធនាគារ ផ្តោតសំខាន់ទៅលើការជំរុញកំណើនទ្រព្យសកម្ម និងអតិថិជនអាជីវកម្ម សហគ្រាសខ្នាតតូច និងមធ្យម ព្រមទាំងអតិថិជនបុគ្គលតាមរយៈអ៊ីនធើណិត ដោយទទួលបានអតិថិជនស្នូលតាមផ្នែកនីមួយៗ ស្របពេលដែលធនាគារបង្កើនការលក់ ដើម្បីទទួលបានចំណូលខ្ពស់។ ធនាគារនឹងបង្កើតផលិតផល និងសេវាកម្ម ដែលមានការច្នៃប្រឌិត ទាក់ទាញ ហើយមានភាពងាយស្រួលក្នុងការប្រើប្រាស់។
- ធនាគារ ព្យាយាមបង្កើន និងពង្រឹងនូវធនធានមនុស្សអោយបានរឹងមាំ ដោយជ្រើសរើសបុគ្គលិកដែលមានសមត្ថភាពក្នុងការធ្វើការ និងរក្សាទុកបុគ្គលិកឆ្នើម។ ធនាគារ ផ្តោតលើគំនិតច្នៃប្រឌិតបែបឌីជីថល និងទេពកោសល្យខ្ពស់។
- ធនាគារ ក៏បានផ្តោតសំខាន់ លើការផ្តល់ជូនអតិថិជននូវបទពិសោធន៍សេវាធនាគារបែបឌីជីថល និងពង្រឹងទីតាំងសាខារបស់ខ្លួន ព្រមទាំងសហការជាមួយអ្នកផ្តល់សេវាផ្សេង

ទៀតអោយបានកាន់តែច្រើន ក្នុងការបង្កើនទំនាក់ទំនង និងការរីកចំរើនរបស់ធនាគារ។

- ធនាគារ បានចូលរួមពង្រឹងផលិតភាពក្នុងការវិនិយោគលើកម្មវិធី ដោយបង្កើតការងារនៅក្នុងការិយាល័យ ដើម្បីអោយប្រតិបត្តិការនានាក្នុងធនាគារមានភាពរលូន តាមរយៈការងារដែលមានលក្ខណៈស្វ័យប្រវត្តិ និងការសហការគ្នា។
- ការអភិវឌ្ឍផ្នែកឌីជីថលតាមរយៈបច្ចេកវិទ្យាដ៏ទំនើប ដើម្បីផ្តល់ជូនសេវាកម្មធនាគារប្រកបទៅដោយភាពសម្បូរបែបដល់អតិថិជន។

## ២.៤. ផែនការ គោលដៅ និងយុទ្ធសាស្ត្រចម្បងរបស់ធនាគារសម្រាប់ឆ្នាំ២០១៨

### ២.៤.១. ផែនការ និងគោលដៅ

សេវាធនាគារសម្រាប់អតិថិជនបុគ្គល បានបន្តតួនាទីយ៉ាងសំខាន់នៅក្នុងការគាំទ្រធនាគារ ដើម្បីផ្តល់ជូនប្រជាជនកម្ពុជានូវភាពងាយស្រួល និងទទួលបានសេវារបស់ធនាគារប្រកបដោយភាពជឿនលឿន ស្របតាមតម្រូវការដែលពេញនិយម និងតាមរយៈប្រព័ន្ធឌីជីថល។ នៅក្នុងឆ្នាំ ២០១៨ ធនាគារបានផ្តល់ជូនអតិថិជននូវសេវាកម្មសំខាន់ៗដូចខាងក្រោម៖

- ដាក់អោយដំណើរការសេវាកម្មហិរញ្ញវត្ថុបុគ្គល ប្រកបដោយការច្នៃប្រឌិត
- ពង្រឹង និងពង្រីកសេវាធនាគារអាទិភាព រួមជាមួយនឹងសេវាកម្មដទៃទៀត
- បន្តវិនិយោគ និងបង្កើតសេវាធនាគារបែបអេឡិចត្រូនិច ដែលមានភាពងាយស្រួលក្នុងការប្រើប្រាស់ និងស្របទៅតាមតម្រូវការអតិថិជនដូចជា ការដាក់អោយដំណើរការនូវប្រព័ន្ធសេវាធនាគារចល័ត ស្របជាមួយនឹងយុទ្ធសាស្ត្រជាអាទិភាពរបស់ធនាគារ ដើម្បីក្លាយខ្លួនជាស្នូលនៃសេវាធនាគារបែបឌីជីថល
- ធនាគារបានបន្តប្តេជ្ញាអភិវឌ្ឍ និងហ្វឹកហ្វឺនបុគ្គលិករបស់ខ្លួន អោយទទួលបាននូវជំនាញ និងសមត្ថភាពសមស្រប ហើយត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ ដើម្បីសម្រេចអោយបាននូវកំណើនអាជីវកម្មរបស់ធនាគារ។

### ២.៤.២. យុទ្ធសាស្ត្រចម្បង

ធនាគារនានាសុទ្ធតែបានរៀបចំ និងបង្កើតនូវយុទ្ធសាស្ត្រចម្បងៗ ដើម្បីអភិវឌ្ឍដំណើរការអាជីវកម្មរបស់ខ្លួន។ យ៉ាងណាមិញ ធនាគារ ហុង លីអុង ក៏បានបង្កើតនូវយុទ្ធសាស្ត្រចម្បងរបស់ខ្លួនដូចខាងក្រោម៖

- បង្កើនការផ្តល់កម្ចី និងប្រមូលបន្ថែមនូវប្រាក់បញ្ញើ ព្រមទាំងអតិថិជនថ្មី សម្រាប់ធនាគារ

ដោយប្រើប្រាស់អោយអស់លទ្ធភាពបំផុតនូវអ្នកជំនាញក្នុងស្រុក រួមជាមួយនឹងទំនាក់-ទំនងក្នុងតំបន់ ដើម្បីចាប់យកនូវកាលានុវត្តភាព និងស្វែងរកនូវដំណោះស្រាយណាដែលមានភាពសមស្របសម្រាប់អតិថិជន

- ជំរុញ និងបង្កើនទំហំនៃការលក់អោយកាន់តែកើនឡើង តាមរយៈការបង្កើតផលិតផល និងសេវាកម្មដែលល្អប្រសើរ
- កសាងក្រុមការងារ និងសេវាធនាគារ សម្រាប់អតិថិជនអាជីវកម្ម ដែលមានសមត្ថ-ភាពខ្ពស់ ប្រកបដោយទេពកោសល្យ និងជំនាញលើផ្នែកឧស្សាហកម្ម តាមរយៈការជ្រើសរើសបុគ្គលិកថ្មី និងការកែសម្រួលនីតិវិធីផ្ទៃក្នុង។

## ២.៥. ធនធានមនុស្ស

ធនាគារ បានចាប់ផ្តើមបើកដំណើរការប្រតិបត្តិការរបស់ខ្លួនជាផ្លូវការ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣ ដោយមានបុគ្គលិកសរុបចំនួន៣៥នាក់ ក៏ប៉ុន្តែចំនួនបុគ្គលិកសរុបរបស់ធនាគារ បានកើនឡើងដល់១២៩នាក់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។ បុគ្គលិកទាំងអស់ បានជំរុញដល់សកម្មភាពនានារបស់ធនាគារ ដោយសារធនាគារមានកម្លាំងពលកម្មចំរុះ ដែលជាប្រភពខ្លាំងរបស់ធនាគារ ដោយបានជ្រើសរើសបុគ្គលិកចេញពី២៨វិស័យដែលរួមមាន វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុថែមទៀតផង។

## ២.៦. អតិថិជនគោលដៅ

អតិថិជនគោលដៅរបស់ធនាគាររួមមាន អតិថិជនអាជីវកម្ម និងសាជីវកម្ម ព្រមទាំងអតិថិ-ជនបុគ្គល។ ចំពោះអតិថិជនអាជីវកម្ម និងសាជីវកម្ម ធនាគារបានផ្តោតលើសហគ្រាសធុនតូចមធ្យម ដែលមានប្រតិបត្តិការរឹងមាំ ដោយផ្តល់ជូនអតិថិជននូវសេវាផ្តល់ប្រាក់កម្ចី និងកញ្ចប់សេវានានា ព្រមទាំងអតិថិជនអាជីវកម្ម សាជីវកម្មក្នុងស្រុក និងថ្នាក់តំបន់ ជាមួយនឹងសេវាកម្មដែលសមស្របនឹងតម្រូវការរបស់អតិថិជនដូចជា សេវាប្រាក់បញ្ញើ-សន្សំ ឥណទាន និងសេវាទីផ្សារហិរញ្ញវត្ថុអន្តរជាតិ។ ដោយឡែក សម្រាប់អតិថិជនគោលដៅរបស់ផ្នែកសេវាធនាគារបុគ្គលវិញរួមមាន អ្នកមានស្តុកស្តម្ភ អ្នកមាន អ្នកមានជីវភាពសមរម្យ និងអ្នកធ្វើការដែលមានចំណេះដឹងផ្នែកបច្ចេកវិទ្យា ដែលអតិថិជនប្រភេទនេះ កំពុងមានចំនួនកើនឡើងនៅក្នុងចំណោមប្រជាជនដែលរស់នៅទីក្រុង។ ហើយអ្នកទាំងនោះ ជាអ្នកដែលបានរួមចំណែកយ៉ាងសំខាន់ នៅក្នុងការកើនឡើងនៃបរិមាណប្រើប្រាស់សេវារបស់ធនាគារ ហុង លីអុង នៅប្រទេសកម្ពុជា។

## ២.៧. ដើមទុន និងភាគទុនិក

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ធនាគារមានដើមទុនចុះបញ្ជីសរុបចំនួន ៥៦,២៥០,០០០ ភាគហ៊ុន ដែលមានតម្លៃចារិក ១ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន។ ភាគហ៊ុនទាំងអស់ ត្រូវបាន បង់រួចទាំងស្រុងដោយធនាគារ ហុង លីអុង បើហាដ ដែលជាធនាគារមេ និងមានការិយាល័យ កណ្តាល នៅប្រទេសម៉ាឡេស៊ី។ នៅកំឡុងឆ្នាំនេះដែរ ធនាគារ ហុង លីអុង បើហាដ បានបន្ថែម ដើមទុនចំនួន ១៨,៧៥០,០០០ ដុល្លារអាមេរិក ដោយក្នុងនោះដែរទឹកប្រាក់ចំនួន ១០លាន ដុល្លារអាមេរិក ត្រូវបានផ្ទេរមកពីអនុបំណុល (នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤ ធនាគារបាន ទទួលអនុបំណុលពីធនាគារមេ ហើយអនុបំណុលនេះនឹងផុតកំណត់ក្នុងរយៈពេល១០ឆ្នាំ និងត្រូវ សងវិញនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ក្នុងអត្រាការប្រាក់ ៤.៥៦% ក្នុងមួយឆ្នាំ) និងទឹកប្រាក់ ចំនួន ៨,៧៥០,០០០ ដុល្លារអាមេរិក ទៀត ត្រូវបានបន្ថែមដោយភាគទុនិកដែលជាសហគ្រិន នៅ ក្នុងប្រទេសម៉ាឡេស៊ី។

តារាង២.៧ ដើមទុនរបស់ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| បរិយាយ | ២០១៧ | | ២០១៦ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាដើមឆ្នាំ | ៣៧,៥០០,០០០ | ១៥១,៣៨៧,៥០០ | ៣៧,៥០០,០០០ | ១៥១,៣៨៧,៥០០ |
| ការបន្ថែមដើមទុនក្នុងឆ្នាំ* | ១៨,៧៥០,០០០ | ៧៥,៦៩៣,៧៥០ | - | - |
| នាដំណាច់ឆ្នាំ | ៥៦,២៥០,០០០ | ២២៧,០៨១,២៥០ | ៣៧,៥០០,០០០ | ១៥១,៣៨៧,៥០០ |

(ប្រភពៈ របាយការណ៍ប្រចាំឆ្នាំ២០១៧របស់ធនាគារ ហុង លីអុង) (ឧបសម្ព័ន្ធទី១)

## ២.៨. ផលិតផល និងសេវាកម្ម

ធនាគារ បានផ្តល់ការគាំទ្រក្នុងការធ្វើអាជីវកម្ម និងតម្រូវការផ្នែកហិរញ្ញវត្ថុរបស់អតិថិជន គ្រប់រូប។ ហេតុដូចនេះ ធនាគារបានផ្តល់ជូនផលិតផល និងសេវាកម្មហិរញ្ញវត្ថុជាច្រើនប្រភេទ ដើម្បីបំពេញតម្រូវការរបស់អតិថិជនដែលជា ក្រុមហ៊ុនអាជីវកម្មធុនតូច មធ្យម សហគ្រាស ពាណិជ្ជកម្ម សាជីវកម្ម និងអតិថិជនបុគ្គលផងដែរ។

ផលិតផល និងសេវាកម្ម របស់ធនាគាររួមមានៈ

- សេវាប្រាក់បញ្ញើ-សន្សំៈ ធនាគារ បានផ្តល់ភាពងាយស្រួលទៅកាន់អតិថិជន ដែលចង់ បង្កើនសាច់ប្រាក់របស់ខ្លួន ដោយធ្វើការវិនិយោគជាមួយធនាគារ ដើម្បីទទួលបានការ ប្រាក់បន្ថែមពីលើប្រាក់បញ្ញើរបស់ខ្លួន។ យ៉ាងណាមិញ គណនីប្រាក់បញ្ញើ-សន្សំ របស់

ធនាគារ មានដូចជា៖

- គណនីប្រាក់សន្សំ៖ ធនាគារ បានបង្កើតប្រភេទគណនីនេះឡើង ដើម្បីបំពេញតម្រូវ-ការអតិថិជន ដែលមានបំណងសន្សំប្រាក់របស់ខ្លួន ដោយទទួលបានការប្រាក់ និងអត្ថប្រយោជន៍ជាច្រើនទៀត។
- គណនីចរន្ត៖ គណនីប្រភេទនេះ បានបង្កើតឡើងសម្រាប់អតិថិជនដែលមានតម្រូវ-ការធ្វើប្រតិបត្តិការជាប្រចាំជាមួយធនាគារ តាមរយៈមូលប្បទានបត្រ ប៉ុន្តែអតិថិជនមិនទទួលបានការប្រាក់ឡើយ។
- គណនីប្រាក់បញ្ញើមានកាលកំណត់៖ គណនីនេះ ត្រូវបានបង្កើតឡើង សម្រាប់អតិថិ-ជនដែលចង់ទទួលបានអត្រាការប្រាក់ខ្ពស់ ក្នុងរយៈពេលជាក់លាក់ណាមួយ។ អត្រាការប្រាក់នឹងត្រូវបានផ្តល់ជូនខុសៗគ្នា ទៅតាមរយៈពេលនៃការផ្ញើប្រាក់គឺអាច ១ខែ ៣ខែ ៦ខែ ៩ខែ ១២ខែ ១៨ខែ និង២៤ខែ។
- គណនីប្រាក់សន្សំសម្រាប់កុមារ៖ គណនីនេះ ត្រូវបានបង្កើតឡើង ដើម្បីលើកទឹកចិត្តកុមារអោយមានទម្លាប់ក្នុងការសន្សំប្រាក់ ហើយពួកគេនឹងអាចប្រើប្រាស់ប្រាក់ទាំងនោះបាន នៅពេលដល់កាលកំណត់ជាក់លាក់មួយ។
- គណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិត៖ គណនីប្រភេទនេះ បានផ្តល់នូវភាពងាយស្រួលដល់អតិថិជន តាមរយៈការធ្វើប្រតិបត្តិការនានា តាមប្រព័ន្ធអ៊ីនធើណិតបានគ្រប់ពេលវេលា និងទីកន្លែង។
- គណនីសេវាអាទិភាព៖ ការប្រើប្រាស់គណនីប្រភេទនេះ អតិថិជននឹងទទួលបានភាពងាយស្រួលក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ជាមួយនឹងការបញ្ចុះតម្លៃផ្សេងៗ។
- គណនីចរន្តអាជីវកម្ម៖ ធនាគារ បានបង្កើតគណនីប្រភេទនេះ ដើម្បីជួយសម្រួលដល់ក្រុមហ៊ុននានា ដែលមានបំណងធ្វើប្រតិបត្តិការជាលក្ខណៈទ្រង់ទ្រាយធំ និងជាប្រចាំ។
- គណនីអាជីវកម្មទទួលបានការប្រាក់៖ គណនីប្រភេទនេះ ត្រូវបានបង្កើតឡើងសម្រាប់តែក្រុមហ៊ុនអាជីវកម្មតែប៉ុណ្ណោះ ដែលមានបំណងសន្សំប្រាក់ និងទទួលបានការប្រាក់ពីលើប្រាក់បញ្ញើរបស់ខ្លួន។
- គណនីអាជីវកម្មរូបិយប័ណ្ណបរទេស៖ គណនីប្រភេទនេះ បានផ្តល់អត្ថប្រយោជន៍ជា

ច្រើន និងភាពងាយស្រួលដល់ បុគ្គល និងក្រុមហ៊ុន ពីការទូទាត់ផ្សេងៗទៅកាន់អ្នកផ្គត់ផ្គង់ក្នុងរូបិយប័ណ្ណរបស់ប្រទេសនីមួយៗ។

- សេវាឥណទាន៖ ធនាគារ បានផ្តល់សេវាឥណទានជាច្រើនប្រភេទ ស្របតាមតម្រូវការអតិថិជនទាំងបុគ្គល ក្រុមហ៊ុន និងសហគ្រាស។ សេវាឥណទានរបស់ធនាគាររួមមាន៖
  - ➢ ឥណទានអាជីវកម្ម៖ ធនាគារ មានឯកទេសក្នុងការផ្តល់កម្ចីជូនដល់ក្រុមហ៊ុនអាជីវកម្ម សាជីវកម្ម សហគ្រាសធុនតូច និងមធ្យម ក្នុងការពង្រីកអាជីវកម្មរបស់ខ្លួន និងការបង្វិលដើមទុន។
  - ➢ ឥណទានមានកាលកំណត់៖ ធនាគារ បានផ្តល់ឥណទានមួយប្រភេទ ដែលមានកាលកំណត់ជាក់លាក់មួយ ដោយតម្រូវអោយអតិថិជន ធ្វើការទូទាត់សងជាប្រចាំខែតែប៉ុណ្ណោះ។ ចំពោះកម្ចីប្រភេទនេះដែរ ត្រូវបានផ្តល់សម្រាប់ប្រើប្រាស់ក្នុងការទិញអចលនទ្រព្យ និងអគារ សម្រាប់ប្រតិបត្តិការអាជីវកម្ម។
  - ➢ ឥណទានវិបារូបន៍៖ ជាទម្រង់នៃការផ្តល់ឥណទាន ដោយមិនមានកាលបរិច្ឆេទសងត្រលប់វិញនោះទេ។ គោលបំណងសំខាន់នៃការផ្តល់ឥណទានប្រភេទនេះ គឺដើម្បីបំពេញតម្រូវការមូលធននៃអាជីវកម្មរបស់អតិថិជន។
  - ➢ ឥណទានរថយន្ត៖ ជាឥណទានមួយប្រភេទ ដែលធនាគារផ្តល់ជូនចំពោះតែឯកត្តជនប៉ុណ្ណោះ ដែលមានបំណងទិញរថយន្ត សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬក្នុងក្រុមគ្រួសារ។
  - ➢ ឥណទានទិញផ្ទះ៖ ជាឥណទានមួយប្រភេទ ដែលធនាគារបង្កើតឡើង សម្រាប់ផ្តល់ជូនអតិថិជន ដើម្បីមានលទ្ធភាពទិញផ្ទះដែលសាងសង់រួច ឬសាងសង់គេហដ្ឋានថ្មីនៅលើដីកម្មសិទ្ធិដែលមានស្រាប់។
  - ➢ ឥណទានទិញផ្ទះសម្រាប់វិនិយោគ៖ ជាឥណទានមួយប្រភេទ ដែលធនាគារជួយដល់អតិថិជន ក្នុងការទិញផ្ទះសម្រាប់វិនិយោគបង្កើនទ្រព្យ។
  - ➢ ឥណទានកែលម្អជីវភាព៖ ធនាគារ ផ្តល់ជូនអតិថិជននូវឥណទានប្រភេទនេះ ដើម្បីយកទៅប្រើប្រាស់ក្នុងការកែលម្អផ្ទះ ការសិក្សា សុខភាព និងកែលម្អជីវភាព អោយកាន់តែមានភាពប្រសើរឡើង។
  - ➢ ឥណទានអចលនវត្ថុពាណិជ្ជកម្ម៖ ជាឥណទានសម្រាប់អតិថិជន ដែលមានតម្រូវការ

ទិញអចលនទ្រព្យ ឬក្នុងគោលបំណងទូទាត់សងឥណទានពីស្ថាប័នហិរញ្ញវត្ថុដទៃ។

- សេវាផ្ទេរប្រាក់៖ ធនាគារ ផ្តល់ជូននូវសេវាផ្ទេរប្រាក់ទាំងក្នុង និងក្រៅប្រទេស ដែលប្រកបដោយសុវត្ថិភាព រហ័ស និងងាយស្រួលជូនអតិថិជន។ ជាពិសេស គឺការផ្ទេរប្រាក់ពីប្រទេសកម្ពុជា ទៅកាន់ប្រទេសដែលជាដៃគូសហការដូចជា ប្រទេសហុងកុង សិង្ហបុរី ចិន វៀតណាម ម៉ាឡេស៊ី និងបណ្តាប្រទេសជាច្រើនទៀតលើពិភពលោកក្នុងរូបិយប័ណ្ណរបស់ប្រទេសនីមួយៗ។
- សេវាហិរញ្ញប្បទានពាណិជ្ជកម្ម៖ ធនាគារ មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការអតិថិជន ដោយភ្ជាប់ទៅកាន់ទីផ្សារពិភពលោក មិនថាជាតម្រូវការហិរញ្ញប្បទានពាណិជ្ជកម្ម ឬតម្រូវការពង្រីកអាជីវកម្ម ដែលមានដូចជា សេវាលិខិតឥណទាននាំចេញ និងនាំចូល ជាដើម។
- ទីផ្សារហិរញ្ញវត្ថុអន្តរជាតិ៖ សេវាកម្មប្រភេទនេះ ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបនឹងតម្រូវការសាជីវកម្ម ស្ថាប័ន វិនិយោគិនទាំងក្នុង និងអន្តរជាតិ ស្ថាប័នហិរញ្ញវត្ថុ និងសមាជិកទីផ្សារដទៃទៀត ដោយផ្តល់ភាពងាយស្រួលក្នុងប្រតិបត្តិការទីផ្សារហិរញ្ញវត្ថុអន្តរជាតិ នៅប្រទេសហុងកុង ទីក្រុងកូឡាឡាំពួរ សិង្ហបុរី និងវៀតណាម។

## ២.៩. រចនាសម្ព័ន្ធនៃការគ្រប់គ្រង

រូបភាព២.៩ រចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក



# ជំពូកទី ៣
# ប្រតិបត្តិការសេវាប្រាក់បញ្ញើ-សន្សំរបស់ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី សាខាផ្សារអូឡាំពិក

## ៣.១. ប្រភេទគណនីប្រាក់បញ្ញើ-សន្សំ

### ៣.១.១. គណនីប្រាក់សន្សំ (Savings Account)

គណនីប្រាក់សន្សំរបស់ធនាគារ ហុង លីអុង គឺជាប្រភេទគណនីមួយក្នុងចំណោមគណនីទាំង៩របស់សេវាប្រាក់បញ្ញើ-សន្សំ។ គណនីប្រាក់សន្សំនេះ បានរចនាឡើងសម្រាប់អតិថិជនដែលមានតម្រូវការសន្សំប្រាក់ ដោយមិនមានការកំណត់ពេលវេលា។

#### ៣.១.១.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍

គណនីប្រាក់សន្សំ របស់ធនាគារ ហុង លីអុង មានលក្ខណៈសម្គាល់ និងផ្តល់អត្ថប្រយោជន៍ដល់អតិថិជនដូចជា៖

- អតិថិជនអាចបើកគណនីជាប្រាក់រៀលខ្មែរ ឬប្រាក់ដុល្លារអាមេរិក
- អតិថិជនអាចដកប្រាក់ដោយឥតគិតថ្លៃសេវា
- ធនាគារនឹងផ្តល់ជូនសៀវភៅគណនីប្រាក់សន្សំភ្លាមៗទៅអោយអតិថិជន
- ការប្រាក់ត្រូវបានគណនាប្រចាំថ្ងៃ
- អាចធ្វើប្រតិបត្តិការគណនីតាមរយៈ បញ្ជរបេឡា និងសេវា(Connect)
- មិនកំណត់ចំនួនដងនៃការធ្វើប្រតិបត្តិការគណនី។

#### ៣.១.១.២. លក្ខខណ្ឌ និងការកំណត់

អតិថិជនត្រូវគោរពតាមលក្ខខណ្ឌ និងការកំណត់ដូចខាងក្រោម៖

- អតិថិជនត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ
- ទឹកប្រាក់អប្បបរមាក្នុងការបើកគណនីលើកដំបូងចាប់ពី ១០០ ដុល្លារអាមេរិក
- ទឹកប្រាក់អប្បបរមាគិតជាមធ្យមប្រចាំខែរក្សាក្នុងគណនីត្រឹម ១០ ដុល្លារអាមេរិក
- គណនីនេះអាចបើកបានជាលក្ខណៈបុគ្គល ឬគណនីរួមបាន។

**ចំណាំ៖**

- សម្រាប់សៀវភៅគណនីសន្សំពេលប្រើអស់ ធនាគារនឹងចេញថ្មីជូនអតិថិជន។ ក្នុងករណី ដែលអតិថិជនធ្វើបាត់ ហើយចង់ស្នើសុំថ្មី អតិថិជនត្រូវបង់ ៤ ដុល្លារ សម្រាប់សៀវភៅមួយក្បាល។

▪ ការប្រើប្រាស់សេវា(Connect) អតិថិជនត្រូវដាក់ពាក្យស្នើសុំការប្រើប្រាស់។ (ឧបសម្ព័ន្ធទី២)

#### ៣.១.១.៣. អត្រាការប្រាក់

តារាង៣.១.១.៣ អត្រាការប្រាក់របស់គណនីប្រាក់សន្សំ

| សមតុល្យ (ដុល្លារ/សមតុល្យមានតម្លៃស្មើ) | អត្រាការប្រាក់(ប្រាក់រៀល) | អត្រាការប្រាក់(ប្រាក់ដុល្លារ) |
|---|---|---|
| ១០០ ដុល្លារ - ៥០០ ដុល្លារ | ០.៧៥% | ០.២៥% |
| > ៥០០ ដុល្លារ - ៥,០០០ ដុល្លារ | ១.០០% | ០.៥០% |
| >៥,០០០ ដុល្លារ | ១.២៥% | ០.៧៥% |

(ប្រភព៖ តារាងអត្រាការប្រាក់ និងខិតប័ណ្ណផ្សព្វផ្សាយពីគណនីប្រាក់សន្សំរបស់ធនាគារ ហុង លីអុង) (ឧបសម្ព័ន្ធទី៣)

### ៣.១.២. គណនីចរន្ត (Current Account)

គណនីចរន្តរបស់ធនាគារ ហុង លីអុង ត្រូវបានបង្កើតឡើងសម្រាប់អតិថិជនដែលមានតម្រូវការធ្វើប្រតិបត្តិការជាប្រចាំជាមួយនឹងធនាគារដែលរួមមាន សេវាដាក់ប្រាក់ ដកប្រាក់ និងទូទាត់សាច់ប្រាក់ តាមរយៈមូលប្បទានបត្រ។

#### ៣.១.២.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍

គណនីចរន្តរបស់ធនាគារ ហុង លីអុង មានលក្ខណៈសម្គាល់ និងផ្តល់អត្ថប្រយោជន៍ដល់អតិថិជនដូចជា៖

- អតិថិជនអាចបើកគណនីជាប្រាក់រៀលខ្មែរ ឬប្រាក់ដុល្លារអាមេរិក
- អតិថិជននឹងទទួលបានកាត( ATM) ភ្លាមៗ
- អតិថិជននឹងទទួលបានរបាយការណ៍ប្រតិបត្តិការប្រចាំខែ ដោយឥតគិតថ្លៃ
- អតិថិជនអាចធ្វើប្រតិបត្តិការគណនីតាមរយៈ មូលប្បទានបត្រ បញ្ជរបេឡា សេវា (Connect) និងម៉ាស៊ីនដកប្រាក់(ATM)
- មិនកំណត់ចំនួនដងនៃការធ្វើប្រតិបត្តិការគណនី។

#### ៣.១.២.២. លក្ខខណ្ឌ និងការកំណត់

អតិថិជនត្រូវគោរពតាមលក្ខខណ្ឌ និងការកំណត់មួយចំនួនដូចខាងក្រោម៖

- អតិថិជនត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ
- ទឹកប្រាក់អប្បបរមាក្នុងការបើកគណនីលើកដំបូងចាប់ពី ១០០ ដុល្លារអាមេរិក
- ទឹកប្រាក់អប្បបរមាគិតជាមធ្យមប្រចាំខែរក្សាក្នុងគណនីត្រឹម ១០ ដុល្លារអាមេរិក

- គណនីនេះអាចបើកបានជាលក្ខណៈបុគ្គល ឬគណនីរួមបាន។

**ចំណាំ៖**

- ប្រសិនបើទឹកប្រាក់អប្បបរមាក្នុងការបើកគណនីលើកដំបូងតិចជាង ៥០ ដុល្លារ នោះធនាគារនឹងពិន័យជាទឹកប្រាក់ចំនួន ១ ដុល្លារ។
- សៀវភៅមូលប្បទានបត្រមានតម្លៃ ៥ ដុល្លារ ក្នុងមួយក្បាល។
- ការស្នើសុំរបាយការណ៍ប្រតិបត្តិការប្រចាំខែជាលើកទី២ក្នុងមួយខែ អតិថិជនត្រូវបង់ ២ ដុល្លារ។

**៣.១.២.៣. អត្រាការប្រាក់**

សម្រាប់ការប្រើប្រាស់គណនីមួយនេះ អតិថិជនមិនទទួលបានការប្រាក់ទេ។

(ប្រភព៖ តារាងអត្រាការប្រាក់ និងខិតប័ណ្ណផ្សព្វផ្សាយពីគណនីចរន្តរបស់ធនាគារ ហុង លីអុង)

(ឧបសម្ព័ន្ធទី៨)

**៣.១.៣. គណនីប្រាក់បញ្ញើមានកាលកំណត់** ( Fixed Deposit Account )

គណនីប្រាក់បញ្ញើមានកាលកំណត់របស់ធនាគារ ហុង លីអុង ត្រូវបានបង្កើតឡើងសម្រាប់អតិថិជនដែលចង់ទទួលបានអត្រាការប្រាក់ខ្ពស់ ក្នុងរយៈពេលជាក់លាក់ណាមួយ។ ធនាគារនឹងធ្វើការផ្តល់ជូននូវអត្រាការប្រាក់ខុសៗគ្នា ទៅតាមរយៈពេលដែលអតិថិជនបានជ្រើសរើស។

រយៈពេលកំណត់នៃការដាក់ប្រាក់របស់ធនាគារ ហុង លីអុង សម្រាប់គណនីប្រភេទនេះមានរយៈពេល ១ខែ ៣ខែ ៦ខែ ៩ខែ ១២ខែ ១៨ខែ និង២៤ខែ។

**៣.១.៣.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍**

គណនីប្រាក់បញ្ញើមានកាលកំណត់របស់ធនាគារ ហុង លីអុង មានលក្ខណៈសម្គាល់ និងបានផ្តល់អត្ថប្រយោជន៍ដល់អតិថិជនមួយចំនួនដូចជា៖

- អតិថិជនអាចបើកគណនីជាប្រាក់រៀលខ្មែរ ឬប្រាក់ដុល្លារអាមេរិក
- ទទួលបានវិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់ភ្លាមៗនៅពេលដាក់ប្រាក់បញ្ញើ
- អតិថិជននឹងទទួលបានអត្រាការប្រាក់ខ្ពស់។

**៣.១.៣.២. លក្ខខណ្ឌ និងការកំណត់**

អតិថិជនត្រូវគោរពតាមលក្ខខណ្ឌ និងការកំណត់មួយចំនួនដូចខាងក្រោម៖

- អតិថិជនត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ
- អាចបើកគណនីជាលក្ខណៈបុគ្គល ឬក្រុមហ៊ុន

- ទឹកប្រាក់អប្បបរមាក្នុងការដាក់ប្រាក់បញ្ញើលើកដំបូងចាប់ពី ១,០០០ ដុល្លារអាមេរិក (សម្រាប់រយៈពេលពី១ខែ រហូតដល់ ១២ខែ)
- ទឹកប្រាក់អប្បបរមាក្នុងការដាក់ប្រាក់បញ្ញើលើកដំបូងចាប់ពី ១០,០០០ ដុល្លារអាមេរិក (សម្រាប់រយៈពេល១៨ខែ និង ២៤ខែ)។

#### ៣.១.៣.៣. អត្រាការប្រាក់

តារាង៣.១.៣.៣ អត្រាការប្រាក់របស់គណនីប្រាក់បញ្ញើមានកាលកំណត់

| ប្រាក់បញ្ញើ | ១ខែ | ៣ខែ | ៦ខែ | ៩ខែ | ១២ខែ | ១៨ខែ | ២៤ខែ |
|---|---|---|---|---|---|---|---|
| ប្រាក់រៀល | ៣.៥០% | ៤.០០% | ៥.០០% | ៥.៥០% | ៦.០០% | អាចពិភាក្សា | អាចពិភាក្សា |
| ប្រាក់ដុល្លារ | ១.៧៥% | ២.៥០% | ៣.៧៥% | ៤.០០% | ៤.៧៥% | អាចពិភាក្សា | អាចពិភាក្សា |

(ប្រភពៈ តារាងអត្រាការប្រាក់ និងខិតប័ណ្ណផ្សព្វផ្សាយពីគណនីប្រាក់បញ្ញើមានកាលកំណត់របស់ធនាគារ ហុង លីអុង) (ឧបសម្ព័ន្ធទី៥)

**ចំណាំៈ**

- ចំពោះការបិទគណនីមុនកាលកំណត់ ធនាគារនឹងផ្តល់ជូនអត្រាការប្រាក់ដូចគណនីប្រាក់សន្សំដែរ ហើយធនាគារមិនធ្វើការពិន័យជាទឹកប្រាក់នោះទេ។

### ៣.១.៤. គណនីប្រាក់សន្សំសម្រាប់កុមារ (Kid's Saving Account)

គណនីប្រាក់សន្សំសម្រាប់កុមាររបស់ធនាគារ ហុង លីអុង គឺត្រូវបានបង្កើតឡើងក្នុងគោលបំណងបង្រៀនដល់កុមារតូចៗអោយយល់អំពីតម្លៃនៃការសន្សំប្រាក់តាំងពីវ័យកុមារ។ លើសពីនេះទៅទៀត ពួកគាត់នឹងទទួលបានអត្រាការប្រាក់ខ្ពស់ និងជម្រើសផ្សេងៗទៀត សម្រាប់ការប្រាក់បន្ថែមជារៀងរាល់ខែដែលផ្តល់ជូនដោយខាងធនាគារ។ គណនីនេះ តម្រូវអោយកុមារបើកគណនីរួមជាមួយឪពុកម្តាយ ឬអាណាព្យាបាល។ កុមារ អាចប្រើប្រាស់ប្រាក់ទាំងនោះបាន នៅពេលមានអាយុគ្រប់១៨ឆ្នាំ។

#### ៣.១.៤.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍

គណនីប្រាក់សន្សំសម្រាប់កុមាររបស់ធនាគារ ហុង លីអុង មានលក្ខណៈសម្គាល់ និងផ្តល់នូវអត្ថប្រយោជន៍ដល់អតិថិជនមួយចំនួនដូចជាៈ

- អាចបើកគណនីជាប្រាក់រៀលខ្មែរ និងប្រាក់ដុល្លារអាមេរិក
- ទទួលបានសៀវភៅគណនីប្រាក់សន្សំនៅពេលបើកគណនី
- អាចធ្វើប្រតិបត្តិការតាមរយៈ បញ្ជរបេឡា និងសេវា(Connect)

- គ្មានថ្លៃសេវាសម្រាប់ការដកប្រាក់ក្នុងមួយខែ តាមរយៈការប្រើប្រាស់សេវា(Connect)
- សម្រាប់ការដកប្រាក់លើកទី២ និងដកតាមបញ្ជរបេឡា អតិថិជនត្រូវបង់ ១ដុល្លារ។

**៣.១.៤.២. លក្ខខណ្ឌ និងការកំណត់**

អតិថិជនត្រូវគោរពតាមលក្ខខណ្ឌ និងការកំណត់មួយចំនួនដូចខាងក្រោមៈ

- គណនីនេះអាចបើកបានសម្រាប់តែអនីតិជន ដែលទទួលបានការអនុញ្ញាតពីឪពុកម្តាយ ឬអាណាព្យាបាល តែប៉ុណ្ណោះ
- ទឹកប្រាក់អប្បបរមាក្នុងការបើកគណនីលើកដំបូងចាប់ពី ២៥០ ដុល្លារអាមេរិក
- ទឹកប្រាក់អប្បបរមាជាមធ្យមប្រចាំខែរក្សាក្នុងគណនីត្រឹម ២៥០ ដុល្លារអាមេរិក។

**ចំណាំៈ**

- ប្រសិនបើទឹកប្រាក់អប្បបរមាក្នុងការបើកគណនីលើកដំបូងតិចជាង ២៥០ ដុល្លារ នោះធនាគារនឹងពិន័យជាទឹកប្រាក់ចំនួន ១ ដុល្លារ។
- ប្រសិនបើទឹកប្រាក់អប្បបរមាជាមធ្យមប្រចាំខែរក្សាក្នុងគណនីតិចជាង ២៥០ ដុល្លារ នោះធនាគារនឹងពិន័យជាទឹកប្រាក់ចំនួន ១ ដុល្លារ។

**៣.១.៤.៣. អត្រាការប្រាក់**

តារាង៣.១.៤.៣ អត្រាការប្រាក់របស់គណនីប្រាក់សន្សំសម្រាប់កុមារ

| | |
|---|---|
| អត្រាការប្រាក់គោល | ១.៦៨% ក្នុងមួយឆ្នាំ |
| បន្ថែម ០.២៥% | សម្រាប់ការដាក់ប្រាក់បន្ថែមប្រចាំខែចាប់ពី ៥០ដុល្លារ |

(ប្រភពៈ តារាងអត្រាការប្រាក់ និងខិតប័ណ្ណផ្សព្វផ្សាយពីគណនីប្រាក់សន្សំសម្រាប់កុមារ របស់ធនាគារ ហុង លីអុង) (ឧបសម្ព័ន្ធទី៦)

**៣.១.៥. គណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិត (E-Saver Account)**

ធនាគារ ហុង លីអុង ផ្តល់ជូនអតិថិជននូវបទពិសោធន៍ហិរញ្ញវត្ថុដ៏ពិសេស ដែលបានអនុញ្ញាតអោយអតិថិជនទាំងអស់ ចាត់ចែងប្រាក់ពីគេហដ្ឋានរបស់ពួកគេបាន និងអាចសន្សំប្រាក់ក្នុងក្តីស្រមៃ។ គណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិតនេះ គឺជាគណនីមួយដែលអាចបើកដោយមិនចាំបាច់បំពេញឯកសារលើក្រដាសនោះទេ។ គណនីនេះនឹងអនុញ្ញាតអោយអតិថិជន ធ្វើការកំណត់ឈ្មោះគណនី តាមគោលបំណងដែលពួកគេចង់បាន។

**៣.១.៥.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍**

គណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិតរបស់ធនាគារ ហុង លីអុង មានលក្ខណៈសម្គាល់

និងផ្តល់អត្ថប្រយោជន៍ដល់អតិថិជនមួយចំនួនដូចជា៖

- អាចបើកគណនីជាប្រាក់រៀលខ្មែរ ឬប្រាក់ដុល្លារអាមេរិក
- អនុញ្ញាតអោយបើកគណនីច្រើនបំផុតចំនួន៥ ដោយមិនបានរាប់បញ្ចូលនូវគណនីប្រាក់សន្សំ និងគណនីចរន្ត ដែលមានស្រាប់
- គ្មានថ្លៃសេវាប្រចាំខែ
- ការបង្កើតគណនីតាមប្រព័ន្ធអ៊ីនធើណិត
- អាចធ្វើប្រតិបត្តិការគណនីតាមរយៈ បញ្ជរបេឡា និងសេវា(Connect)
- មិនកំណត់ចំនួនដងក្នុងការធ្វើប្រតិបត្តិការគណនី
- ការកំណត់ឈ្មោះគណនី (ឧទាហរណ៍៖ គណនីសន្សំសម្រាប់គេហដ្ឋានដំបូង គណនីប្រាក់សន្សំសម្រាប់កូនដំបូង។ល។)។

### ៣.១.៥.២. លក្ខខណ្ឌ និងការកំណត់

ដើម្បីអាចបើកគណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិតបាន អតិថិជនចាំបាច់ត្រូវគោរពតាមលក្ខខណ្ឌ និងការកំណត់មួយចំនួនដូចខាងក្រោម៖

- ទឹកប្រាក់អប្បបរមាក្នុងការបើកគណនីលើកដំបូងចាប់ពី ១០០ ដុល្លារអាមេរិក
- ទឹកប្រាក់អប្បបរមាជាមធ្យមប្រចាំខែរក្សាក្នុងគណនីត្រឹម ១០០ ដុល្លារអាមេរិក។
- គណនីនេះអាចបើកបានជាលក្ខណៈបុគ្គលតែប៉ុណ្ណោះ។

**ចំណាំ៖**

▪ ប្រសិនបើទឹកប្រាក់អប្បបរមាក្នុងការបើកគណនីលើកដំបូងតិចជាង ១០០ ដុល្លារ នោះធនាគារនឹងពិន័យជាទឹកប្រាក់ចំនួន ១ ដុល្លារ។

▪ ប្រសិនបើទឹកប្រាក់អប្បបរមាជាមធ្យមប្រចាំខែរក្សាក្នុងគណនីតិចជាង ១០០ ដុល្លារ នោះធនាគារនឹងពិន័យជាជាទឹកប្រាក់ចំនួន ២ ដុល្លារ។

### ៣.១.៥.៣. វិធីបើកគណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិត

ដើម្បីអាចបើកគណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិតបាន អតិថិជនត្រូវធ្វើតាមវិធីណែនាំដូចខាងក្រោម៖

- អតិថិជនត្រូវចូលទៅកាន់គេហទំព័រ www.hongleongconnect.com.kh រួច Log-In ដោយប្រើឈ្មោះគណនី (Username) និងលេខកូដសម្ងាត់ (Password)

- បន្ទាប់មកត្រូវចូលទៅកាន់ "E-Product"
- ជ្រើសរើសមុខងារ "Create Account" ដែលបិតនៅខាងក្រោម "E-Saver Account"។

#### ៣.១.៥.៤. អត្រាការប្រាក់

តារាង៣.១.៥.៤ អត្រាការប្រាក់របស់គណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិត

| | |
|---|---|
| អត្រាការប្រាក់គោល | ១% ក្នុងមួយឆ្នាំ |
| បន្ថែម ០.២៥% ក្នុងមួយឆ្នាំ | សម្រាប់ការដាក់ប្រាក់បន្ថែមប្រចាំខែចាប់ពី ៥០ដុល្លារ |
| បន្ថែម ០.៥% ក្នុងមួយឆ្នាំ | សម្រាប់ការសន្សំដោយមិនមានការដកប្រាក់សម្រាប់៦ខែចុងក្រោយ |

(ប្រភព៖ តារាងអត្រាការប្រាក់ និងខិតប័ណ្ណផ្សព្វផ្សាយពីគណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិត របស់ធនាគារ ហុង លីអុង) (ឧបសម្ព័ន្ធទី៧)

### ៣.១.៦. គណនីសេវាអាទិភាព ( Priority Banking )

ធនាគារ ហុង លីអុង ផ្តល់ជូនអតិថិជននូវសេវាធនាគារ ដែលមានលំដាប់ខ្ពស់ជាមួយនឹងគណនីសេវាអាទិភាពដែលបង្កើតឡើង ដើម្បីឆ្លើយតបនឹងតម្រូវការជាអាទិភាពក្នុងជីវភាពរស់នៅ និងទទួលបានជោគជ័យក្នុងការប្រើប្រាស់ហិរញ្ញវត្ថុរបស់អតិថិជន ដែលអាចជួយអោយការរស់-នៅរបស់អតិថិជនកាន់តែមានភាពល្អប្រសើរ។ ការប្រើប្រាស់គណនីសេវាអាទិភាព បានផ្តល់ផលប្រយោជន៍ដូចជា ការផ្តល់ជូននូវការបញ្ចុះតម្លៃ ចំពោះការស្នាក់នៅក្នុងសណ្ឋាគារដ៏ល្អប្រណិតបរិភោគអាហារនៅក្នុងភោជនីយដ្ឋានល្បីៗ កន្លែងហាត់ប្រាណ និងវាយកូនហ្គោលជាលក្ខណៈឯកជន និងផ្តល់ជូនអត្ថប្រយោជន៍ជាច្រើនទៀត។

#### ៣.១.៦.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍

គណនីសេវាអាទិភាពរបស់ធនាគារ ហុង លីអុង មានលក្ខណៈសម្គាល់ និងផ្តល់នូវអត្ថ-ប្រយោជន៍ជូនដល់អតិថិជនដូចជា៖

- អាចបើកគណនីជាប្រាក់រៀលខ្មែរ ឬប្រាក់ដុល្លារអាមេរិក
- ទទួលបានកាត(ATM) ពិសេស ភ្លាមៗនៅពេលបើកគណនី
- ផ្តល់ជូនឥណទានវិបារូបរ៍តាមរយៈការព្រមព្រៀង
- ផ្តល់ជូនសៀវភៅមូលប្បទានបត្រមួយក្បាលក្នុងមួយខែ ដោយឥតគិតថ្លៃ
- ទទួលបានរបាយការណ៍ប្រចាំខែដោយឥតគិតថ្លៃ
- អាចធ្វើប្រតិបត្តិការគណនីតាមរយៈ បញ្ជរបេឡា ម៉ាស៊ីនដកប្រាក់(ATM) មូលប្បទាន-បត្រ និងសេវា(Connect)

– មិនកំណត់ចំនួនដងនៃការធ្វើប្រតិបត្តិការគណនី។

**៣.១.៦.២. លក្ខខណ្ឌ និងការកំណត់**

អតិថិជនត្រូវគោរពតាមលក្ខខណ្ឌ និងការកំណត់មួយចំនួនដូចខាងក្រោម៖

– អតិថិជនត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ

– ទឹកប្រាក់អប្បបរមាក្នុងការបើកគណនីលើកដំបូងចាប់ពី ២៥,០០០ ដុល្លារអាមេរិក

– ទឹកប្រាក់អប្បបរមាគិតជាមធ្យមប្រចាំខែរក្សាក្នុងគណនីត្រឹម ២៥,០០០ ដុល្លារអាមេរិក

– គណនីនេះអាចបើកជាលក្ខណៈបុគ្គល ឬរួមបាន។

**ចំណាំ៖**

▪ ប្រសិនបើទឹកប្រាក់អប្បបរមាគិតជាមធ្យមប្រចាំខែក្នុងគណនីតិចជាង ២៥,០០០ ដុល្លារ នោះធនាគារនឹងពិន័យជាទឹកប្រាក់ចំនួន ១៥ ដុល្លារ។

▪ ការស្នើសុំសៀវភៅមូលប្បទានបត្រលើកទី២ក្នុងមួយខែ អតិថិជនត្រូវបង់ ៥ ដុល្លារ សម្រាប់សៀវភៅមួយក្បាល។

**៣.១.៦.៣. អត្រាការប្រាក់**

តារាង៣.១.៦.៣. អត្រាការប្រាក់របស់គណនីសេវាអាទិភាព

| សមតុល្យ(ដុល្លារ/សមតុល្យមានតម្លៃស្មើ) | អត្រាការប្រាក់(ប្រាក់រៀល) | អត្រាការប្រាក់(ប្រាក់ដុល្លារ) |
|---|---|---|
| ៥,០០០ ដុល្លារ - ១៥,០០០ ដុល្លារ | ១.០០% | ០.៥០% |
| >១៥,០០០ ដុល្លារ - ២៥,០០០ ដុល្លារ | ១.២៥% | ០.៧៥% |
| >២៥,០០០ ដុល្លារ - ១០០,០០០ ដុល្លារ | ១.៥០% | ១.០០% |
| >១០០,០០០ ដុល្លារ | ២.០០% | ១.៥០% |

(ប្រភព៖ តារាងអត្រាការប្រាក់ និងខិតប័ណ្ណផ្សព្វផ្សាយពីគណនីសេវាអាទិភាពរបស់ធនាគារ ហុង លីអុង) (ឧបសម្ព័ន្ធទី៨)

**៣.១.៧. គណនីចរន្តអាជីវកម្ម** (Business Current Account)

ធនាគារ ហុង លីអុង ផ្តល់ជូននូវគណនីចរន្តអាជីវកម្មដែលជាជម្រើសដ៏ល្អ សម្រាប់ក្រុម-ហ៊ុន សាជីវកម្ម និងស្ថាប័ន ដែលមានតម្រូវការធ្វើប្រតិបត្តិការទ្រង់ទ្រាយធំ និងជាប្រចាំ។

**៣.១.៧.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍**

គណនីចរន្តអាជីវកម្មរបស់ធនាគារ ហុង លីអុង មានលក្ខណៈសម្គាល់ និងបានផ្តល់នូវអត្ថ-ប្រយោជន៍ដល់អតិថិជនមួយចំនួនដូចជា៖

- អតិថិជនអាចបើកគណនីជាប្រាក់រៀលខ្មែរ ឬប្រាក់ដុល្លារអាមេរិក
- អតិថិជនអាចធ្វើប្រតិបត្តិការគណនីតាមរយៈ មូលប្បទានបត្រ និងបញ្ជរបេឡា
- ផ្តល់ជូនឥណទានវិបារូបរ៍តាមរយៈការព្រមព្រៀង
- មិនកំណត់ចំនួនដងនៃការធ្វើប្រតិបត្តិការគណនី។

**៣.១.៧.២. លក្ខខណ្ឌ និងការកំណត់**

អតិថិជនត្រូវគោរពតាមលក្ខខណ្ឌ និងការកំណត់មួយចំនួនដូចខាងក្រោម៖

- អតិថិជនត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ
- ទឹកប្រាក់អប្បបរមាក្នុងការបើកគណនីលើកដំបូងចាប់ពី ៥០០ ដុល្លារអាមេរិក
- ទឹកប្រាក់អប្បបរមាជាមធ្យមប្រចាំខែរក្សាក្នុងគណនីត្រឹម ៥០ ដុល្លារអាមេរិក
- គណនីនេះបើកជាលក្ខណៈក្រុមហ៊ុន ឬអាជីវកម្ម។

**ចំណាំ៖** ប្រសិនបើទឹកប្រាក់អប្បបរមាក្នុងការបើកគណនីលើកដំបូងតិចជាង ៥០០ដុល្លារ នោះធនាគារនឹងពិន័យជាទឹកប្រាក់ចំនួន ១ដុល្លារ។

**៣.១.៧.៣. អត្រាការប្រាក់**

សម្រាប់ការប្រើប្រាស់គណនីនេះ អតិថិជនមិនទទួលបានការប្រាក់ទេ។

(ប្រភព៖ ខិតប័ណ្ណផ្សព្វផ្សាយពីគណនីចរន្តអាជីវកម្មរបស់ធនាគារ ហុង លីអុង) (ឧបសម្ព័ន្ធទី៩)

**៣.១.៨. គណនីអាជីវកម្មទទួលបានការប្រាក់ (Business Account Bearing Interest)**

ធនាគារ ហុង លីអុង បានបង្កើតគណនីប្រភេទនេះឡើង ដើម្បីជួយអតិថិជនក្នុងការគ្រប់គ្រងលំហូរសាច់ប្រាក់របស់ពួកគេ ដោយទទួលបានអត្រាការប្រាក់ដែលមានលក្ខណៈប្រកួតប្រជែង។

**៣.១.៨.១ លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍**

គណនីអាជីវកម្មទទួលបានការប្រាក់ របស់ធនាគារ ហុង លីអុង មានលក្ខណៈសម្គាល់ និងផ្តល់នូវអត្ថប្រយោជន៍ដូចជា៖

- អាចបើកគណនីជាប្រាក់រៀលខ្មែរ ឬប្រាក់ដុល្លារអាមេរិក
- ទទួលបានរបាយការណ៍ប្រតិបត្តិការប្រចាំខែដោយឥតគិតថ្លៃ
- អាចធ្វើប្រតិបត្តិការគណនីតាមរយៈ មូលប្បទានបត្រ និងបញ្ជរបេឡា
- មិនកំណត់ចំនួនដងនៃការធ្វើប្រតិបត្តិការគណនី

- ធនាគារនឹងចាត់តាំងប្រធានផ្នែកទំនាក់ទំនងដើម្បីជួយគ្រប់គ្រងគណនីរបស់អតិថិជន។

**៣.១.៨.២. លក្ខខណ្ឌ និងការកំណត់**

អតិថិជនត្រូវគោរពតាមលក្ខខណ្ឌ និងការកំណត់មួយចំនួនដូចខាងក្រោម៖

- អតិថិជនត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ
- ទឹកប្រាក់អប្បបរមាក្នុងការបើកគណនីលើកដំបូងចាប់ពី ៥,០០០ ដុល្លារអាមរិក
- ទឹកប្រាក់អប្បបរមាជាមធ្យមប្រចាំខែរក្សាក្នុងគណនីត្រឹម ៥,០០០ ដុល្លារអាមេរិក
- គណនីអាចបើកបានជាលក្ខណៈក្រុមហ៊ុន ឬអាជីវកម្ម តែប៉ុណ្ណោះ។

**ចំណាំ៖**

- ប្រសិនបើទឹកប្រាក់អប្បបរមាក្នុងការបើកគណនីលើកដំបូងតិចជាង ១០,០០០ ដុល្លារ ធនាគារនឹងពិន័យជាទឹកប្រាក់ចំនួន ២ ដុល្លារ។
- ប្រសិនបើទឹកប្រាក់អប្បបរមាមធ្យមប្រចាំខែរក្សាក្នុងគណនីតិចជាង ៥,០០០ ដុល្លារ ធនាគារនឹងពិន័យជាទឹកប្រាក់ចំនួន ៣ ដុល្លារ។

**៣.១.៨.៣. អត្រាការប្រាក់**

តារាង៣.១.៨.៣ អត្រាការប្រាក់របស់គណនីអាជីវកម្មទទួលបានការប្រាក់

| សមតុល្យ(ដុល្លារ/សមតុល្យមានតម្លៃស្មើ) | អត្រាការប្រាក់(ប្រាក់រៀល) | អត្រាការប្រាក់(ប្រាក់ដុល្លារ) |
|---|---|---|
| ៥,០០០ ដុល្លារ - ២៥,០០០ ដុល្លារ | ១.០០% | ០.៥០% |
| >២៥,០០០ ដុល្លារ - ១០០,០០០ ដុល្លារ | ១.២៥% | ០.៧៥% |
| >១០០,០០០ ដុល្លារ | ២.០០% | ១.៥០% |

(ប្រភព៖ តារាងអត្រាការប្រាក់ និងគេហទំព័រផ្លូវការរបស់ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី)
(ឧបសម្ព័ន្ធទី១០)

**៣.១.៩. គណនីអាជីវកម្មរូបិយប័ណ្ណបរទេស** (Business Foreign Currencies Account)

ធនាគារ ហុង លីអុង បានបង្កើតគណនីនេះឡើង ដើម្បីផ្តល់ជូនអតិថិជននូវអត្ថប្រយោជន៍នៃការប្រែប្រួលតម្លៃរូបិយប័ណ្ណនៅក្នុងទីផ្សារហិរញ្ញវត្ថុ ដោយការដាក់សន្សំជាមុននូវរូបិយប័ណ្ណបរទេស សម្រាប់ទូទាត់ទៅអោយអ្នកផ្គត់ផ្គង់តាមបណ្តាប្រទេស ដែលជាដៃគូសហការ នាពេលអនាគត។

**៣.១.៩.១. លក្ខណៈសម្គាល់ និងអត្ថប្រយោជន៍**

គណនីអាជីវកម្មរូបិយប័ណ្ណបរទេស របស់ធនាគារ ហុង លីអុង មានលក្ខណៈសម្គាល់ និង

អត្ថប្រយោជន៍ដូចជា៖

- បើកគណនីក្នុងរូបិយប័ណ្ណដូចជា៖ ដុល្លារអូស្ត្រាលី ដុល្លារញូសេឡែន ដុល្លារហុងកុង ដុល្លារសិង្ហបុរី អឺរ៉ូ យ៉េន ផោន បាត
- ផ្តល់ជូនរបាយការណ៍ប្រតិបត្តិការប្រចាំខែ ដោយឥតគិតថ្លៃ
- អាចធ្វើប្រតិបត្តិការតាមរយៈ បញ្ជរបេឡា
- មិនកំណត់ចំនួនដងនៃការធ្វើប្រតិបត្តិការគណនី
- លុបបំបាត់ហានិភ័យក្នុងការផ្លាស់ប្តូររូបិយប័ណ្ណ
- មានភាពងាយស្រួលសម្រាប់ការវិនិយោគក្នុងរូបិយប័ណ្ណផ្សេងៗ។

**៣.១.៩.២. លក្ខខណ្ឌ និងការកំណត់**

អតិថិជនត្រូវគោរពតាមលក្ខខណ្ឌ និងការកំណត់មួយចំនួនដូចខាងក្រោម៖

- អតិថិជនត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ
- អាចបើកគណនីជាលក្ខណៈបុគ្គល ឬក្រុមហ៊ុន

តារាង៣.១.៩.២ សមតុល្យក្នុងគណនីអាជីវកម្មរូបិយប័ណ្ណបរទេស

| រូបិយប័ណ្ណ | ទឹកប្រាក់អប្បបរមា ក្នុងការបើកគណនីលើកដំបូង | ទឹកប្រាក់អប្បបរមា ជាមធ្យមប្រចាំខែរក្សាក្នុងគណនី |
|---|---|---|
| ដុល្លារអូស្ត្រាលី | ១០០ AUD | ៥០ AUD |
| ដុល្លារញូសេឡែន | ១០០ NZD | ៦០ NZD |
| ដុល្លារហុងកុង | ៨០០ HKD | ៥០០ HKD |
| ដុល្លារសិង្ហបុរី | ១០០ SGD | ៥០ SGD |
| អឺរ៉ូ | ១០០ EUR | ៥០ EUR |
| យ៉េន | ១,០០០ JPY | ៥០០ JPY |
| ផោន | ១០០ GBP | ៥០ GBP |
| បាត | ៣,៥០០ THB | ១,៥០០ THB |

(ប្រភព៖ តារាងអត្រាការប្រាក់ និងគេហទំព័រផ្លូវការរបស់ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី)

(ឧបសម្ព័ន្ធទី១១)

**៣.១.៩.៣. អត្រាការប្រាក់**

ការប្រើប្រាស់គណនីនេះ អតិថិជនមិនទទួលបានការប្រាក់ទេ។

## ៣.២. ការគណនាការប្រាក់ និងការកាត់ពន្ធ

### ៣.២.១. ការគណនាការប្រាក់

សម្រាប់ការប្រើប្រាស់រាល់គណនីប្រាក់បញ្ញើ-សន្សំដែលទទួលបានការប្រាក់ នោះការប្រាក់ដែលធនាគារផ្តល់ជូនអតិថិជន ត្រូវបានគណនាឡើងតាមរូបមន្តដូចខាងក្រោម៖

រូបមន្ត៣.២.១ រូបមន្តសម្រាប់គណនាការប្រាក់ជូនអតិថិជន

$$I = P \times r \times t$$

### ៣.២.២. ការកាត់ពន្ធ

យោងតាមការកំណត់របស់ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី សម្រាប់ការកាត់ពន្ធលើការប្រាក់របស់គណនីសន្សំគ្មានកាលកំណត់ ត្រូវបានអនុវត្តដូចខាងក្រោម៖

- កាត់ ៤% សម្រាប់និវាសជន
- កាត់ ៦% សម្រាប់អនិវាសជន

ដោយឡែក សម្រាប់ការកាត់ពន្ធលើការប្រាក់របស់គណនីសន្សំមានកាលកំណត់ ត្រូវបានអនុវត្តដូចខាងក្រោម៖

- កាត់ ៦% សម្រាប់និវាសជន
- កាត់ ១២% សម្រាប់អនិវាសជន

## ៣.៣. ឯកសារចាំបាច់ដើម្បីបើកគណនីប្រាក់បញ្ញើ-សន្សំ

### ៣.៣.១. សម្រាប់បុគ្គល

- ឯកសារចម្បង៖
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិកម្ពុជា
  - ឬលិខិតឆ្លងដែន

ក្នុងករណីអ្នកមិនមានឯកសារចម្បង សូមភ្ជាប់មកជាមួយនូវឯកសារចំនួន២ ក្នុងចំណោមឯកសារបន្ទាប់បន្សំខាងក្រោម៖

- សំបុត្រកំណើត
- សៀវភៅស្នាក់នៅ
- លិខិតអាពាហ៍ពិពាហ៍

- លិខិតស្នាក់នៅចេញដោយរដ្ឋាភិបាល
- សៀវភៅគ្រួសារដែលមានរូបថតសាមីខ្លួនជាមេគ្រួសារ
- ប័ណ្ណបើកបរ

ក្នុងចំណោមឯកសារបន្ទាប់បន្សំទាំងពីរខាងលើ មានមួយចាំបាច់ត្រូវមានរូបថតសាមីខ្លួន។ ឧទាហរណ៍៖ ប័ណ្ណបើកបរ និងសំបុត្រកំណើត។

### ៣.៣.២. សម្រាប់កុមារ

- សំបុត្រកំណើត ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិកម្ពុជា ឬ
- លិខិតឆ្លងដែន។

### ៣.៣.៣. សម្រាប់ក្រុមហ៊ុន សហគ្រាស ឬស្ថាប័ន

- អត្តសញ្ញាណប័ណ្ណសញ្ជាតិកម្ពុជា ឬលិខិតឆ្លងដែនរបស់ក្រុមប្រឹក្សាភិបាល អ្នកតំណាងស្របច្បាប់ សម្រាប់ការគ្រប់គ្រងគណនី និងហត្ថលេខីមានការអនុញ្ញាត
- វិញ្ញាបនបត្រចេញដោយក្រសួងពាណិជ្ជកម្ម
- លក្ខន្តិកៈក្រុមហ៊ុន
- លិខិតគោលការណ៍ចេញដោយក្រសួងពាណិជ្ជកម្ម
- ប្រកាសប្រតិវេទន៍ប្រចាំឆ្នាំចុងក្រោយជាមួយក្រសួងពាណិជ្ជកម្ម
- ប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយ
- សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគហ៊ុន
- ឯកសារផ្សេងៗអាស្រ័យលើប្រភេទស្ថាប័ន ក្រុមហ៊ុន។ (ឧបសម្ព័ន្ធទី១២)

### ៣.៣.៤. សម្រាប់អនិវាសជន

- លិខិតឆ្លងដែន
- ទិដ្ឋាការស្នាក់នៅប្រទេសកម្ពុជាមានរយៈពេលចាប់ពី៣ខែឡើងទៅ
- លិខិតបញ្ជាក់ការងារនៅក្នុងប្រទេសកម្ពុជា។

## ៣.៤. ប្រតិបត្តិការសេវាប្រាក់បញ្ញើ-សន្សំ

គ្រប់ការធ្វើប្រតិបត្តិការគណនីទាំងអស់ របស់ធនាគារ ហុង លីអុង គឺត្រូវបានធ្វើឡើងដោយគោរពតាមលក្ខខណ្ឌរបស់ធនាគារ។ រាល់ឯកសារ និងពត៌មាននានា ដែលអតិថិជនប្រគល់ជូន

ធនាគារទាំងអស់ គឺត្រូវតែជាឯកសារច្បាប់ដើម ដែលគ្មានការកោសលុប ឬថតចម្លង និងជាពត៌មានដែលគ្រប់គ្រាន់ ត្រឹមត្រូវ និងពិតប្រាកដ។ សម្រាប់ពត៌មាន ឬឯកសារនានារបស់អតិថិជន ធនាគារមិនអាចទទួលយកតាមរយៈសារទូរស័ព្ទដៃ ការបង្ហាប់តាមទូរស័ព្ទ ឬតាមប្រព័ន្ធអេឡិចត្រូនិចជាដាច់ខាត។ រាល់ការស្នើសុំបើក ឬបិទគណនី និងការកែប្រែផ្សេងៗ គឺធនាគារបានតម្រូវអោយអតិថិជនអញ្ជើញមកសាខាណាមួយរបស់ធនាគារដោយផ្ទាល់។ អតិថិជនដែលមានសិទ្ធិប្រើប្រាស់ផលិតផល ឬសេវានានារបស់ធនាគារ ត្រូវតែប្រកាសថាខ្លួនមិនធ្លាប់ក្ស័យធន ប្រព្រឹត្តចោទប្រកាន់អំពីភាពក្ស័យធន ឬកំពុងនៅក្នុងនីតិវិធីក្ស័យធន និងគ្មានការប្តឹងណាមួយដែលបានបញ្ជូនទៅធនាគារជាតិនៃកម្ពុជា ឬតុលាការកម្ពុជា នៅក្នុងរយៈពេល៦ខែចុងក្រោយឡើយ។

### ៣.៤.១. ការបើកគណនី

រាល់ការស្នើសុំបើកគណនី គ្រប់អតិថិជនទាំងអស់ ត្រូវបំពេញពាក្យស្នើសុំបើកគណនីជាឯកត្តបុគ្គល ឬក្រុមហ៊ុន ជាលាយលក្ខណ៍អក្សរនូវពត៌មានលម្អិតអំពី គណនី ម្ចាស់គណនី ពេលមានអាសន្ន និងពត៌មានអំពីអ្នកណែនាំ ដោយភ្ជាប់មកជាមួយនឹងសេចក្តីប្រកាសរបស់អ្នកស្នើសុំនៅខាងខ្នងនៃពាក្យស្នើសុំ ។ អតិថិជនទាំងអស់ ត្រូវតែជាម្ចាស់គណនីផ្ទាល់ និងអះអាងថាពត៌មានលំអិតទាំងអស់ គឺពិតជាត្រឹមត្រូវ ពិតប្រាកដ និងអះអាងថាហត្ថលេខាដែលបានចុះ ក៏ជាគំរូហត្ថលេខាពិតប្រាកដផងដែរ។

ពេលធ្វើប្រតិបត្តិការស្នើសុំបើកគណនីអតិថិជនទាំងអស់ត្រូវប្រគល់ជូនធនាគារនូវ៖

- ឯកសារចាំបាច់ដើម្បីបើកគណនី ដែលធនាគារតម្រូវអោយមាន
- និងពាក្យស្នើសុំបើកគណនី។ (ឧបសម្ព័ន្ធទី១៣)

### ៣.៤.២. ការបិទគណនី

អតិថិជនដែលមានបំណងបិទគណនីរបស់ខ្លួន គឺត្រូវតែបំពេញពាក្យស្នើសុំបិទគណនីជាលាយលក្ខណ៍អក្សរ នៅសាខាណាមួយរបស់ធនាគារដោយផ្ទាល់ ដោយមិនចាំបាច់ជូនដំណឹងជាមុនទេ និងភ្ជាប់មកជាមួយ៖

- សម្រាប់ឯកត្តបុគ្គល (និវាសជន អនិវាសជន និងអនីតិជន)៖
  - អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬសំបុត្រកំណើត
  - ពាក្យស្នើសុំបិទគណនី (ឧបសម្ព័ន្ធទី១៤)
  - និងប្រគល់មកវិញនូវសម្ភារៈទាំងអស់ដែលធនាគារប្រគល់ជូនមានដូចជា សៀវភៅ

គណនីសន្សំ របាយការណ៍ប្រតិបត្តិការប្រចាំខែ សៀវភៅមូលប្បទានបត្រ កាត(ATM) វិញ្ញាបនបត្រគណនីមានកាលកំណត់ ជាដើម។ល។

- សម្រាប់ក្រុមហ៊ុនៈ
  - អ្នកដែលពាក់ព័ន្ធពេលស្នើសុំបើកគណនី ត្រូវអញ្ជើញមកធនាគារដើម្បីស្នើសុំបិទគណនី(ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន)
  - ពាក្យស្នើសុំបិទគណនី
  - និងប្រគល់មកវិញនូវសម្ភារៈទាំងអស់ដែលធនាគារប្រគល់ជូនមានដូចជា សៀវភៅគណនីសន្សំ របាយការណ៍ប្រតិបត្តិការប្រចាំខែ សៀវភៅមូលប្បទានបត្រ កាត(ATM) វិញ្ញាបនបត្រគណនីមានកាលកំណត់ ជាដើម។ល។
- សម្រាប់ធនាគារផ្ទាល់ៈ

ប្រសិនបើ គណនីរបស់អតិថិជនមានសមតុល្យសូន្យ លើសពីមួយខែ ធនាគារនឹងធ្វើការបិទដំណើរការប្រតិបត្តិការទាំងអស់របស់គណនីនោះ ទោះបីអតិថិជនមិនអញ្ជើញមកបិទគណនីក៏ដោយ ដោយធនាគារបានជូនដំណឹងទៅអតិថិជនជាមុន។ ទោះបីជា គណនីអតិថិជនមានសម-តុល្យសូន្យក៏ពិតមែន អោយតែចំនួននោះ នៅក្រោមចំនួនអប្បបរមាដែលត្រូវរក្សាក្នុងគណនីប្រចាំខែ គឺអតិថិជនត្រូវតែបង់សងថ្លៃពិន័យ តាមគោលការណ៍ដែលធនាគារបានកំណត់។ ធនាគារនឹងស្នើអោយអតិថិជន បង់ថ្លៃពិន័យ និងប្រគល់មកវិញនូវសម្ភារៈទាំងអស់ ដែលធនាគារប្រគល់ជូនមានដូចជា សៀវភៅគណនីសន្សំ របាយការណ៍ប្រតិបត្តិការប្រចាំខែ សៀវភៅមូលប្បទានបត្រ កាត(ATM) វិញ្ញាបនបត្រគណនីមានកាលកំណត់ ជាដើម។ល។

### ៣.៤.៣. ការកែប្រែ

ចំពោះការកែប្រែនូវរាល់ពត៌មានគណនីផ្សេងៗ អតិថិជនដែលពាក់ព័ន្ធទាំងអស់ ត្រូវចូលរួមស្នើសុំពាក្យដើម្បីកែប្រែនូវពត៌មានគណនី ដោយភ្ជាប់មកនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬសំបុត្រកំណើត នៅតាមសាខាណាមួយរបស់ធនាគារ ដោយមិនចាំបាច់ជូនដំណឹងជាមុនឡើយ។ (ឧបសម្ព័ន្ធទី១៤)

**សម្គាល់ៈ** សម្រាប់ការបិទ និងកែប្រែគណនី

- ចំពោះគណនីឯកត្តជនៈ ម្ចាស់គណនីផ្ទាល់ជាអ្នកមានសិទ្ធិបិទ ឬកែប្រែគណនី
- ចំពោះគណនីក្រុមហ៊ុនៈ ភាគីដែលពាក់ព័ន្ធទាំងអស់ជាអ្នកមានសិទ្ធិបិទ ឬកែប្រែគណនី

- ចំពោះគណនីរួមៈ រាល់ការបិទ ឬការកែប្រែគណនី គឺត្រូវតែមានការយល់ស្របទាំងអស់គ្នា។
- ករណីម្ចាស់គណនីទទួលមរណៈភាព ឬបាត់ខ្លួនៈ អ្នកទទួលមរតក ជាអ្នកមានសិទ្ធិបិទ ឬកែប្រែគណនី។ បើគ្មានអ្នកទទួលមរតកទេនោះ សាច់ញាតិជាអ្នកមានសិទ្ធិ ដោយភ្ជាប់មកជាមួយនូវលិខិតមរណៈភាព ឬឯកសារណា ដែលអាចបញ្ជាក់ពីទំនាក់ទំនងសាច់ញាតិ និងឯកសារសម្គាល់ខ្លួនរបស់អ្នកបិទ ឬកែប្រែគណនីជំនួស។

## ៣.៥. យុទ្ធសាស្ត្រប្រមូលប្រាក់បញ្ញើ

ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក បានរៀបចំនូវយុទ្ធសាស្ត្រក្នុងការប្រមូលប្រាក់បញ្ញើ ដែលសមស្របទៅតាមបរិបទទីផ្សារនាពេលបច្ចុប្បន្ននេះ។ ដូចនេះ យុទ្ធសាស្ត្រក្នុងការប្រមូលប្រាក់បញ្ញើរបស់ធនាគារ ហុង លីអុង មានដូចជាៈ

### ៣.៥.១. យុទ្ធសាស្ត្រទាក់ទាញអតិថិជន

យុទ្ធសាស្ត្រទាក់ទាញអតិថិជន អោយប្រើប្រាក់សេវាប្រាក់បញ្ញើ-សន្សំ របស់ធនាគារ ហុង-លីអុង មានដូចជាៈ

- បង្កើតផលិតផលប្រាក់បញ្ញើ-សន្សំ ដែលប្រកបដោយភាពច្នៃប្រឌិត ឌីជីថល បច្ចេក-វិទ្យាខ្ពស់ និងភាពទាក់ទាញដល់អតិថិជន
- បណ្តុះបណ្តាលបុគ្គលិកអោយមានក្រមសីលធម៌ល្អក្នុងការទទួលស្វាគមន៍ និងឆ្លើយតបនឹងតម្រូវការនានារបស់អតិថិជន
- បុគ្គលិកត្រូវតែស្វែងយល់អោយបានច្បាស់នូវពត៌មានដែលពាក់ព័ន្ធនឹងផលិតផលប្រាក់បញ្ញើ-សន្សំ របស់ធនាគារ ដើម្បីណែនាំទៅកាន់អតិថិជន អោយមានការចាប់អារម្មណ៍ចំពោះផលិតផល
- ហ្វឹកហ្វឺនបុគ្គលិកគ្រប់ផ្នែកទាំងអស់អោយមានភាពបត់បែន និងភាពឆ្លាតវៃក្នុងការដោះ-ស្រាយបញ្ហានានាជូនអតិថិជន
- ផ្តល់ជូនអតិថិជននូវអត្រាការប្រាក់ក្នុងកម្រិតមួយខ្ពស់ ធៀបនឹងដៃគូប្រកួតប្រជែង
- បង្កើនការសហការជាមួយមជ្ឈដ្ឋាននានា ដើម្បីអោយអតិថិជនទទួលបានការបញ្ចុះតម្លៃតាមរយៈការបញ្ជាទិញតាមកាត(ATM) ពិសេស។

### ៣.៥.២. យុទ្ធសាស្ត្រថែរក្សាអតិថិជន

ធនាគារ បានប្រើប្រាស់យុទ្ធសាស្ត្រក្នុងការទាក់ទាញអតិថិជន ប៉ុន្តែអ្វីដែលសំខាន់នោះគឺ ធនាគារ ត្រូវស្វែងរកនូវយុទ្ធសាស្ត្រក្នុងការថែរក្សាអតិថិជនរបស់ខ្លួនដែលមានស្រាប់ដូចជា៖

- រក្សាអោយបាននូវក្រមសីលធម៌ល្អជូនអតិថិជន
- បន្តរក្សាទំនាក់ទំនងល្អជាមួយអតិថិជន
- អភិវឌ្ឍសេវាប្រាក់បញ្ញើ-សន្សំ អោយកាន់តែមានភាពល្អប្រសើរឡើង
- ផ្តល់ភាពងាយស្រួលដល់ការប្រើប្រាស់ប្រតិបត្តិការនានា របស់សេវាប្រាក់បញ្ញើ-សន្សំ និងការបំពេញឯកសារផ្សេងៗ
- បង្កើនទំនុកចិត្តជូនអតិថិជនពីសុវត្ថិភាពក្នុងការដាក់ប្រាក់បញ្ញើនៅធនាគារ ហុង លីអុង
- ផ្តល់ជូនអតិថិជននូវវត្ថុអនុស្សាវរីយ៍ផ្សេងៗ។

### ៣.៥.៣. យុទ្ធសាស្ត្រផ្សព្វផ្សាយ

ធនាគារ បានរៀបចំនូវយុទ្ធសាស្ត្រក្នុងការផ្សព្វផ្សាយពីផលិតផល និងអត្ថប្រយោជន៍នៃការប្រើប្រាស់សេវាប្រាក់បញ្ញើ-សន្សំ តាមរយៈមធ្យោបាយផ្សេងៗដូចជា ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធអ៊ីនធើណិត ទូរទស្សន៍ ខិតប័ណ្ណផ្សព្វផ្សាយ ផ្ទាំងប៉ាណូ និងវីឌីអូផ្សព្វផ្សាយពាណិជ្ជកម្មតាមបណ្តាញសង្គមនានា ដើម្បីទាក់ទាញអតិថិជនបន្ថែមទៀត។

## ៣.៦. ហានិភ័យប្រាក់បញ្ញើ និងវិធីទប់ស្កាត់ហានិភ័យ

ហានិភ័យប្រាក់បញ្ញើ សំដៅដល់ការខាតបង់នានាទាក់ទងនឹងប្រាក់បញ្ញើ ដែលធនាគារអាចជួបប្រទះ។

### ៣.៦.១. រូបិយប័ណ្ណក្លែងក្លាយ

របរអាជីវកម្មក្នុងវិស័យធនាគារ គឺត្រូវតែប្រឈមមុខជាមួយនឹងហានិភ័យចំពោះរូបិយប័ណ្ណក្លែងក្លាយ ដោយសាររូបិយប័ណ្ណក្លែងក្លាយ មានលក្ខណៈស្រដៀងគ្នាខ្លាំងទៅនឹងរូបិយប័ណ្ណពិតដែលធ្វើអោយគេពិបាកនៅក្នុងការត្រួតពិនិត្យទៅលើសាច់ប្រាក់។

ដូចនេះ ដើម្បីទប់ស្កាត់នូវបញ្ហាបែបនេះកុំអោយកើតមានឡើង ដែលអាចជាហេតុនាំអោយធនាគារជួបប្រទះនូវបញ្ហាសាច់ប្រាក់នោះ ធនាគារ ហុង លីអុង បានបង្កើតនូវវិធានការការពារនូវរាល់បញ្ហាទាំងអស់នេះ។ ចំពោះបញ្ហានេះដែរ ធនាគារបានបណ្តុះបណ្តាល និងណែនាំបុគ្គលិកដែលទទួលបន្ទុកពាក់ព័ន្ធនឹងបញ្ហានេះអំពី របៀប និងការយកចិត្តទុកដាក់ខ្ពស់ក្នុងការពិនិត្យទៅ

លើសាច់ប្រាក់រវាងរូបិយប័ណ្ណក្លែងក្លាយ និងរូបិយប័ណ្ណពិត ដោយធ្វើការផ្ទៀងផ្ទាត់បន្ថែមជាមួយនឹងម៉ាស៊ីនរាប់សាច់ប្រាក់ ដើម្បីបញ្ជាក់អោយកាន់តែច្បាស់ថា រូបិយប័ណ្ណដែលខ្លួនកំពុងកាន់ គឺជារូបិយប័ណ្ណក្លែងក្លាយ ឬពិតប្រាកដ។ ប្រសិនបើ ធនាគារបានរកឃើញថា រូបិយប័ណ្ណដែលខ្លួនកំពុងកាន់ជារូបិយប័ណ្ណក្លែងក្លាយនោះ ធនាគារនឹងជម្រាបពត៌មានជូនអតិថិជន តែធនាគារមិនប្រគល់រូបិយប័ណ្ណក្លែងក្លាយទាំងអស់នោះ ជូនអតិថិជនវិញជាដាច់ខាត។ កន្លងមកនេះ ធនាគារហុង លីអុង សាខាផ្សារអូឡាំពិក មិនដែលជួបប្រទះនូវបញ្ហាមួយនេះឡើយ។

### ៣.៦.២. អសមតុល្យរវាងប្រាក់បញ្ញើ និងឥណទាន

ធនាគារ បានប្រើប្រាស់ប្រាក់បញ្ញើរបស់អតិថិជន ក្នុងការផ្តល់កម្ចីទៅកាន់ពួកគេវិញ។ ទោះបីជាអត្រាការប្រាក់ ដែលធនាគារទទួលបានពីការផ្តល់កម្ចី មានកម្រិតខ្ពស់ជាងអត្រាការប្រាក់ដែលធនាគារផ្តល់ជូនអ្នកដាក់ប្រាក់បញ្ញើក៏ពិតមែន តែវាពិតជាសំខាន់ណាស់ដែលធនាគារត្រូវធ្វើអោយមានសមតុល្យរវាងប្រាក់បញ្ញើ និងឥណទាន។ ប្រសិនបើ ធនាគារផ្តល់កម្ចីច្រើនហួសកម្រិតពេកនោះ ធនាគារអាចជួបប្រទះនូវបញ្ហានៅពេលដែលអតិថិជនធ្វើការដកប្រាក់ ដោយធនាគារពុំមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់អតិថិជន។ ក៏ប៉ុន្តែ បើចំនួនប្រាក់បញ្ញើនៅសល់ច្រើន ហើយធនាគារបញ្ចេញឥណទានមិនទាន់ទេនោះ វានឹងបណ្តាលអោយធនាគារមានការខាតបង់ ហើយការប្រាក់ដែលធនាគារផ្តល់ជូនអ្នកដាក់ប្រាក់បញ្ញើ គឺមិនសមាមាត្រទៅនឹងការប្រាក់ដែលធនាគារទទួលបានពីការផ្តល់ឥណទានឡើយ។

ដូចនេះ ធនាគារបានប្រើប្រាស់នូវយុទ្ធសាស្រ្តដែលល្អៗ ក្នុងការបញ្ចេញឥណទានអោយបានច្រើន និងទាក់ទាញអតិថិជនអោយដាក់ប្រាក់បញ្ញើនៅធនាគារ ដោយអភិវឌ្ឍសេវាកម្មទាំងពីរប្រភេទនេះ អោយកាន់តែមានភាពលេចធ្លោព្រមគ្នានៅលើទីផ្សារប្រកួតប្រជែង។ ប៉ុន្តែធនាគារត្រូវធានាអោយបាននូវសមតុល្យរវាងសេវាទាំងពីរប្រភេទនេះ ដើម្បីជៀសវាងពីបញ្ហានានាដែលធនាគារនឹងត្រូវប្រឈម ប្រសិនបើមានករណីខាងលើកើតឡើង។

### ៣.៦.៣. បទល្មើសលាងលុយកង្វក់

ការលាងលុយកង្វក់ គឺជាអំពើខុសច្បាប់ ហើយធនាគារបានយកចិត្តទុកដាក់ខ្លាំងបំផុតចំពោះករណីបែបនេះ ពេលដែលអតិថិជនស្នើសុំបើកគណនីប្រាក់បញ្ញើ-សន្សំ នៅក្នុងបរិមាណទឹកប្រាក់ដ៏ច្រើនមួយ។ ដូចនេះ ធនាគារបានអនុវត្តការងារយ៉ាងល្អិតល្អន់ មុនពេលសម្រេចបើកគណនីជូនអតិថិជន ដោយសាកសួរលម្អិតអំពីពត៌មានផ្ទាល់ខ្លួន ជាពិសេសប្រភពចំណូលរបស់

អតិថិជន និងស្នើសុំនូវលិខិត ឬឯកសារណា ដែលអាចបញ្ជាក់ពីប្រភពចំណូលទាំងនោះបាន។ ដោយសារតែធនាគារមានប្រព័ន្ធគ្រប់គ្រងល្អ ដូចនេះធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក មិនដែលមានករណីបែបនេះ កើតឡើងនោះទេ។ (ឧបសម្ព័ន្ធទី១៥)

#### ៣.៦.៤ ការដកសាច់ប្រាក់មុនកាលកំណត់

ធនាគារ បានអនុញ្ញាតអោយអតិថិជនដកប្រាក់បញ្ញើរបស់ខ្លួនមុនកាលកំណត់បាន។ ប៉ុន្តែ អ្វីដែលចោទជាបញ្ហាសំខាន់សម្រាប់ធនាគារនោះគឺ អតិថិជនច្រើនបានមកដកប្រាក់បញ្ញើរបស់ខ្លួនមុនកាលកំណត់ស្របពេលគ្នា ដែលធ្វើអោយធនាគារបង្វិលប្រាក់ជូនអតិថិជនមិនទាន់។ ដូចនេះ ដើម្បីជៀសវាងពីបញ្ហានេះ ធនាគារ បានស្នើសុំអោយអតិថិជនផ្តល់ដំណឹងជាមុន នៅពេលដែលអតិថិជនត្រូវការដកសាច់ប្រាក់មុនកាលកំណត់ក្នុងចំនួនមួយដែលច្រើន។

## ៣.៧. លទ្ធផលនៃការស្រាវជ្រាវ

ខាងក្រោមនេះ គឺជាទិន្នន័យនៃសមតុល្យគណនីប្រាក់បញ្ញើ-សន្សំទាំងអស់ របស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក ចាប់ពីឆ្នាំ ២០១៥ ដល់ ២០១៧ ដែលជាលទ្ធផលនៃការស្រាវជ្រាវកន្លងមក នៅធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក។

### ៣.៧.១. សមតុល្យប្រាក់បញ្ញើ-សន្សំពីឆ្នាំ ២០១៥ ដល់ ២០១៧ របស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក

#### ៣.៧.១.១. សមតុល្យគណនីប្រាក់សន្សំ

តារាង៣.៧.១.១ សមតុល្យគណនីប្រាក់សន្សំពីឆ្នាំ ២០១៥ ដល់ ២០១៧

| ឆ្នាំ | 2015 | 2016 | 2017 |
|---|---|---|---|
| សមតុល្យ | $2,491,530 | $2,921,559 | $4,436,960 |
| បម្រែបម្រួលជាទឹកប្រាក់ | - | $430,029 | $1,515,401 |
| អត្រាបម្រែបម្រួល | - | 17.25% | 51.87% |

(ប្រភព៖ នាយកដ្ឋានសេវាធនាគារសម្រាប់អតិថិជនបុគ្គលរបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក)

**ក្រាហ្វិក៣.៧.១.១៖** សមតុល្យគណនីប្រាក់សន្សំពីឆ្នាំ ២០១៥ ដល់ ២០១៧




យោងតាមតារាង៣.៧.១.១ និងក្រាហ្វិកខាងលើ យើងឃើញថា នៅឆ្នាំ២០១៥ សមតុល្យទឹកប្រាក់សរុបដែលមាននៅក្នុងគណនីប្រាក់សន្សំមានចំនួន ២,៤៩១,៥៣០ ដុល្លារអាមេរិក ដែលចំនួននេះត្រូវកើនឡើងទៅដល់ ២,៩២១,៥៥៩ ដុល្លារអាមេរិក នៅឆ្នាំ២០១៦ គិតជាទឹកប្រាក់គឺកើនឡើងចំនួន ៤៣០,០២៩ ដុល្លារអាមេរិក ស្មើនឹងកំណើន ១៧.២៥%។ ត្រឹមតែរយៈពេលមួយឆ្នាំប៉ុណ្ណោះ សមតុល្យទឹកប្រាក់សរុបដែលមានក្នុងគណនីនេះ បានកើនឡើងពី ២,៩២១,៥៥៩ ដុល្លារអាមេរិក នៅឆ្នាំ២០១៦ ឡើងទៅដល់ ៤,៤៣៦,៩៦០ ដុល្លារអាមេរិក នៅឆ្នាំ២០១៧ បើគិតជាទឹកប្រាក់ គឺបានកើនឡើងចំនួន ១,៥១៥,៤០១ ដុល្លារអាមេរិក ស្មើនឹងកំណើន ៥១.៨៧%។

### ៣.៧.១.២. សមតុល្យគណនីចរន្ត

តារាង៣.៧.១.២ សមតុល្យគណនីចរន្តពីឆ្នាំ ២០១៥ ដល់ ២០១៧

| ឆ្នាំ | 2015 | 2016 | 2017 |
|---|---|---|---|
| សមតុល្យ | $2,863,790 | $5,886,896 | $9,954,661 |
| បម្រែបម្រួលជាទឹកប្រាក់ | - | $3,023,106 | $4,067,765 |
| អត្រាបម្រែបម្រួល | - | 105.56% | 69.10% |

(ប្រភព៖ នាយកដ្ឋានសេវាធនាគារសម្រាប់អតិថិជនបុគ្គលរបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក)

**ក្រាហ្វិក៣.៧.១.២៖** សមតុល្យគណនីចរន្តពីឆ្នាំ ២០១៥ ដល់ ២០១៧




យោងតាមតារាង៣.៧.១.២ និងក្រាហ្វិកខាងលើ យើងអាចសន្និដ្ឋានបានថា នៅឆ្នាំ២០១៥ សមតុល្យទឹកប្រាក់សរុបដែលមាននៅក្នុងគណនីប្រាក់ចរន្តនេះ មានចំនួន ២,៨៦៣,៧៩០ ដុល្លារអាមេរិក ដែលចំនួននេះត្រូវបានកើនឡើងទៅដល់ ៥,៨៨៦,៨៩៦ ដុល្លារអាមេរិក នៅឆ្នាំ២០១៦ ដែលគិតជាទឹកប្រាក់ គឺបានកើនឡើងចំនួន ៣,០២៣,១០៦ ដុល្លារអាមេរិក ស្មើនឹងកំណើន ១០៥.៥៦%។ ត្រឹមតែរយៈពេលមួយឆ្នាំ សមតុល្យទឹកប្រាក់សរុបដែលមាននៅក្នុងគណនីនេះ បានកើនឡើងគួរអោយកត់សម្គាល់ពីចំនួន ៥,៨៨៦,៨៩៦ ដុល្លារអាមេរិក នៅឆ្នាំ២០១៦ ទៅដល់ ៩,៩៥៤,៦៦១ ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១៧ បើគិតជាទឹកប្រាក់ គឺមានការកើនឡើងចំនួន ៤,០៦៧,៧៦៥ ដុល្លារអាមេរិក ស្មើនឹងកំណើន ៦៩.១០%។

### ៣.៧.១.៣. សមតុល្យគណនីប្រាក់បញ្ញើមានកាលកំណត់

#### ៣.៧.១.៣.១. សម្រាប់គណនីបុគ្គល

តារាង៣.៧.១.៣.១ សមតុល្យគណនីប្រាក់បញ្ញើមានកាលកំណត់សម្រាប់គណនីបុគ្គលពីឆ្នាំ ២០១៥ ដល់ ២០១៧

| ឆ្នាំ | 2015 | 2016 | 2017 |
|---|---|---|---|
| សមតុល្យ | $19,063,734 | $49,961,068 | $128,889,445 |
| បម្រែបម្រួលជាទឹកប្រាក់ | - | $30,897,334 | $78,928,377 |
| អត្រាបម្រែបម្រួល | - | 162.07% | 157.98% |

(ប្រភព៖ នាយកដ្ឋានសេវាធនាគារសម្រាប់អតិថិជនបុគ្គលរបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក)

**ក្រាហ្វិក៣.៧.១.៣.១៖** សមតុល្យគណនីប្រាក់បញ្ញើមានកាលកំណត់(គណនីបុគ្គល)ពីឆ្នាំ២០១៥-២០១៧




យោងតាមតារាង៣.៧.១.៣.១ និងក្រាហ្វិក ដែលបានបង្ហាញខាងលើ យើងអាចសន្និដ្ឋានបានថា សមតុល្យទឹកប្រាក់សរុប ដែលមាននៅក្នុងគណនីប្រាក់បញ្ញើមានកាលកំណត់ សម្រាប់គណនីបុគ្គល មានការរីកលូតលាស់ទៅមុខយ៉ាងខ្លាំង ពីមួយឆ្នាំទៅមួយឆ្នាំ។ ដោយសមតុល្យទឹកប្រាក់សរុបនៅក្នុងគណនីនេះ មានចំនួនត្រឹម ១៩,០៦៣,៧៣៤ ដុល្លារអាមេរិក ប៉ុណ្ណោះ ក្នុងឆ្នាំ ២០១៥ តែចំនួននេះត្រូវបានកើនឡើងទៅដល់ ៤៩,៩៦១,០៦៨ ដុល្លារអាមេរិក នៅឆ្នាំ២០១៦ ដែលគិតជាទឹកប្រាក់ គឺបានកើនឡើងចំនួន ៣០,៨៩៧,៣៣៤ ដុល្លារអាមេរិក ស្មើនឹងកំណើន ១៦២.០៧%។ ត្រឹមតែរយៈពេលមួយឆ្នាំ សមតុល្យទឹកប្រាក់សរុបដែលមាននៅក្នុងគណនីនេះ មានសន្ទុះកើនឡើងយ៉ាងខ្លាំងពី ៤៩,៩៦១,០៦៨ ដុល្លារអាមេរិក នៅឆ្នាំ២០១៦ ឡើងទៅដល់ ១២៨,៨៨៩,៤៤៥ ដុល្លារអាមេរិក នៅឆ្នាំ២០១៧ បើគិតជាទឹកប្រាក់ គឺមានការកើនឡើងចំនួន ៧៨,៩២៨,៣៣៧ ដុល្លារអាមេរិក ស្មើនឹងកំណើន ១៥៧.៩៨%។

#### ៣.៧.១.៣.២. សម្រាប់គណនីអាជីវកម្ម

តារាង៣.៧.១.៣.២ សមតុល្យគណនីប្រាក់បញ្ញើមានកាលកំណត់(គណនីអាជីវកម្ម)ពីឆ្នាំ២០១៥ ដល់ ២០១៧

| ឆ្នាំ | 2015 | 2016 | 2017 |
|---|---|---|---|
| សមតុល្យ | $29,230,372 | $42,674,804 | $39,852,231 |
| បម្រែបម្រួលជាទឹកប្រាក់ | - | $13,444,432 | -$2,822,573 |
| អត្រាបម្រែបម្រួល | - | 45.99% | -6.61% |

(ប្រភពៈ នាយកដ្ឋានសេវាធនាគារសម្រាប់អតិថិជនបុគ្គលរបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក)

**ក្រាហ្វិក៣.៧.១.៣.២ៈ**សមតុល្យគណនីប្រាក់បញ្ញើមានកាលកំណត់(គណនីអាជីវកម្ម)ពីឆ្នាំ២០១៥-២០១៧




យោងតាមតារាង៣.៧.១.៣.២ និងក្រាហ្វិកខាងលើ យើងអាចសន្និដ្ឋានបានថា សមតុល្យទឹកប្រាក់សរុប ដែលមាននៅក្នុងគណនីប្រាក់បញ្ញើមានកាលកំណត់ សម្រាប់គណនីអាជីវកម្ម គឺមានការកើនឡើងពី ២៩,២៣០,៣៧២ ដុល្លារអាមេរិក នៅឆ្នាំ២០១៥ រហូតដល់ ៤២,៦៧៤,៨០៤ ដុល្លារអាមេរិក នៅឆ្នាំ២០១៦។ ពោលគឺ មានការកើនឡើងជាចំនួនទឹកប្រាក់ ១៣,៤៤៤,៤៣២ ដុល្លារអាមេរិក ស្មើនឹងកំណើន ៤៥.៩៩%។ ប៉ុន្តែ សមតុល្យទឹកប្រាក់នៅក្នុងគណនីនេះ បានធ្លាក់ចុះវិញ នៅឆ្នាំ២០១៧ ដោយសល់ត្រឹមតែ ៣៩,៨៥២,២៣១ ដុល្លារអាមេរិក ដែលគិតជាទឹកប្រាក់ គឺបានថយចុះចំនួន ២,៨២២,៥៧៣ ដុល្លារអាមេរិក ស្មើនឹងថយចុះ ៦.៦១%។

### ៣.៧.១.៤. សមតុល្យគណនីប្រាក់សន្សំសម្រាប់កុមារ

តារាង៣.៧.១.៤ សមតុល្យគណនីប្រាក់សន្សំសម្រាប់កុមារពីឆ្នាំ ២០១៥ ដល់ ២០១៧

| ឆ្នាំ | 2015 | 2016 | 2017 |
|---|---|---|---|
| សមតុល្យ | - | $69,894 | $149,189 |
| បម្រែបម្រួលជាទឹកប្រាក់ | - | - | $79,295 |
| អត្រាបម្រែបម្រួល | - | - | 113.45% |

(ប្រភពៈ នាយកដ្ឋានសេវាធនាគារសម្រាប់អតិថិជនបុគ្គលរបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក)

**ក្រាហ្វិក៣.៧.១.៤៖** សមតុល្យគណនីប្រាក់សន្សំសម្រាប់កុមារពីឆ្នាំ ២០១៥ ដល់ ២០១៧




គណនីប្រាក់សន្សំសម្រាប់កុមារ គឺជាគណនីថ្មីមួយ របស់ធនាគារ ហុង លីអុង សាខាផ្សារ-អូឡាំពិក ដែលបានដាក់អោយមានប្រតិបត្តិការ ចាប់ពីឆ្នាំ២០១៦។ ហេតុដូច្នេះហើយ បានជានៅឆ្នាំ២០១៥ តារាងខាងលើនេះ បានបង្ហាញថាគ្មានសមតុល្យនៅក្នុងគណនីឡើយ។ ដោយយោងតាមតារាង៣.៧.១.៤ និងក្រាហ្វិកខាងលើនេះ យើងឃើញថា ចាប់ពីឆ្នាំ២០១៦ ចំនួនសមតុល្យទឹកប្រាក់សរុប ដែលមាននៅក្នុងគណនីប្រាក់សន្សំសម្រាប់កុមារ មានចំនួន ៦៩,៨៩៤ ដុល្លារអាមេរិក។ បន្តមកដល់ឆ្នាំ២០១៧ សមតុល្យទឹកប្រាក់ដែលមានក្នុងគណនីនេះ មានការកើនឡើងគួរអោយកត់សម្គាល់ ពោលគឺ នៅឆ្នាំ២០១៧ ចំនួនសមតុល្យទឹកប្រាក់សរុប ដែលមាននៅក្នុងគណនីនេះ គឺមានចំនួន ១៤៩,១៨៩ ដុល្លារអាមេរិក ដែលបានកើនឡើងគិតជាទឹកប្រាក់ចំនួន ៧៩,២៩៥ ដុល្លារអាមេរិក ស្មើនឹងកំណើន ១១៣.៤៥%។

### ៣.៧.១.៥. សមតុល្យគណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិត

តារាង៣.៧.១.៥ សមតុល្យគណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិតពីឆ្នាំ ២០១៥ ដល់ ២០១៧

| ឆ្នាំ | 2015 | 2016 | 2017 |
|---|---|---|---|
| សមតុល្យ | - | $11,968 | $88,840 |
| បម្រែបម្រួលជាទឹកប្រាក់ | - | - | $76,872 |
| អត្រាបម្រែបម្រួល | - | - | 642.31% |

(ប្រភព៖ នាយកដ្ឋានសេវាធនាគារសម្រាប់អតិថិជនបុគ្គលរបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក)

**ក្រាហ្វិក៣.៧.១.៥៖** សមតុល្យគណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិតពីឆ្នាំ ២០១៥ ដល់ ២០១៧




ចំពោះគណនីប្រាក់សន្សំតាមប្រព័ន្ធអ៊ីនធើណិត ក៏ត្រូវបានស្គាល់ថា ជាផលិតផលថ្មីរបស់ធនាគារ ហុង លីអុង ហើយគណនីនេះ ត្រូវបានបើកអោយមានដំណើរការប្រតិបត្តិការ នៅឆ្នាំ ២០១៦ ដូចគណនីប្រាក់សន្សំសម្រាប់កុមារដែរ។ តាមតារាងខាងលើ និងក្រាហ្វិក៣.៧.១.៥ បានបង្ហាញអោយឃើញថា នៅឆ្នាំដំបូងនៃប្រតិបត្តិការគណនីនេះ សមតុល្យទឹកប្រាក់សរុបគឺមានចំនួន ១១,៩៦៨ ដុល្លារអាមេរិក។ ចំណែក នៅឆ្នាំ២០១៧ យើងបានសង្កេតឃើញថា សមតុល្យទឹកប្រាក់នៅក្នុងគណនីនេះ បានកើនឡើងដល់ ៨៨,៨៤០ ដុល្លារអាមរិក។ ពោលគឺ មានការកើនឡើង គិតជាទឹកប្រាក់មានចំនួន ៧៦,៨៧២ ដុល្លារអាមេរិក ស្មើនឹងកំណើន ៦៤២.៣១%។

### ៣.៧.១.៦. សមតុល្យគណនីសេវាអាទិភាព

តារាង៣.៧.១.៦ សមតុល្យគណនីសេវាអាទិភាពពីឆ្នាំ ២០១៥ ដល់ ២០១៧

| ឆ្នាំ | 2015 | 2016 | 2017 |
|---|---|---|---|
| សមតុល្យ | $4,768,197 | $14,987,749 | $43,301,563 |
| បម្រែបម្រួលជាទឹកប្រាក់ | - | $10,219,552 | $28,313,814 |
| អត្រាបម្រែបម្រួល | - | 214.33% | 188.91% |

(ប្រភព៖ នាយកដ្ឋានសេវាធនាគារសម្រាប់អតិថិជនបុគ្គលរបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក)

**ក្រាហ្វិក៣.៧.១.៦៖** សមតុល្យគណនីសេវាអាទិភាពពីឆ្នាំ ២០១៥ ដល់ ២០១៧




យោងតាមតារាង៣.៧.១.៦ និងក្រាហ្វិកខាងលើ យើងសង្កេតឃើញថា បម្រែបម្រួលនៃចំនួនសមតុល្យទឹកប្រាក់ នៅក្នុងគណនីសេវាអាទិភាពពីឆ្នាំ ២០១៥ ដល់ ២០១៧ គឺមានការកើនឡើងជាលំដាប់ មិនមានការថយចុះឡើយ។ នៅក្នុងឆ្នាំ២០១៥ សមតុល្យទឹកប្រាក់សរុបនៅក្នុងគណនីមានចំនួន ៤,៧៦៨,១៩៧ ដុល្លារអាមេរិក ហើយនៅឆ្នាំ២០១៦ ទឹកប្រាក់សរុបនៅក្នុងគណនីបានកើនឡើងទៅដល់ ១៤,៩៨៧,៧៤៩ ដុល្លារអាមេរិក ពោលគឺ មានការកើនឡើងជាចំនួនទឹកប្រាក់ ១០,២១៩,៥៥២ ដុល្លារអាមេរិក ស្មើនឹងកំណើន ២១៤.៣៣%។ ដោយឡែក នៅឆ្នាំ២០១៧ យើងសង្កេតឃើញថា សមតុល្យទឹកប្រាក់ក្នុងគណនីនេះ មានការកើនឡើងរហូតដល់ ៤៣,៣០១,៥៦៣ ដុល្លារអាមេរិក គិតជាចំនួនទឹកប្រាក់ គឺកើនឡើងចំនួន ២៨,៣១៣,៨១៤ ដុល្លារអាមេរិក ស្មើនឹងកំណើន ១៨៨.៩១%។

### ៣.៧.១.៧. សមតុល្យគណនីចរន្តអាជីវកម្ម និងគណនីអាជីវកម្មទទួលបានការប្រាក់

តារាង៣.៧.១.៧ សមតុល្យគណនីចរន្តអាជីវកម្ម និងគណនីអាជីវកម្មទទួលបានការប្រាក់ពីឆ្នាំ២០១៥ ដល់ ២០១៧

| ឆ្នាំ | 2015 | 2016 | 2017 |
|---|---|---|---|
| សមតុល្យ | $4,183,672 | $11,445,349 | $8,316,027 |
| បម្រែបម្រួលជាទឹកប្រាក់ | - | $7,261,677 | -$3,129,322 |
| អត្រាបម្រែបម្រួល | - | 173.57% | -27.34% |

(ប្រភព៖ នាយកដ្ឋានសេវាធនាគារសម្រាប់អតិថិជនបុគ្គលរបស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក)

**ក្រាហ្វិក៣.៧.១.៧៖** សមតុល្យគណនីចរន្តអាជីវកម្ម និងគណនីអាជីវកម្មទទួលបានការប្រាក់ពីឆ្នាំ ២០១៥ ដល់ ២០១៧




យោងតាមតារាង៣.៧.១.៧ និងក្រាហ្វិកខាងលើ យើងអាចសន្និដ្ឋានបានថា សមតុល្យទឹកប្រាក់នៅក្នុងគណនីចរន្តអាជីវកម្ម និងអាជីវកម្មទទួលបានការប្រាក់ពីឆ្នាំ ២០១៥ ដល់ ២០១៧ គឺមានបម្រែបម្រួលឡើងចុះ មិនមានលក្ខណៈស្ថិតស្ថេរ ពីមួយឆ្នាំទៅមួយឆ្នាំនោះទេ។ ដូចទិន្នន័យដែលបានបង្ហាញនេះ សមតុល្យទឹកប្រាក់នៅក្នុងគណនីទាំងពីរ នៅឆ្នាំ២០១៥ គឺមានចំនួនត្រឹមតែ ៤,១៨៣,៦៧២ ដុល្លារអាមេរិក ប៉ុណ្ណោះ។ ប៉ុន្តែ ចំនួននេះបានកើនឡើងទៅដល់ ១១,៤៤៥,៣៤៩ ដុល្លារអាមេរិក នៅឆ្នាំ២០១៦ ពោលគឺ បានកើនឡើងជាទឹកប្រាក់ចំនួន ៧,២៦១,៦៧៧ ដុល្លារអាមេរិក ស្មើនឹងកំណើន ១៧៣.៥៧%។ ក៏ប៉ុន្តែ យើងសង្កេតឃើញថា មានការថយចុះវិញ នូវសមតុល្យទឹកប្រាក់សរុបពី ១១,៤៤៥,៣៤៩ ដុល្លារអាមេរិក នៅឆ្នាំ២០១៦ សល់ត្រឹម ៨,៣១៦,០២៧ ដុល្លារអាមេរិក នៅឆ្នាំ២០១៧ ដែលគិតជាទឹកប្រាក់គឺថយចុះចំនួន ៣,១២៩,៣២២ ដុល្លារអាមេរិក ស្មើនឹងការថយចុះ ២៧.៣៤%។

## ៣.៨. ចំណុចខ្លាំង និងចំណុចខ្សោយ

### ៣.៨.១. ចំណុចខ្លាំង

ខាងក្រោមនេះ ជាចំណុចខ្លាំងរបស់ធនាគារ ហុង លីអុង ដែលមានសក្តានុពលដូចជា៖

- ធនាគារ ហុង លីអុង ជាធនាគារមួយដែលមានលក្ខណៈស្តង់ដារអន្តរជាតិ ព្រមទាំងជាបណ្តាញភ្នាក់ងាររបស់ធនាគារ ដែលឈានមុខគេនៅក្នុងប្រទេសម៉ាឡេស៊ី

- ធនាគារ មានសាខាដែលស្ថិតនៅតំបន់ដែលមានសក្តានុពល និងបានជំរុញអោយអតិថិជន មានភាពងាយស្រួលក្នុងការប្រើប្រាស់សេវាប្រាក់បញ្ញើ-សន្សំ និងសេវាកម្មផ្សេងទៀត
- ធនាគារ មានដៃគូសហការជាច្រើននៅក្នុងប្រទេសម៉ាឡេស៊ី វៀតណាម ហុងកុង ចិន សិង្ហបុរី និងបណ្តាប្រទេសជាច្រើនទៀត
- ជាពិសេសធនាគារ បានផ្តល់ជូននូវជម្រើសជាច្រើនប្រភេទនៃសេវាប្រាក់បញ្ញើ-សន្សំ ប្រកបដោយឌីជីថល និងបច្ចេកវិទ្យាខ្ពស់។ លើសពីនេះទៅទៀត ធនាគារមានការផ្តល់ជូននូវភាពងាយស្រួល សម្រាប់អតិថិជនក្នុងការបើកគណនី ក៏ដូចជាការធ្វើប្រតិបត្តិការគណនីផ្សេងៗបានយ៉ាងឆាប់រហ័ស។

### ៣.៨.២. ចំណុចខ្សោយ

ថ្វីត្បិតតែ ធនាគារ ហុង លីអុង មានចំណុចខ្លាំងរបស់ខ្លួនក៏ពិតមែន តែធនាគារក៏មានចំណុចខ្វះខាតមួយចំនួនដូចខាងក្រោម៖

- ការផ្សព្វផ្សាយពីផលិតផល និងសេវាប្រាក់បញ្ញើ-សន្សំ របស់ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក នៅមានកម្រិតនៅឡើយ
- ធនាគារ ហុង លីអុង មិនទាន់មានសាខានៅតាមបណ្តាខេត្តនោះទេ ដូច្នេះការផ្សព្វផ្សាយពីសេវាប្រាក់បញ្ញើ-សន្សំ មិនទាន់មានភាពទូលំទូលាយ
- ធនាគារ មានប្រភេទកាត(ATM) តែ២ប៉ុណ្ណោះ ដែលធ្វើអោយអតិថិជនមិនអាចប្រើប្រាស់កាតទាំងនោះ នៅក្រៅប្រទេសបាន។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានចុះកម្មសិក្សា និងការសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ លើប្រធានបទស្តីពី "សេវាប្រាក់បញ្ញើ-សន្សំ" នៅធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក រួចមក យើងខ្ញុំសូមធ្វើការសន្និដ្ឋានដូចខាងក្រោម៖

ធនាគារ ហុង លីអុង សាខាផ្សារអូឡាំពិក បានគោរពតាមនូវនីតិវិធី និងគោលការណ៍ ក្នុងការផ្តល់ជូនសេវាប្រាក់បញ្ញើ-សន្សំ បានយ៉ាងត្រឹមត្រូវ ដោយរួមផ្សំជាមួយការអនុវត្តដ៏មានប្រសិទ្ធភាពខ្ពស់ចំពោះការងារជាក់ស្តែង និងផ្តល់ភាពងាយស្រួលដល់អតិថិជន ក្នុងការប្រើប្រាស់សេវាកម្មរបស់ខ្លួន។

ធនាគារ បានផ្តល់សេវាប្រាក់បញ្ញើ-សន្សំ ជូនអតិថិជនប្រកបដោយប្រសិទ្ធភាព និងអត្រាការប្រាក់ ដែលមានលក្ខណៈប្រកួតប្រជែង ដោយផ្សារភ្ជាប់ជាមួយសេវាធនាគារបែបឌីជីថល ដែលទទួលបានការគាំទ្រ និងផ្តល់ភាពស្រួលជូនទៅកាន់អតិថិជនរបស់ខ្លួន។ មិនតែប៉ុណ្ណោះ ធនាគារបានបង្កើតនូវគណនីសេវាអាទិភាព និងគណនីអាជីវកម្មរូបិយប័ណ្ណបរទេស ដែលផ្តល់ជូនអតិថិជននូវអត្ថប្រយោជន៍យ៉ាងច្រើន ព្រមទាំងបានទាក់ទាញអតិថិជន អោយប្រើប្រាស់គណនីទាំងពីរប្រភេទនេះ បានយ៉ាងច្រើនគួរអោយកត់សម្គាល់។

ដោយមានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំរបស់ធនាគារ ក៏បានបណ្តុះបណ្តាលបុគ្គលិកគ្រប់ផ្នែកទាំងអស់ អោយមានក្រមសីលធម៌ល្អក្នុងការប្រាស្រ័យទាក់ទងគ្នា និងទទួលស្វាគមន៍អតិថិជន។ លើសពីនេះទៅទៀត ដោយសារតែយុទ្ធសាស្ត្រក្នុងការថែរក្សា និងទាក់ទាញអតិថិជន ព្រមទាំងការអភិវឌ្ឍនូវផលិតផល និងសេវាកម្មរបស់ខ្លួន បានធ្វើអោយសមតុល្យគណនីប្រាក់បញ្ញើ-សន្សំ ភាគច្រើន មានចំនួនកើនឡើងពីឆ្នាំទៅមួយឆ្នាំ។

